# កម្មវិធីគាំទ្រវិស័យអប់រំកុមារដែលរស់នៅតំបន់ដាច់ស្រយាល

## (អេស្កាប់)

EQUIP1
Educational Quality Improvement Program
Classrooms • Schools • Communities

# វគ្គបណ្ដុះបណ្ដាលបន្ថែមសម្រាប់គ្រូសហគមន៍

# រយៈពេល ៣ ថ្ងៃ




# សៀវភៅសម្រាប់អ្នកសម្របសម្រួល

ខេត្តកំពង់ចាម ប្រទេសកម្ពុជា

ខែតុលា ឆ្នាំ២០០៦

# អេស្ដាប់

## វគ្គបណ្ដុះបណ្ដាលបន្ថែមរយៈពេល៧ថ្ងៃ សម្រាប់គ្រូសហគមន៍

## ខ្លឹមសារសំខាន់ៗ

| ថ្ងៃទី១ សេចក្ដីផ្ដើម និង ការឆ្លុះបញ្ចាំងការបង្រៀន | រយៈពេល |
|---|---|
| ១.១ ការស្វាគមន៍ និង ការបង្ហាញពីកម្មវិធីសិក្ខាសាលារយៈពេលបីថ្ងៃ | ១៥ នាទី |
| ១.២ ការបង្ហាញពីស្ថានភាពនៃកម្មវិធីអេស្ដាប់ | ២០ នាទី |
| ១.៣ ផែនការគាំទ្រគ្រូសហគមន៍ក្នុងកម្មវិធីអេស្ដាប់សម្រាប់ឆ្នាំសិក្សា ២០០៦-២០០៧ | ១០ នាទី |
| ១.៤ ខ្លឹមសារសំខាន់ៗដែលគ្រូសហគមន៍លើកឡើងសម្រាប់វគ្គបណ្ដុះបណ្ដាលបន្ថែមរយៈពេល៣ថ្ងៃ...(១) ការធ្វើកិច្ចតែងការបង្រៀន (២) ការគ្រប់គ្រងថ្នាក់រៀន (៣) ការផលិតសម្ភារសម្រាប់ការបង្រៀន និង រៀន (៤) សម្ភារសម្រាប់ការបង្រៀន និង រៀន | ១៥ នាទី |
| ប្រធានរឿងទី១: ការធ្វើផែនការ ការបង្រៀន/រៀន ការឆ្លុះបញ្ចាំង (វដ្ដបង្រៀន) | |
| ១.៥ ការធ្វើកិច្ចតែងការបង្រៀន...ធាតុនៃកិច្ចតែងការបង្រៀន និង កិច្ចតែងការគំរូរបស់ក្រសួងអប់រំ យុវជន និង កីឡា | ៦០ នាទី |
| ១.៦ ការវិភាគសកម្មភាពសិក្សាក្រុមតូច | ៩០ នាទី |
| ១.៧ ការរៀបចំសកម្មភាពសិក្សាបែបសហការសម្រាប់ក្រុមតូច | ៦០ នាទី |
| ១.៨ ការវាយតម្លៃសិស្ស | ៦០ នាទី |
| ១.៩ ការវាយតម្លៃការបង្រៀន | ៦០ នាទី |
| សរុប | ៦ម៉ោង ៣០នាទី |
| ថ្ងៃទី២ ប្រធានរឿងទី២: បំនិននៃការសួរសំណួរ និង ការគិតកម្រិតខ្ពស់ | |
| ២.១ បំនិននៃការសួរសំណួរ...មូលហេតុដែលគ្រូបង្រៀនសួរសំណួរ | ១៥ នាទី |
| ២.២ តើអ្វីទៅដែលហៅថា តាក់សូណូមី? | ៣០ នាទី |
| ២.៣ ការធ្វើចំណាត់ថ្នាក់ (តាក់សូណូមី) នៃសំណួរ | ៦០ នាទី |
| ២.៤ ការវិភាគសំណួរ-កិច្ចការសិក្ខាកាម | ៤៥ នាទី |
| ២.៥ រចនាសម្ព័ន្ធនៃភាសា និង កម្រិតនៃការសួរសំណួរ | ៦០ នាទី |
| ២.៦ ការសរសេរសំណួរដែលមានកម្រិតខ្ពស់ជាង-កិច្ចការសិក្ខាកាម | ៦០ នាទី |
| ២.៧ សកម្មភាពសិក្សាដែលជួយឱ្យសិស្សគិតកម្រិតខ្ពស់: ១. ការស្រាវជ្រាវរបស់សិស្ស | ៦០ នាទី |
| ២.៨ សកម្មភាពសិក្សាដែលជួយឱ្យសិស្សគិតគិតកម្រិតខ្ពស់: ២. ល្បែងសិក្សា | ៦០ នាទី |
| សរុប | ៦ម៉ោង ៣០នាទី |

| **ថ្ងៃទី៣ ប្រធានរឿងទី៣: ការអភិវឌ្ឍន៍បំនិនភាសា** | |
|---|---|
| ៣.១ ការបង្កើតបរិស្ថានបន្ទប់រៀនសំបូរបែប | ២០ នាទី |
| ៣.២ ភាសាក្នុងកម្មវិធីសិក្សា...កុមាររៀនភាសា ការរៀនអំពីភាសា ការរៀនតាមរយៈការប្រើភាសាលើគ្រប់មុខវិជ្ជា | ១៥ នាទី |
| ៣.៣ ការប្រើប្រាស់ប៉ូស្ទ័រ និង រូបភាព-ការអភិវឌ្ឍន៍បំនិនស្តាប់ និង និយាយ | ៤៥ នាទី |
| ៣.៤ ការប្រើប្រាស់ផែនទី-ការអភិវឌ្ឍន៍បំនិនស្តាប់ និង និយាយ | ៤៥ នាទី |
| ៣.៥ អំណានឮ ដើម្បីអភិវឌ្ឍន៍បំនិនស្តាប់ និង ចំណេះដឹងលើអត្ថបទ | ៤៥ នាទី |
| ៣.៦ ការជួយកុមារឱ្យស្វែងយល់ពីអ្វីដែលបង្កើតឱ្យបានជាអត្ថបទ "ពេញលេញ" | ៤៥ នាទី |
| ៣.៧ ការលើកទឹកចិត្តឱ្យកុមារសរសេរ-សំណេរដើម និង អត្ថបទចរចា | ៤៥ នាទី |
| ៣.៨ ការលើកទឹកចិត្តឱ្យកុមារសរសេរ-ការធ្វើពង្រាង និង ការប្រជុំពិភាក្សា | ៤៥ នាទី |
| ៣.៩ ការផ្លាស់ប្តូរធាតុនៃអត្ថបទ-ការប្រើប្រាស់អត្ថបទជាក់ស្តែង ( បំនិនជីវិត ភាពមានទំនាក់ទំនងគ្នា) | ៤៥ នាទី |
| **ការបែងចែកកញ្ចប់សម្ភារ** | ២០ នាទី |
| **សរុប** | **៦ម៉ោង ០៥នាទី** |

# អេស្កាប់

# វគ្គបណ្តុះបណ្តាលបន្ថែមរយៈពេល៣ថ្ងៃ សម្រាប់គ្រូសហគមន៍

| |
|---|
| **ថ្ងៃទី១**<br>សេចក្តីផ្តើម<br>ប្រធានរឿងទី១: ការធ្វើផែនការ ការបង្រៀន/រៀន ការឆ្លុះបញ្ចាំង (ការឆ្លុះបញ្ចាំងការបង្រៀន) |
| **ដំណាក់កាលបង្រៀនទី ១.១: ការស្វាគមន៍ និង ការបង្ហាញពីកម្មវិធីសិក្ខាសាលារយៈពេលបីថ្ងៃ ១៥ នាទី**<br>**សម្ភារៈ** ខ្លឹមសារសិក្ខាសាលា-ចំណងជើងដំណាក់កាលបង្រៀន និង ពេលវេលា (ឯកសារទី១)<br><br>អ្នកសម្របសម្រួលស្វាគមន៍សិក្ខាកាម និង បង្ហាញពីកម្មវិធីសិក្ខាសាលារយៈពេលបីថ្ងៃ។ ឯកសារទី១-គោលបំណងសិក្ខាសាលា ចំណងជើងដំណាក់កាលបង្រៀន និង ពេលវេលា។ |
| **ដំណាក់កាលបង្រៀនទី ១.២: ស្ថានភាពបច្ចុប្បន្នរបស់កម្មវិធីអេស្កាប់ ២០ នាទី**<br><br>អ្នកសម្របសម្រួលនិយាយទៅកាន់សិក្ខាកាមអំពីស្ថានភាពបច្ចុប្បន្ននៃកម្មវិធីអេស្កាប់ ដោយលើកឡើងនូវចំនុចមួយចំនួនរួមមាន: កាបន្តគាំទ្ររហូតដល់ខែមេសាឆ្នាំ២០០៧ ក្តីសង្ឃឹមនៃការបន្តកម្មវិធី ការវិលត្រឡប់របស់គរុសិស្សពីសាលាគរុកោសល្យសម្រាប់ឆ្នាំសិក្សា២០០៧-២០០៨ ការបន្តកើតមានបញ្ហាកង្វះគ្រូបង្រៀន កង្វះខាតគ្រូបង្រៀនដែលមិនអាចជៀសផុត (មានជំងឺ ការចូលនិវត្តន៍ ។ល។) ការពង្រីកសាលាបឋមសិក្សាបឋមភូមិ...។ |
| **ដំណាក់កាលបង្រៀនទី ១.៣: ផែនការទៅថ្ងៃអនាគតសម្រាប់គ្រូសហគមន៍ ១០ នាទី**<br><br>អ្នកសម្របសម្រួលនិយាយពីផែនការគាំទ្រគ្រូសហគមន៍សម្រាប់ឆ្នាំសិក្សា ២០០៦-២០០៧ ដោយបញ្ជាក់ថា ការគាំទ្រមានរចនាសម្ព័ន្ធទូលំទូលាយ មានការបណ្តុះបណ្តាលបន្ថែមរយៈពេលបីថ្ងៃ និង ការប្រជុំរៀងរាល់ពីរខែម្តងរួមមាន ខែវិច្ឆិការ មករា មីនា ឧសភា កក្កដា...ការបើកប្រាក់ខែបន្តរហូតដល់ចុងឆ្នាំសិក្សា២០០៦-២០០៧ (ប្រាក់ខែទទួលបានចុងក្រោយក្នុងខែកក្កដា ឆ្នាំ២០០៧)។ |
| **ដំណាក់កាលបង្រៀនទី ១.៤: ចំណុចសំខាន់ៗដែលគ្រូសហគមន៍លើកឡើងសម្រាប់វគ្គបណ្តុះបណ្តាលបន្ថែម៣ថ្ងៃ ១៥ នាទី**<br><br>អ្នកសម្របសម្រួលសង្ខេបលទ្ធផលការប្រជុំចុងក្រោយពីខែមិថុនា និង កក្កដា ឆ្នាំ២០០៦។ អ្នកសម្របសម្រួលសង្ខេបពីអ្វីដែលគ្រូសហគមន៍លើកឡើងសម្រាប់វគ្គបណ្តុះបណ្តាលបីថ្ងៃ ដែលចំណុចសំខាន់ផ្តោតទៅលើ<br>ការធ្វើកិច្ចតែងការបង្រៀន |

| |
|---|
| ការគ្រប់គ្រងថ្នាក់រៀន<br>ការផលិតសម្ភារបង្រៀន និង រៀន<br>សម្ភារសម្រាប់បង្រៀន និង រៀន<br>អ្នកសម្របសម្រួលលើកពីកត្តាផ្សេងៗដែលនាំឱ្យមានការជ្រើសរើសខ្លឹមសារសម្រាប់សិក្ខាសាលានេះ ដោយបញ្ជាក់ថាខ្លឹមសារនៅក្នុងវគ្គនេះមានលក្ខណៈទូទៅច្រើន ពីព្រោះគ្រូសហគមន៍បង្រៀនគ្រប់កម្រិតថ្នាក់ ដូច្នោះយើងមិនអាចចំណាយពេលច្រើនពេកទៅលើសកម្មភាពដែលសមស្របតែនឹងកម្រិតថ្នាក់ជាក់លាក់មួយឬពីរបានទេ។ |
| **ប្រធានរឿងទី១: ការធ្វើផែនការ ការបង្រៀន/រៀន ការឆ្លុះបញ្ចាំង (ការឆ្លុះបញ្ចាំងការបង្រៀន)** |
| **ដំណាក់កាលបង្រៀនទី ១.៥: ធាតុនៅក្នុងកិច្ចតែងការបង្រៀន-ការវិភាគកិច្ចតែងការគំរូរបស់ក្រសួងអប់រំ យុវជន និង កីឡា ៦០ នាទី**<br>**សម្ភារៈ ឯកសារទី២** កិច្ចតែងការគំរូរបស់ក្រសួងអប់រំ យុវជន និង កីឡា ដោយបិទនៅលើក្រដាសវ៉ាមធំ (២) ចម្លើយវិភាគ ស្លាក សេចក្តីពន្យល់ របស់អ្នកសម្របសម្រួលលើកិច្ចតែងការរបស់ក្រសួងអប់រំ យុវជន និង កីឡា។<br><br>អ្នកសម្របសម្រួលសួរបំផុសសិក្ខាកាមអំពីធាតុនៃកិច្ចតែងការដែលល្អ ហើយសរសេរនៅលើតារាងលើក្តារខៀន។ អ្នកសម្រប-សម្រួលពន្យល់ពីគោលនយោបាយរបស់ក្រសួងអប់រំ យុវជន និង កីឡាលើការធ្វើកិច្ចតែងការបង្រៀនដោយបញ្ជាក់ថា គ្រូបង្រៀនអាចប្រើប្លង់កិច្ចតែងការបង្រៀនប្រភេទណាក៏បាន ឱ្យតែគ្រូបង្រៀនបញ្ចូលនូវធាតុសំខាន់ៗ (TGL1)។ អ្នកសម្របសម្រួលនិយាយថាមន្ត្រីអប់រំមួយចំនួននៅក្នុងក្រសួងអប់រំ យុវជន និង កីឡា នៅតែទាមទារឱ្យគ្រូបង្រៀនប្រើប្រាស់កិច្ចតែងការដែលមានលក្ខណៈស្តង់ដា។ អ្នកសម្របសម្រួលផ្តល់**ឯកសារទី២**ទៅសិក្ខាកាមនៃមេរៀនដែលធ្វើតាមគំរូស្តង់ដារបស់ក្រសួងអប់រំ យុវជន និង កីឡា (បិទនៅលើក្រដាសវ៉ាមធំ) និង ឱ្យពួកគាត់វិភាគទៅតាមធាតុទាំងឡាយដែលបានសរសេររួចខាងលើ ដោយប្រើសញ្ញាព្រួញ និង ស្លាក។ អ្នកសម្របសម្រួលឱ្យសិក្ខាកាមធ្វើការជាក្រុមតូចដើម្បីបំពេញការវិភាគនេះ ។ នៅពេលសិក្ខាកាមបញ្ចប់កិច្ចការ អនុញ្ញាតឱ្យក្រុមមួយបង្ហាញ ចំណែកឯក្រុមផ្សេងត្រូវពិនិត្យមើល ហើយផ្តល់យោបល់យល់ស្រប ឬ មិនយល់ស្រប។ អ្នកសម្រប-សម្រួលផ្តល់គំនិតបន្ថែមទៀត ដោយប្រៀបធៀបគំនិតសិក្ខាកាមជាមួយនឹងគំនិតរបស់អ្នកសម្របសម្រួលដែលបានរៀបចំរួចជាស្រេច។<br><br>អ្នកសម្របសម្រួលពន្យល់ថា គ្រូសហគមន៍នឹងមានឱកាសនៅក្នុងកំឡុងឆ្នាំសិក្សានេះ គឺនៅពេលប្រជុំរាល់ពីរខែម្តង ដើម្បីសរសេរកិច្ចតែងការបង្រៀនតាមគំរូរបស់ក្រសួងអប់រំ យុវជន និង កីឡា។<br><br>អ្នកសម្របសម្រួលបន្ថែមថា ការសរសេរកិច្ចតែងការតាមគំរូក្រសួងគឺជាការអនុវត្តដ៏ល្អមួយ ប៉ុន្តែគ្រូបង្រៀនជាច្រើនមិនមានពេលសរសេរឱ្យបានលំអិតដូចនោះទេ។ ផែនការដែលខ្លីជាង មានលក្ខណៈសង្ខេប ឬ គ្រាន់តែជាគម្រោងផែនការ ក៏អាចប្រើបានដែរ ហើយនេះគឺជារបៀបដែលគ្រូបង្រៀនភាគច្រើនបំផុតអនុវត្តកន្លងមក។ |

**ដំណាក់កាលបង្រៀនទី ១.៦: ការវិភាគសកម្មភាពសិក្សា (ជាពិសេសសកម្មភាពក្រុម)** **៩០ នាទី**

**សម្ភារៈ ឯកសារទី៣** ករណីសិក្សាអំពីសកម្មភាពសិក្សាក្នុងមេរៀនបី ដែលមានកម្រិតគុណភាពខុសៗគ្នា។ **ឯកសារទី៤** គំរូតារាងសម្រាប់ឱ្យសិក្ខាកាមកត់ត្រាការវិភាគលើករណីសិក្សា។ **ឯកសារទី៥** (រូបថត) សកម្មភាពសិក្សាក្រុមតូចពីរ។ រូបថតទីមួយបង្ហាញពីសកម្មភាពកុមារដែលកំពុងធ្វើកាជាលក្ខណៈបុគ្គលក្នុងក្រុម និង រូបថតទី២ បង្ហាញពីសកម្មភាពដែលកុមារកំពុងធ្វើការរួមគ្នាជាក់ស្តែងក្នុងក្រុម។

អ្នកសម្របសម្រួលសួរសិក្ខាកាមៈ ទោះបីជាផ្នែកទាំងអស់នៃកិច្ចតែងការបង្រៀនសុទ្ធតែសំខាន់ តើអ្នកគិតថាផ្នែកណាមួយដែលសំខាន់ជាងគេបំផុត បើផ្តោតទៅលើការសិក្សារបស់សិស្ស? អ្នកសម្របសម្រួលស្តាប់ចម្លើយរបស់សិក្ខាកាម...។ អ្នកសម្របសម្រួល រំលឹកសិក្ខាកាមអំពីគំនិតសន្មតមួយអំពីការសិក្សា ដោយបញ្ជាក់ថា បើសិនជាខ្ញុំស្តាប់ខ្ញុំចងចាំបាន២០% បើសិនជាខ្ញុំមើលឃើញខ្ញុំចាំបាន៤០% ហើយបើសិនខ្ញុំធ្វើ/អនុវត្ត ខ្ញុំចាំបាន៨០%។ សិក្ខាកាមជាច្រើន នឹងយល់ស្របថា <u>**សកម្មភាពសិក្សាផ្ទាល់របស់សិស្ស**</u> គឺជាផ្នែកមួយដ៏សំខាន់សម្រាប់ការសិក្សាដែលមានប្រសិទ្ធភាព។

អ្នកសម្របសម្រួលនិយាយថា គាត់នឹងផ្តល់ករណីសិក្សាចំនួនបី ដែលពិពណ៌នាពីសកម្មភាពសិក្សាផ្សេងៗគ្នា។ កិច្ចការរបស់សិក្ខាកាមគឺត្រូវអាន និង ពិភាក្សាករណីសិក្សាទាំងបីនោះ រួចហើយបំពេញក្នុងតារាងដែលបានផ្តល់ជូន។ អ្នកសម្របសម្រួលនិយាយថា កិច្ចការរបស់សិក្ខាកាមគឺត្រូវធ្វើការជាក្រុមតូចដើម្បីវិភាគករណីសិក្សាដោយផ្តោតលើៈ

(១) តើកិច្ចការនេះតម្រូវឱ្យសិស្សគ្រាន់តែចងចាំអ្វីមួយ ឬ តម្រូវឱ្យសិស្សរិះគិតឱ្យបានជ្រៅ?

(២) តើកិច្ចការនេះតម្រូវឱ្យសិស្សធ្វើសកម្មភាពជាក្រុម (ការពិភាក្សា ការយល់ស្របគ្នា) ដើម្បីបំពេញដែរឬទេ?

(៣) តើក្រុមសិស្សត្រូវតែបង្កើតអ្វីមួយដើម្បីបំពេញកិច្ចការនេះឬទេ?

(៤) តើសិស្សមានឱកាសពិភាក្សាកិច្ចការជាមួយសិស្ស ផ្សេងទៀតឬទេ?

(៥) តើសិស្សមានឱកាសពន្យល់ការគិតរបស់ពួកគេ ទៅកាន់គ្រូ និង សិស្សទាំងអស់ឬទេ?

(៦) តើមានចម្លើយត្រឹមត្រូវមួយសម្រាប់សកម្មភាពសិក្សានេះឬទេ? តើជានិច្ចកាលត្រូវតែមានចម្លើយតែមួយបែបនេះឬ?

(៧) ចូររៀបលំដាប់លំដោយសកម្មភាពសិក្សាទៅតាមកម្រិតប្រសិទ្ធភាព (១ ២ និង ៣ )។ ចូរសរសេរហេតុផលចំពោះមូលហេតុរបស់អ្នក។

សិក្ខាកាមអាន និង ពិភាក្សាករណីសិក្សា បន្ទាប់មកបំពេញតារាងនៅលើក្រដាសផ៉ាមធំ។ តំណាងក្រុមទាំងឡាយ លើកបិទប៉ូស្ទ័រ ហើយធ្វើការប្រៀបធៀប។ ចូរពិភាក្សារាល់គំនិតយោបល់ដែលខុសគ្នា។ អ្នកសម្របសម្រួលសង្ខេបគំនិតយោបល់ទាំងនោះ។ នៅក្នុងសំណួរទី៧ (ការរៀបលំដាប់ទៅតាមកម្រិតប្រសិទ្ធភាព) អ្នកសម្របសម្រួលបញ្ជាក់ថា គ្រូបង្រៀនលើកទឹកចិត្តសិស្សឱ្យធ្វើការជាក្រុមដើម្បី **រិះគិត** គឺមិនមែនគ្រាន់តែចងចាំប៉ុណ្ណោះទេ។ អ្នកសម្របសម្រួលសួរសិក្ខាកាមថាៈ តើសិស្សប្រើការគិតប្រភេទអ្វីនៅក្នុងករណីសិក្សាទី១ ទី២ ទី៣...? អ្នកសម្របសម្រួលសរសេរចម្លើយសិក្ខាកាម ហើយនិយាយថា ចំនុចទាំងនេះនឹងជួបម្តង

ទៀតនៅថ្ងៃស្អែកនៅក្នុងដំណាក់កាលបង្រៀនអំពីសំណួរគាក់សួណ្ឌមី និង ការគិតកម្រិតខ្ពស់។

ចម្លើយរំពឹងទុកសម្រាប់ករណីសិក្សាទាំងបី

| ចំនុចប្រៀបធៀប | ករណីសិក្សាទី១ | ករណីសិក្សាទី២ | ករណីសិក្សាទី៣ |
|---|---|---|---|
| តើកិច្ចការនេះតម្រូវឱ្យ សិស្សគ្រាន់តែចងចាំប៉ុណ្ណោះ ឬ តម្រូវឱ្យសិស្សធ្វើការគិតឱ្យបានច្រើន? | *ចងចាំប៉ុណ្ណោះ-ការធ្វើផលបូកប្រភាគ និង ការរកចម្លើយ ត្រូវ ឬ ខុស* | *ចងចាំ និង រិះគិត-ការគូរដ្យាក្រាមថ្មី ដើម្បីជួយពន្យល់លំហាត់ផលបូក* | *ចងចាំ និង រិះគិត-ការគូរដ្យាក្រាមដើម្បីជួយពន្យល់លំហាត់ផលបូក* |
| តើកិច្ចការតម្រូវឱ្យមានសកម្មភាពក្រុម(ការពិភាក្សា ការយល់ស្របគ្នា) ឬទេ? | *ទេ កិច្ចការទាំងអស់ធ្វើជាលក្ខណៈបុគ្គល* | *បាទ/ចាស៎ សិស្សត្រូវយល់ស្របគ្នាលើការគូរដ្យាក្រាម បន្ទាប់មកឆ្លើយលំហាត់ផលបូក។ ក្រុមសិស្សក៏បានកែកិច្ចការ* | *បាទ/ចាស៎ សិស្សត្រូវយល់ស្របគ្នា លើការគូរដ្យា-ក្រាម បន្ទាប់មកឆ្លើយលំហាត់ផលបូក។ ក្រុមសិស្សក៏បានកែកិច្ចការ* |
| តើក្រុមសិស្សត្រូវតែបង្កើតអ្វីមួយដើម្បីបំពេញកិច្ចការនោះឬទេ? | *ទេ មានតែសិស្សធ្វើការជាលក្ខណៈបុគ្គលដើម្បីផ្តល់នូវ(ផលិតផល) ចម្លើយ* | *បាទ/ចាស៎ ក្រុមនីមួយៗមានផលិតផល* | *បាទ/ចាស៎ ក្រុមនីមួយៗមានផលិតផល* |
| តើសិស្សមានឱកាសពិភាក្សាកិច្ចការជាមួយសិស្សផ្សេងទៀតឬទេ? | *ទេ* | *បាទ/ចាស៎* | *បាទ/ចាស៎* |
| តើសិស្សមានឱកាស ពន្យល់ការគិតរបស់ពួកគេទៅកាន់គ្រូ និង សិស្សទាំងអស់ឬទេ? | *ទេ* | *ទេ ពួកគេគ្រាន់តែបានពិភាក្សានៅក្នុងក្រុម* | *បាទ/ចាស៎ ពួកគេមានឱកាសពន្យល់នៅពេលពួកគេឡើងគូរបង្ហាញនៅលើក្តារខៀន អំពីរបៀបដែលពួកគេឆ្លើយលំហាត់* |
| តើមានចម្លើយ ត្រឹមត្រូវមួយសម្រាប់សកម្មភាពសិក្សានេះឬទេ? តើជានិច្ចកាលត្រូវមានចម្លើយតែមួយបែបនេះឬ? | *បាទ/ចាស៎ មានចម្លើយត្រឹមត្រូវមួយ។ ប៉ុន្តែនេះមិនមែនជាករណីទូទៅទេ។ សកម្មភាពសិក្សាបែបសហការ ដែលសិស្សផ្តល់យោបល់ ឬ ចម្លើយពីបទពិសោធន៍របស់ពួកគេជាញឹកញាប់គឺ មានចម្លើយច្រើនផ្សេងៗគ្នា។* | | |
| ចូររៀបលំដាប់លំដោយសកម្មភាពសិក្សាទៅតាមកម្រិតប្រសិទ្ធភាព(១ ២ និង ៣ )។ ចូរសរសេរហេតុផលចំពោះ មូលហេតុរបស់អ្នក។ | *១* | *២* | *៣* |

អ្នកសម្របសម្រួលនិយាយថាៈ ការងារជាបុគ្គលមានប្រយោជន៍ណាស់សម្រាប់សិស្សដើម្បីអភិវឌ្ឍ និង អនុវត្តបំនិន ព្រមទាំងការវាយតម្លៃកាយល់ដឹងរបស់ពួកគេ។ ការងារក្រុមក៏មានលក្ខណៈល្អប្រសើរពីព្រោះវាបានជួយឱ្យកុមារអភិវឌ្ឍន៍បំនិននៃការធ្វើការរួមគ្នា ការពន្យល់គំនិតរបស់ពួកគេទៅវិញទៅមក និង ការធ្វើការជាក្រុម។ ភាពជាគ្រូបង្រៀន នៅពេលណាដែលអ្នកបញ្ចូលសកម្មភាពពិភាក្សាក្រុមតូចបានល្អ គឺអ្នកកំពុងបង្រៀនដោយស្វ័យប្រវត្តិនូវចំនុច "តរិយាបថ" ក្នុង KSA។

ប៉ុន្តែចូរក្រលេកមើលដ្យាក្រាមនេះ... (អ្នកសម្របសម្រួលផ្តល់ឯកសារដែលមានរូបភាពពីរដែលរូបភាពមួយបង្ហាញពីកុមារកំពុងធ្វើការជាលក្ខណៈបុគ្គលនៅក្នុងក្រុម និង រូបភាពមួយផ្សេងទៀតបង្ហាញពីសិស្សដែលកំពុងធ្វើការជាក្រុមរួមគ្នាពិតប្រាកដ)។ អ្នកសម្របសម្រួលសួរ...*តើអ្វីកំពុងកើតឡើងនៅក្នុងរូបភាពនេះ?* ចម្លើយរំពឹងទុកៈ *សិស្សនៅក្នុងរូបភាពទី១កំពុងស្ថិតនៅជាក្រុម ប៉ុន្តែកំពុងធ្វើកិច្ចការផ្ទាល់ខ្លួនរបស់ពួកគេ ចំណែកនៅក្នុងរូបភាពទីពីរសិស្សកំពុងធ្វើការជាក្រុម។*

**ដំណាក់កាលបង្រៀនទី ១.៧ៈ ការរៀបចំសកម្មភាពសិក្សាបែបសហការ (កិច្ចការ) សម្រាប់ក្រុមតូច ៦០ នាទី**

**សម្ភារៈ** សៀវភៅសិក្សារបស់ក្រសួងអប់រំ យុវជន និង កីឡា ពីថ្នាក់ទី១-៦ គ្រប់មុខវិជ្ជា ក្រដាសផ្ទាំងធំ និង ហ្វឺត

បន្ទាប់មកអ្នកសម្របសម្រួលប្រាប់សិក្ខាកាមបង្កើតជាក្រុមទៅតាមកម្រិតថ្នាក់។ ថ្នាក់ទី៤ ៥ និង ទី៦ អាចបង្កើតជាមួយក្រុមបើសិន ជាមានគ្រូសហគមន៍ចំនួនតិច។ ក្រុមតូចនីមួយៗធ្វើការលើសៀវភៅសិក្សាទាំងបួនទៅតាមកម្រិតថ្នាក់របស់ពួកគាត់។ សិក្ខាកាម ជ្រើសរើសមេរៀនមួយពីសៀវភៅសិក្សានីមួយៗ និង បង្កើតកិច្ចការមួយសម្រាប់ក្រុមសិក្សាតូចដែលទាក់ទងនឹងមេរៀននោះ។ សិក្ខាកាមបង្ហាញការងាររបស់ពួកគាត់ដោយបង្ហាញទាំងឯកសារយោង (ជំពូក មេរៀន ចំណងជើង ទំព័រ...) របស់មេរៀនដែលបានជ្រើសរើស។

អ្នកសម្របសម្រួលនិយាយថាក្រុមទាំងឡាយគួរព្យាយាមសរសេរសកម្មភាពសិក្សា/កិច្ចការដែលៈ

- ជំរុញឱ្យសិស្សពិភាក្សាគ្នាទៅវិញទៅមក
- បង្កើតលទ្ធផលដែលសមាជិកក្រុមអាចបកស្រាយបង្ហាញ/ពន្យល់
- មានលទ្ធផលច្រើនយ៉ាង
- កុមារត្រូវប្រើបទពិសោធន៍/គំនិតផ្ទាល់ខ្លួនរបស់ពួកគេ

ក្រុមទាំងឡាយគួរសរសេរសង្ខេបកិច្ចការទាំង៤នៅលើក្រដាសផ្ទាំងធំ។

នៅពេលពួកគាត់បានបំពេញកិច្ចការចប់ ក្រុមតាមកម្រិតថ្នាក់ឡើងបង្ហាញលទ្ធផល។ ក្រុមផ្សេងទៀតអាចសួរសំណួរ ឬ ផ្តល់យោបល់។ បន្ទាប់មកអ្នកសម្របសម្រួលសង្ខេបគំនិតទាំងឡាយ។

បើសិនជាមានពេលវេលាអ្នកសម្របសម្រួលអាចជ្រើសរើសសកម្មភាពសិក្សាមួយចំនួនទៀត ហើយសួរសិក្ខាកាមឱ្យនិយាយថា តើសិស្សត្រូវប្រើការគិតប្រភេទអ្វីដើម្បីបំពេញកិច្ចការនោះ។ ចំនុចនេះអាចជាការរៀបចំល្អមួយសម្រាប់សកម្មភាពនៅថ្ងៃទី២។

**ដំណាក់កាលបង្រៀនទី ១.៨: ការវាយតម្លៃការសិក្សាសិស្ស** **៦០ នាទី**

**សម្ភារៈ ឯកសារទី៦** អំពីការវាយតម្លៃ

អ្នកសម្របសម្រួលចាប់ផ្តើមប្រធានបទអំពីការវាយតម្លៃការសិក្សាសិស្សដោយសួរសិក្ខាកាមឱ្យប្រាប់ចំនួនសិស្សដែលមិនបានឡើងថ្នាក់/ត្រួតថ្នាក់ (ឬ អត្រាឡើងថ្នាក់/ត្រួតថ្នាក់) ពីថ្នាក់របស់ពួកគាត់ក្នុងឆ្នាំសិក្សា២០០៥-២០០៦។ អ្នកសម្របសម្រួលសួរៈ *តើអ្នកមានហេតុផលអ្វីខ្លះសម្រាប់ធ្វើការសម្រេចចិត្តថាឱ្យសិស្សចំនួន X%ត្រួតថ្នាក់?* អ្នកសម្របសម្រួលសរសេរហេតុផលរបស់សិក្ខាកាមជាបញ្ជីនៅលើក្តារខៀន។ (ចម្លើយរំពឹងទុកៈ ប្រលងធ្លាក់ អវត្តមានច្រើន មិនអាចធ្វើនេះ ឬ នោះ (រាប់ អាន សរសេរ...) មិនចូលរួមពិភាក្សា មានអាកប្បកិរិយាមិនល្អ មិនយកចិត្តទុកដាក់លើការងារ ។ល។)

អ្នកសម្របសម្រួលគួរតែបង្ហាញសិក្ខាកាមឱ្យគិតពីហេតុផលមួយចំនួនផ្សេងទៀតផងដែរ ដែលទាក់ទងនឹងផ្នែក "ឥរិយាបថ" (បញ្ហាអាកប្បកិរិយា កម្រិតចាប់អារម្មណ៍ ការយកចិត្តទុកដាក់ ការចង់ដឹងចង់ឃើញ ។ល។ ព្រមទាំងផ្នែកផ្សេងៗទៀត "ចំណេះដឹង" និង "បំនិន"។

បន្ទាប់មកអ្នកសម្របសម្រួលសួរសំណួរបន្ថែមៈ *តើអ្នកបានធ្វើអ្វីខ្លះដើម្បីរកឱ្យឃើញចំនុចទាំងនេះពីសិស្ស?* បន្ទាប់មកសរសេរគំនិតរបស់ពួកគាត់នៅលើក្តារខៀន។ នៅពេលសិក្ខាកាមផ្តល់គំនិតទាំងអស់របស់ពួកគាត់ អ្នកសម្របសម្រួលសរសេរចំណងជើងលើបញ្ជីគំនិតនោះ "យុទ្ធសាស្ត្រវាយតម្លៃ"។ អ្នកសម្របសម្រួលគួរត្រួតពិនិត្យមើលថាតើសិក្ខាកាមទទួលបានគំនិតផ្សេងទៀតនៅក្នុងចម្លើយរំពឹងទុកខាងក្រោមឬទេ។

*ចម្លើយរំពឹងទុកៈ រៀបចំ និង ដាក់ពិន្ទុលើតេស្ត សួរសំណួរ សង្កេតអាកប្បកិរិយា ស្តាប់ពួកគេនៅពេលនិយាយ/ពន្យល់ ពិនិត្យមើលកិច្ចការសំណេរ ពិនិត្យមើលការសហការជាមួយអ្នកដទៃ...។*

បន្ទាប់មកអ្នកសម្របសម្រួលនិយាយថា ក្រសួងអប់រំ យុវជន និង កីឡាកំពុងរៀបចំកែសម្រួលឱ្យបានជាទម្រង់ថ្មីមួយសម្រាប់វាយតម្លៃការសិក្សាសិស្ស។

ការវាយតម្លៃសិស្ស-*តើពួកគេរៀនឬទេ? តើអ្នកដឹងដោយរបៀបណា?...ការសង្កេត ការបង្ហាញ ការប្រើប្រាស់ភាសាដើម្បីពន្យល់ ការធ្វើតេស្ត...ការវាយតម្លៃជាដំណាក់/ការវាយតម្លៃបែបសរុប និង អត្ថប្រយោជន៍នៃការវាយតម្លៃនីមួយៗ។* គ្រូបង្រៀនត្រូវ

ចងចាំថាការប្រើប្រាស់យុទ្ធសាស្ត្រចម្រុះគឺជាវិធីល្អប្រសើរណាស់ ។

អ្នកសម្របសម្រួលផ្តល់**ឯកសារទី៦**ឱ្យសិក្ខាកាមអំពីការវាយតម្លៃដើម្បីអានជាមួយដៃគូ ។ បន្ទាប់មកឱ្យសិក្ខាកាមសួរសំណួរ ។ បើសិនជាគ្មានសំណួរ អ្នកសម្របសម្រួលសួរសំណួរមួយចំនួន ហើយសំណួរដែលអាចសួរ មានបង្ហាញជូនខាងក្រោម ។

| **សំណួរ** | **ចម្លើយរំពឹងទុក** |
|---|---|
| តើមានភាពខុសគ្នាដូចម្តេចរវាង ការវាយតម្លៃជាដំណាក់ និង ការវាយតម្លៃសរុប? | ការវាយតម្លៃជាដំណាក់គឺធ្វើនៅក្នុងកំឡុងវគ្គសិក្សា ចំណែកការវាយតម្លៃសរុបគឺធ្វើនៅចុងវគ្គសិក្សា |
| តើគ្រូបង្រៀន ធ្វើការវាយតម្លៃក្រៅផ្លូវការនៅពេលណា និង ប្រើប្រាស់វិធីសំខាន់ៗអ្វីខ្លះ? | គ្រូបង្រៀនធ្វើការវាយតម្លៃក្រៅផ្លូវការជារៀងរាល់ថ្ងៃ ដោយការស្តាប់អ្វីៗដែលកុមារនិយាយ ការសង្កេតពួកគេនៅពេលធ្វើការងារ ការពិនិត្យមើលសៀវភៅរបស់ពួកគេ ។ល ។ |
| តើមានភាពខុសគ្នាដូចម្តេចរវាងការវាយតម្លៃក្រៅផ្លូវការ និង ផ្លូវការ? | ការវាយតម្លៃក្រៅផ្លូវការគឺធ្វើជារៀងរាល់ថ្ងៃ ការសង្កេតជាទម្លាប់ ចំណែកការវាយតម្លៃផ្លូវការគឺធ្វើទៅតាមពេលវេលាពិសេសមួយ ដែលមានធ្វើផែនការដោយយកចិត្តទុកដាក់ ហើយជាញឹកញាប់មានទម្រង់ជាការសរសេរ (ដូចជា តេស្ត) |
| ។ល ។ | ។ល ។ |

**ដំណាក់កាលបង្រៀនទី ១.៩: ការវាយតម្លៃការបង្រៀន-គ្រូបង្រៀនដែលមានការឆ្លុះបញ្ចាំង** **៦០ នាទី**

**សម្ភារៈ** រូបភាព/ដ្យាក្រាមនៃវដ្តជីវិតសត្វមេអំបៅ **ឯកសារទី៧** អំពីការឆ្លុះបញ្ចាំងការបង្រៀន

អ្នកសម្របសម្រួលប្រើប្រាស់លំនាំ នៃវដ្តជីវិតរបស់សត្វមេអំបៅ (ពង... ដង្កូវមេអំបៅ... ដឹកដឿ... មេអំបៅ... ពង...។ល ។) ដើម្បីបង្ហាញគំនិតអំពីវដ្ត។ បន្ទាប់មកអ្នកសម្របសម្រួលព្យាយាមសួរបំផុសគំនិតសិក្ខាកាមអំពីធាតុសំខាន់ៗក្នុង វដ្តបង្រៀន និង រៀន ។ អ្នកសម្របសម្រួលសួរ: *នៅពេលអ្នកកំពុងព្យាយាមបង្រៀនសិស្សអំពីគំនិតសំខាន់ថ្មី ឬ បំនិនថ្មី អ្នកព្យាយាមបំបែកវាទៅជាជំហានៗជាច្រើនតាមលំដាប់លំដោយជាក់លាក់ និង ទៅតាមរយៈពេលនៃពេលវេលា ។ ក្នុងខណៈដែលអ្នកផ្លាស់ប្តូរពីជំហានមួយទៅកាន់ជំហានមួយផ្សេងទៀតនៅក្នុងលំដាប់លំដោយនៃមេរៀនទាំងនេះ តើអ្នកកំពុងធ្វើតាមវដ្តនៃសកម្មភាពអ្វីខ្លះ?* ចម្លើយរំពឹងទុក: *ការធ្វើផែនការ ការបង្រៀន ការវាយតម្លៃ/ការឆ្លុះបញ្ចាំង ការធ្វើផែនការជាថ្មី ការបង្រៀន ។ល ។*

*អ្នកបាននិយាយរួចហើយយ៉ាងច្រើនអំពីការធ្វើផែនការ និង ធាតុក្នុងការបង្រៀន... តើអ្នកគិតថាមានអ្វីកើតឡើងនៅក្នុងជំហាននៃការវាយតម្លៃ/ឆ្លុះបញ្ចាំង?* អ្នកសម្របសម្រួលព្យាយាមដឹកនាំសិក្ខាកាមឆ្ពោះទៅរកការពន្យល់ដែលផ្តោតលើការឆ្លុះបញ្ចាំង

ដែលយើងកំពុងតែគិតគឺ ទី១ *តើអ្វីខ្លះដែលសិស្សសម្រេចបាន* និង បន្ទាប់មកទី២ *តើគ្រូបង្រៀនបានធ្វើអ្វីខ្លះ?* ដូនេះផ្នែកសំខាន់នៃការឆ្លុះបញ្ចាំងគឺជាផ្នែកផ្សេងៗនៃកាបង្រៀនរបស់ពួកគាត់ និង អ្វីៗដែលជាការផ្លាស់ប្តូរ ដើម្បីជួយជំរុញឱ្យការសិក្សារបស់សិស្សទទួលបានជោគជ័យ ។ ហេតុដូចនេះ ភាគច្រើនបំផុតនៃការវាយតម្លៃគឺជាស្វ័យវាយតម្លៃដែលធ្វើឡើងដោយគ្រូបង្រៀនផ្ទាល់ ។

ការវាយតម្លៃការបង្រៀន/គ្រូបង្រៀនគឺ ដោយ(ខ្លួនឯង) ដោយចោទសួរខ្លួនឯងថា-*តើខ្ញុំ**បានធ្វើផែនការ**អ្វីខ្លះ? តើខ្ញុំ**បានធ្វើ**អ្វីខ្លះ? តើខ្ញុំត្រូវ**ផ្លាស់ប្តូរ**វិធីអ្វីខ្លះដើម្បីពង្រីកលទ្ធផលការសិក្សារបស់សិស្ស?*

អ្នកសម្របសម្រួលផ្តល់**ឯកសារទី៧** អំពីការឆ្លុះបញ្ចាំងការបង្រៀន ឱ្យសិក្ខាកាមអាន និង ពិភាក្សាជាមួយដៃគូ។ អ្នកសម្របសម្រួលឱ្យសិក្ខាកាមសួរសំណួរនៅពេលអានចប់ ។ បើសិនជាគ្មានសំណួរ អ្នកសម្របសម្រួលសួរសំណួរមួយចំនួន ។ សំណួរដែលអាចសួរមានដូចខាងក្រោមៈ

| **សំណួរ** | **ចម្លើយរំពឹងទុក** |
|---|---|
| បន្ទាប់ពីការឆ្លុះបញ្ចាំង តើលោកគ្រូ/អ្នកគ្រូមានផែនការផ្លាស់ប្តូរអ្វីខ្លះ (សំណួរទូទៅ)? | តាមការអនុវត្តការបង្រៀនផ្ទាល់របស់ពួកគាត់ |
| បន្ទាប់ពីការបង្រៀន តើចំនុចដំបូងដែលគ្រូត្រូវគិតដើម្បីធ្វើការឆ្លុះបញ្ចាំងគឺអ្វី?<br>បន្ទាប់មកអ្វីទៀត? | លទ្ធផលការសិក្សារបស់សិស្ស-តើមានបញ្ហាអ្វីឬទេ?<br>តើសិស្សទាំងអស់រៀនបានល្អឬទេ?<br>តាមការបង្រៀនផ្ទាល់របស់ពួកគាត់ និង ការផ្លាស់ប្តូរដែលពួកគាត់អាចធ្វើបាន។ |
| នៅពេលគ្រូបង្រៀនសម្រេចចិត្តផ្លាស់ប្តូរការអនុវត្តរបស់ពួកគាត់ តើលទ្ធផលអ្វីខ្លះដែលពួកគាត់ចង់បាន (សំណួរទូទៅ)? | ការរីកចម្រើនលូតលាស់ ដែលសង្កេតឃើញលើលទ្ធផលការសិក្សារបស់សិស្ស ( ឧ. តាមរយៈ ទឹកចិត្តចង់ធ្វើអ្វីមួយកើនឡើង កម្រិតចំណូលចិត្ត ការផ្តោតអារម្មណ៍ ការសប្បាយរីករាយ ការពន្យល់បានប្រសើរជាងមុន សកម្មភាពសិក្សា មានការប្រឹងប្រែងច្រើន ។ល។) |
| ។ល។ | ។ល។ |

**សរុប ៦ម៉ោង ៣០ នាទី**

# ថ្ងៃទី២

## ប្រធានរឿងទី២-បំនិនសួរសំណួរ និង ការគិតកម្រិតខ្ពស់

**ដំណាក់កាលបង្រៀនទី ២.១: បំនិនសួរសំណួរ...មូលហេតុដែលគ្រូបង្រៀនប្រើសំណួរ** **១៥ នាទី**

**សម្ភារៈ** ចំណិតក្រដាសសម្រាប់សរសេរឧទាហរណ៍នៃសំណួរ

អ្នកសម្របសម្រួលសួរសំណួរបំផុសដល់សិក្ខាកាម ដើម្បីឱ្យពួកគាត់សង្ខេបគំនិតសំខាន់ៗអំពីការសួរសំណួរដែលបានរៀនរួចហើយនៅក្នុងវគ្គបណ្តុះបណ្តាលរយៈពេល១០ថ្ងៃក្នុងឆ្នាំ២០០៥។ ចំនុចទាំងនេះរួមមាន

- *ហេតុអ្វីបានជាគ្រូបង្រៀនប្រើសំណួរ?* ចម្លើយរំពឹងទុកៈ *ដើម្បីត្រួតពិនិត្យការយល់ដឹង ដើម្បីជំរុញការគិត ដើម្បីឱ្យសិស្សពិភាក្សា/និយាយ ដើម្បីប្រមូលគំនិត និង បទពិសោធន៍ពីកុមារ ។ល។*
- *តើសំណួរទាំងអស់ដូចគ្នាឬទេ?* ចម្លើយរំពឹងទុកៈ *ទេ។* អ្នកសម្របសម្រួលបន្តសួរៈ *តើអ្នកអាចប្រាប់ខ្ញុំពីឈ្មោះសំណួរពីរប្រភេទដែលយើងធ្លាប់ដឹងជាទូទៅបានឬទេ?* ចម្លើយរំពឹងទុកៈ *សំណួរចងចាំ និង សំណួរវិះគិត។*
- *តើមានភាពខុសគ្នាដូចម្តេចរវាងសំណួរចងចាំ និង សំណួរវិះគិត?* ចម្លើយរំពឹងទុកៈ *សំណួរចងចាំ អាចឆ្លើយបានដោយការចងចាំពីអ្វីដែលគ្រូបាននិយាយប្រាប់ ចំណែកសំណួរវិះគិតគឺធ្វើឱ្យសិស្សគិតដោយខ្លួនរបស់ឯង មុននឹងផ្តល់ចម្លើយ។*

អ្នកសម្របសម្រួលផ្តល់ចំណិតក្រដាសពីរ ហើយឱ្យសិក្ខាកាមធ្វើការជាដៃគូ ដើម្បីសរសេរឧទាហរណ៍សំណួរចងចាំ និង ចំណិតក្រដាសមួយផ្សេងទៀតសម្រាប់សរសេរឧទាហរណ៍សំណួរវិះគិត។ អ្នកសម្របសម្រួលហៅសិក្ខាកាមមួយចំនួនឱ្យស្ម័គ្រចិត្តឡើងបង្ហាញឧទាហរណ៍សំណួររបស់ពួកគាត់ទៅកាន់សិក្ខាកាមទាំងឡាយ។ សិក្ខាកាមផ្សេងទៀតពិនិត្យមើលនឹងផ្តល់យោបល់យល់ស្របបើសិនជាមិនយល់ស្របជាមួយចម្លើយ ត្រូវផ្តល់មូលហេតុ។

**ដំណាក់កាលបង្រៀនទី ២.២: តើអ្វីទៅដែលហៅថាតាក់សូណូមី?** **៣០ នាទី**

**សម្ភារៈ ឯកសារទី៨:** ដ្យាក្រាមតាក់សូណូមីអំពីប្រទេស និង សត្វ

អ្នកសម្របសម្រួលនិយាយថា ឥឡូវនេះសិក្ខាកាមត្រូវគិតឱ្យបានជ្រៅអំពីការសួរសំណួរ។ បន្ទាប់មកអ្នកសម្របសម្រួលនិយាយថាជាតំបូងខ្ញុំចង់បង្ហាញថាអ្វីទៅជា "តាក់សូណូមី"។ អ្នកសម្របសម្រួលនិយាយថាៈ *តាក់សូណូមីគឺជាប្រព័ន្ធនៃការធ្វើចំណាត់ថ្នាក់ការរៀបចំអ្វីមួយទៅតាមប្រភេទ*។ វប្បធម៌ និង ភាសាផ្សេងៗគ្នាធ្វើចំណាត់ថ្នាក់ពតិមាន ទៅតាមរបៀបផ្សេងៗគ្នា។ មនុស្សធ្វើតាក់សូណូមីទៅលើប្រភេទពតិមានផ្សេងៗគ្នា។ ហើយអ្វីដែលគេបានដឹងច្បាស់បំផុតគឺតាក់សូណូមីវិទ្យាសាស្ត្រលោកខាងលិចទៅលើប្រភេទសត្វ និង រុក្ខជាតិ។ តាក់សូណូមីជាទូទៅមានក្បួនស្មុគស្មាញក្នុងការធ្វើចំណាត់ថ្នាក់អ្វីមួយទៅតាមក្រុមនេះ ឬក្រុមនោះ។

អ្នកសម្របសម្រួលនិយាយថាៈ ដើម្បីយល់ថាអ្វីទៅជាតាក់សូណូមី ជាការល្អប្រសើរយើងត្រូវអនុវត្តដោយប្រើឧទាហរណ៍ជាក់ស្តែង។ នៅខាងក្រោមនេះបង្ហាញពីក្រុមចំណាត់ថ្នាក់ពីរប្រភេទ។ ក្រុមទី១ ជាក្រុមប្រទេសនៅក្នុងពិភពលោក និង ក្រុមទី២

ជាប្រភេទសត្វ។ កិច្ចការរបស់សិក្ខាកាមគឺត្រូវសម្រេចចិត្តលើការបែងចែកវត្ថុក្នុងក្រុមទៅតាមប្រភេទរបស់វា ដាក់ឈ្មោះប្រភេទនីមួយៗ និង ត្រូវបង្ហាញក្បួនដែលជាមូលហេតុបញ្ជាក់ថាវត្ថុនេះគួរស្ថិតនៅតាមក្រុមផ្សេងៗគ្នា។

<table>
<tr><td colspan="4" align="center">ក្រុមទី១</td></tr>
<tr><td colspan="4" align="center">ប្រភេទៈ ប្រទេសក្នុងពិភពលោក<br>កម្ពុជា បារាំង វៀតណាម ចិន អាឡឺម៉ង់ អ៊ីតាលី ម៉ាឡេស៊ី ជប៉ុន ហ្វីលីពីន ស្រីលង្កា ឥណ្ឌា អេស្ប៉ាញ ឡាវ អៀរឡង់</td></tr>
<tr><td colspan="2" align="center">ប្រភេទៈ អាស៊ី<br>កម្ពុជា វៀតណាម ចិន ម៉ាឡេស៊ី ជប៉ុន ហ្វីលីពីន ស្រីលង្កា ឥណ្ឌា ឡាវ</td><td colspan="2" align="center">ប្រភេទៈ អឺរ៉ុប<br>បារាំង អាឡឺម៉ង់ អ៊ីតាលី អេស្ប៉ាញ ចក្រភពអង់គ្លេស ស៊ុយអែត អៀរឡង់</td></tr>
<tr><td align="center">ប្រភេទៈ អាស៊ាន<br>កម្ពុជា វៀតណាម ឡាវ ម៉ាឡេស៊ី ហ្វីលីពីន</td><td align="center">ប្រភេទៈ មិនមែនអាស៊ាន<br>ចិន ជប៉ុន ស្រីលង្កា ឥណ្ឌា</td><td align="center">ប្រភេទៈ អឺរ៉ុបទ្វីប<br>បារាំង អាឡឺម៉ង់ អ៊ីតាលី អេស្ប៉ាញ</td><td align="center">ប្រភេទៈ តំបន់កោះនៅអឺរ៉ុប<br>ចក្រភពអង់គ្លេស ស៊ុយអែត អៀរឡង់</td></tr>
</table>

<table>
<tr><td colspan="4" align="center">ក្រុមទី២</td></tr>
<tr><td colspan="4" align="center">ប្រភេទៈ សត្វ<br>ឆ្កែ ឆ្មា បង្កង បង្គារ មាន់ ឆ្លាម ទា ខ្លា មឹក បាឡែន ខ្លាឃ្មុំ ឥន្ទ្រី ត្រីរ៉ស់ ត្រីក្រាញ់ ក្រៀល ក្ងាន ភេ ក្របី</td></tr>
<tr><td colspan="2" align="center">ប្រភេទៈ សត្វលើគោក<br>ឆ្កែ ឆ្មា មាន់ ខ្លា ខ្លាឃ្មុំ ឥន្ទ្រី ក្រៀល ក្ងាន អាកេងកង ក្របី</td><td colspan="2" align="center">ប្រភេទៈ សត្វក្នុងទឹក<br>បង្កង បង្គារ ឆ្លាម មឹក បាឡែន ត្រីរ៉ស់ ត្រីក្រាញ់ ភេ</td></tr>
<tr><td align="center">ប្រភេទៈ ថនិកសត្វ<br>ឆ្កែ ឆ្មា ខ្លា ខ្លាឃ្មុំ ក្របី</td><td align="center">ប្រភេទៈ បក្សី<br>មាន់ ទា ឥន្ទ្រី ក្រៀល ក្ងាន អាកេងកង</td><td align="center">ប្រភេទៈ ទឹកសាប<br>បង្កង ត្រីរ៉ស់ ភេ ត្រីក្រាញ់</td><td align="center">ប្រភេទៈ ទឹកប្រៃ<br>បង្គារ ឆ្លាម បាឡែន</td></tr>
</table>

អ្នកសម្របសម្រួលសួរសិក្ខាកាម ថាតើពួកគាត់អាចបែងចែកក្រុមថនិកសត្វឱ្យទៅជាពីរឬបីក្រុមផ្សេងទៀតបានឬទេ? (ចម្លើយរំពឹងទុកៈ *សត្វព្រៃ/សត្វស្រុក ស៊ីស្មៅ/ស៊ីសាច់*)។

**ដំណាក់កាលបង្រៀនទី ២.៣ៈ ការធ្វើចំណាត់ថ្នាក់ (តាក់សូណូមី) នៃសំណួរ** **៦០ នាទី**

**សម្ភារៈ ឯកសារទី៩** អត្ថបទ និង សំណួរ តារាងដែលបង្ហាញពីប្រភេទសំខាន់ៗបីនៃសំណួរ និង លក្ខណៈរបស់វា

អ្នកសម្របសម្រួលនិយាយថា ឥឡូវនេះសិក្ខាកាមនឹងគិតបន្ថែមទៀតអំពីការធ្វើចំណាត់ថ្នាក់សំណួរ។ យើងនឹងយកសំណួរចងចាំដាក់ជាប្រភេទទី១ ប៉ុន្តែយើងបំបែកសំណួររិះគិតជាពីរក្រុមគឺ សំណួរយល់ដឹង និង សំណួរគិតកម្រិតខ្ពស់។

| **ការធ្វើចំណាត់ថ្នាក់ចាស់** | សំណួរចងចាំ | សំណួររិះគិត | |
|---|---|---|---|
| **ការធ្វើចំណាត់ថ្នាក់ថ្មី** | សំណួរចងចាំ | សំណួរយល់ដឹង | សំណួរគិតកម្រិតខ្ពស់ |

អ្នកសម្របសម្រួលនិយាយថា ប្រព័ន្ធនៃការធ្វើចំណាត់ថ្នាក់ភាគច្រើនបំផុតផ្សេងទៀត គេបែងចែកប្រភេទច្រើនជាងនេះគឺរហូតដល់ ៦ ប្រភេទ។ ប្រភេទទី១ គឺសំណួរចងចាំ ដែលសំណួរនេះមានលក្ខណៈងាយជាងគេបំផុត។ បន្ទាប់មក មានសំណួរ៥ប្រភេទទៀត ដែលសំណួរនីមួយៗតម្រូវឱ្យមានការគិតច្រើនឡើងៗ រហូតដល់សំណួរកម្រិតទី៦ គឺសំណួរវាយតម្លៃ។ ប្រព័ន្ធនៃការធ្វើចំណាត់ថ្នាក់សំណួរទៅជា៦កម្រិត ពីកម្រិតងាយជាងគេបំផុត (ទាបជាងគេបំផុត) ទៅកម្រិតស្មុគ្រស្មាញបំផុត (កម្រិតខ្ពស់បំផុត) ត្រូវបានគេហៅជាភាសាអង់គ្លេសថា សំណួរតាក់សូណូមី (Taxonomy of questions)។

| កម្រិត | ក្រុម | ឈ្មោះកម្រិតសំណួរ | **អ្វីដែលតម្រូវឱ្យធ្វើ (លក្ខណៈ)** |
|---|---|---|---|
| ១ | **ចងចាំ** | ចងចាំ | នឹកឃើញឡើងវិញនូវព័ត៌មានណាមួយ |
| ២ | **យល់ដឹង** | យល់ដឹង | ពន្យល់នូវអត្ថន័យនៃព័ត៌មានណាមួយ |
| ៣ | **គិតកម្រិតខ្ពស់** | អនុវត្ត | អនុវត្តព័ត៌មានអ្វីមួយដែលបានយល់ ទៅក្នុងស្ថានការណ៍មួយផ្សេងទៀត ដើម្បីបង្កើតជាលទ្ធផលមួយ។ |
| | | វិភាគ | គិតអំពីព័ត៌មានមួយឬច្រើន ហើយបកប្រែព័ត៌មាននោះ ដើម្បីបង្កើតគំនិតថ្មី ឬ ការសន្និដ្ឋានថ្មី ខុសពីព័ត៌មានដែលបានផ្តល់រួចហើយ |
| | | សំយោគ | យកគំនិតពីព័ត៌មានផ្សេងគ្នាចំនួនពីរ ឬ ច្រើន មកបញ្ចូលគ្នា ដើម្បីបង្កើតជាគំនិតថ្មីមួយ។ |
| | | វាយតម្លៃ | ថ្លឹងថ្លែងទិន្នន័យច្រើនដើម្បីបង្កើតជាមតិយោបល់ ឬ ឈានទៅរកការសន្និដ្ឋានមួយ និង ពន្យល់ហេតុផលសម្រាប់ការថ្លឹងថ្លែងនោះ។ |

អ្នកសម្របសម្រួលនិយាយថា នៅក្នុងសិក្ខាសាលានេះយើងពុំមានពេលវេលាគ្រប់គ្រាន់ដើម្បីសិក្សាឱ្យបានល្អិតល្អន់នូវសំណួរកម្រិតទាំង៦នោះទេ ដូច្នោះយើងនឹងជជែកគ្នាតែអំពីៈ

ប្រភេទទី១ៈ សំណួរចងចាំ

ប្រភេទទី២: សំណួរយល់ដឹង

ប្រភេទទី៣: សំណួរគិតកម្រិតខ្ពស់ (បន្ទាប់មកយើងបញ្ចូលសំណួរកម្រិតខ្ពស់ជាងគេទាំង៤ទៅក្នុងប្រភេទនេះតែម្តង)

កម្រិតនៃសំណួរគិតកម្រិតខ្ពស់រួមបញ្ចូលសំណួរដូចជា សំណួរអនុវត្ត វិភាគ សំយោគ និង វាយតម្លៃ។ សំណួរទាំងអស់នេះមានលក្ខណៈខុសប្លែកពីសំណួរចងចាំ និង សំណួរយល់ដឹង ពីព្រោះអ្នកត្រូវតែបង្កើតគំនិតថ្មី ឬ ព័ត៌មានថ្មីដើម្បីឆ្លើយនឹងសំណួរទាំងនេះ។ នៅពេលអ្នកគិតឱ្យបានច្រើនអំពីការប្រើប្រាស់សំណួរ ហើយព្យាយាមអនុវត្តនៅក្នុងថ្នាក់រៀនរបស់អ្នក អ្នកនឹងចាប់ផ្តើមស្គាល់ភាពខុសគ្នារវាងសំណួរកម្រិតទាំង៤នេះ។ នៅពេលចាប់ផ្តើម វាជាការលំបាកមួយ ដូច្នេះយើងមិនព្យាយាមធ្វើនៅក្នុងសិក្ខាសាលានេះទេ ពីព្រោះយើងពុំមានពេលគ្រប់គ្រាន់ដើម្បីអនុវត្ត។

អ្នកសម្របសម្រួលនិយាយថា: ដើម្បីបញ្ជាក់ឱ្យកាន់តែច្បាស់ យើងនឹងអនុវត្តទៅលើឧទាហរណ៍មួយរួមគ្នា។ អ្នកសម្របសម្រួលចែក**ឯកសារទី៩** (នៅខាងក្រោម)។

អ្នកសម្របសម្រួលឱ្យសិក្ខាកាមអានអត្ថបទ បន្ទាប់មកមើលសំណួរ។ អ្នកសម្របសម្រួលប្រាប់ឱ្យសិក្ខាកាមព្យាយាមឆ្លើយសំណួរ។ អ្នកសម្របសម្រួលប្រាប់ឱ្យពួកគាត់និយាយទៅកាន់អ្នកដទៃទៀតដើម្បីផ្លាស់ប្តូរយោបល់គ្នា។ អ្នកសម្របសម្រួលប្រាប់ថា នៅពេលនេះសូមកុំទាន់អាលសរសេរពីប្រភេទសំណួរ។

នៅពេលសិក្ខាកាមបានសរសេរចម្លើយរួចហើយ អ្នកសម្របសម្រួលសួរពួកគាត់ពីអ្វីដែលបានសរសេរ សម្រាប់សំណួរទី១ និង បន្ទាប់មកទៀត សំណួរទី២។ អ្នកសម្របសម្រួលសួរ: *តើអ្នកដឹងចម្លើយចំពោះសំណួរទាំងនោះដោយរបៀបណា?* ចម្លើយរំពឹងទុក: *ដោយសារព័ត៌មាន មាននៅក្នុងអត្ថបទ-ខ្ញុំបានចងចាំ ឬខ្ញុំបានអាន*។ អ្នកសម្របសម្រួលនិយាយថា "ត្រឹមត្រូវ" ហើយសួរសិក្ខាកាមបន្តទៀតថា *តើសំណួរទាំងនេះជាសំណួរប្រភេទអ្វី?* ចម្លើយរំពឹងទុក: *ចំណួរចងចាំ*។

បន្ទាប់មក អ្នកសម្របសម្រួលសួរសិក្ខាកាមចំពោះសំណួរទី៣ និង ទី៤ ដោយសួរថា: *តើអ្នកដឹងចម្លើយចំពោះសំណួរទាំងនោះដោយរបៀបណា?* ចម្លើយរំពឹងទុក: *តាមរយៈអត្ថបទ*។ អ្នកសម្របសម្រួលនិយាយថា: *ត្រឹមត្រូវ ប៉ុន្តែព័ត៌មាននោះមិនបានបង្ហាញនៅក្នុងអត្ថបទទេ គឺទាល់តែអ្នកបានយល់អត្ថបទសិន ទើបអ្នកអាចរកចម្លើយឃើញ*។ បន្ទាប់មកអ្នកសម្របសម្រួលបន្តសួរតទៅទៀតថា តើសំណួរទាំងនេះជាសំណួរប្រភេទអ្វី? ចម្លើយរំពឹងទុក: *សំណួរយល់ដឹង*។

បន្ទាប់មកទៀតអ្នកសម្របសម្រួល សួរសិក្ខាកាមនូវសំណួរទី៥ និង ទី៦។ អ្នកសម្របសម្រួលសួរ: *តើអ្នកដឹងចម្លើយចំពោះសំណួរទាំងនោះដោយរបៀបណា?* ចម្លើយរំពឹងទុក: *វាគឺជាគំនិតរបស់ខ្ញុំ ដោយផ្អែកលើអ្វីៗនៅក្នុងអត្ថបទ*។ អ្នកសម្របសម្រួលសួរថា: *បើដូច្នោះ តើអ្នកត្រូវធ្វើអ្វីខ្លះ?* ចម្លើយរំពឹងទុក: *យើងត្រូវអានអត្ថបទ ស្វែងយល់អត្ថបទ បន្ទាប់មកប្រើគំនិតផ្ទាល់របស់យើង*

*ដើម្បីឆ្លើយសំណួរ។* អ្នកសម្របសម្រួលសួរថា: *ត្រឹមត្រូវ បើដូច្នោះតើអ្នកគិតថាសំណួរទី៥ និង ទី៦ ជាសំណួរប្រភេទណាដែរ?* ចម្លើយរំពឹងទុក: *សំណួរគិតកម្រិតខ្ពស់។*

**ឯកសារទី៩**

គ្រូបង្រៀនអានអត្ថបទខ្លីនេះទៅកាន់សិស្សថ្នាក់ទី៥ ឬ សរសេរនៅលើចំណិតក្រដាស រួចហើយផ្តល់ឱ្យសិស្សក្នុងក្រុមតូច ដើម្បីអាន និង ពិភាក្សា...

> *មានម៉ូតូ ឡាន និង យានយន្តជាច្រើន កំពុងធ្វើចរាចរ នៅលើដងផ្លូវដីហុយ នៅខាងមុខផ្ទះរបស់ខ្ញុំ ដែលមានកុមារតូចៗតែងតែលេងនៅទីនោះ ។ យានយន្តមួយចំនួនបើកក្នុងល្បឿនលឿន ដែលបញ្ហានេះវាអាចបង្កឱ្យរងរបួសធ្ងន់ធ្ងរដល់កុមារ និង អាចបណ្តាលឱ្យកុមារស្លាប់បាត់បង់ជីវិតទៀតផង ។ ខ្ញុំមិនអាចដឹងពីរបៀបដោះស្រាយបញ្ហានេះបានទេ ។*

ភាពជាគ្រូបង្រៀន តើអ្នកអាចប្រើប្រាស់សំណួរប្រភេទអ្វីដើម្បីសួរកុមារទៅលើអត្ថបទនេះ? មានឧទាហរណ៍មួយចំនួន សរសេរបង្ហាញនៅខាងក្រោម ។ ចូរអាន និង ពិភាក្សាជាមួយដៃគូ ហើយធ្វើការសម្រេចចិត្ត ថាតើសំណួរទាំងនេះស្ថិតនៅក្នុងសំណួរប្រភេទណា (សំណួរចងចាំ សំណួរយល់ដឹង ឬ សំណួរគិតកម្រិតខ្ពស់)

| សំណួរ | ចម្លើយដែលអាចកើតឡើង | ប្រភេទសំណួរ |
|---|---|---|
| តើមានយានយន្តអ្វីខ្លះ កំពុងចរាចរនៅលើផ្លូវ? | ម៉ូតូ ឡាន និង យានយន្តផ្សេងៗ ទៀត | ចងចាំ |
| តើផ្លូវនេះស្ថិតនៅឯណា? | នៅខាងមុខផ្ទះរបស់ខ្ញុំ | ចងចាំ |
| ហេតុអ្វីកុមារត្រូវប្រឈមមុខនឹងការរងរបួស? | ពីព្រោះពួកគេ កំពុងលេងនៅក្បែរផ្លូវ<br>ពីព្រោះផ្លូវនោះហុយ ដែលពិបាកមើល ឃើញកុមារ<br>ពីព្រោះចរាចរតាមផ្លូវ មានល្បឿនលឿន | យល់ដឹង |
| តើអ្នកគិតថា ហេតុអ្វីបានជាកុមារលេងនៅក្បែរផ្លូវ? | ពីព្រោះកុមារតែងតែលេងនៅទីនោះ<br>ពីព្រោះពុំមានទីធ្លាផ្សេងសម្រាប់កុមារលេង<br>ពីព្រោះឪពុកម្តាយរបស់ពួកគេមិនការពារ | សំណួរគិតកម្រិតខ្ពស់ |
| តើអ្វីទៅដែលអ្នកនិពន្ធព្រួយបារម្ភជាងគេបំផុត? | កុមារកំពុងលេងលើផ្លូវដែលគ្រោះថ្នាក់<br>យានយន្តបើកបរក្នុងល្បឿនលឿន | យល់ដឹង |
| តើអ្នកគិតថា មនុស្សដែលរស់នៅក្បែរដងផ្លូវត្រូវធ្វើអ្វីខ្លះ ដើម្បីការពារកុមារកុំឱ្យរងរបួស ឬ អាចនឹងស្លាប់? | សំអាត ឬ ស្រោចទឹកកុំឱ្យផ្លូវហុយ បញ្ឈប់យានយន្តធំៗដែលចរាចរលើផ្លូវនេះ<br>ដាក់ផ្លាកសញ្ញាបង្ហាញថា "កុមារកំពុងលេង"<br>កសាងទំនប់កាត់ផ្លូវដើម្បីបន្ថយល្បឿន<br>កសាងទីធ្លាដែលមានសុវត្ថិភាពឱ្យកុមារលេង | សំណួរគិតកម្រិតខ្ពស់ |

អ្នកសម្របសម្រួលនិយាយថាៈ នេះជាតារាងដែលសង្ខេបសំណួរប្រភេទទាំងបី។ ចូរពិនិត្យមើល និង ពិភាក្សាជាមួយអ្នកដែលអង្គុយក្បែរ។ យើងនឹងប្រើតារាងនេះនៅក្នុងសកម្មភាពបន្ទាប់ ហើយអ្នកអាចអនុវត្តក្នុងការធ្វើចំណាត់ថ្នាក់សំណួរ ទៅជាប្រភេទទាំងបីដោយខ្លួនឯង។

| ប្រភេទសំណួរ | ដើម្បីឆ្លើយសំណួរ គេត្រូវ... | ប្រភេទនៃការគិត/សកម្មភាពដែលចាំបាច់ដើម្បីឆ្លើយ |
|---|---|---|
| ចងចាំ | **ចងចាំ និង និយាយ**អ្វីមួយដែលបានរៀនរួចហើយ | នឹកឃើញ ចងចាំ |
| យល់ដឹង | **យល់ដឹង និង ពន្យល់**ទៅតាមរបៀបផ្សេងនូវគំនិត ឬ ព័ត៌មានដែលបានផ្តល់រួចហើយ | យល់ដឹង ពន្យល់ |
| គិតកម្រិតខ្ពស់ | **យល់ដឹង និង បង្កើតគំនិតថ្មី** ចេញពីគំនិត ឬ ព័ត៌មានដែលមាន និង **អាចពន្យល់**គំនិតនោះបាន... | ប្រៀបធៀប បង្ហាញភាពផ្ទុយគ្នា បកស្រាយ អនុវត្ត ស្រាវជ្រាវរកហេតុផល វិភាគ ធ្វើសម្មតិកម្ម វាយតម្លៃ កំណត់អទិភាព |

**ដំណាក់កាលបង្រៀនទី ២.៤: កិច្ចការស្វែងរកប្រភេទទាំងបីនៃសំណួរ** **៤៥ នាទី**

**សម្ភារៈ ឯកសារទី១០** អំពីឧទាហរណ៍នៃសកម្មភាពសិក្សា និង សំណួរសម្រាប់វិភាគជាក្រុមតូច **ឯកសារទី១១** សម្រាប់គ្រូបង្រៀនដែលបង្ហាញពីការសួរសំណួរ និង ការគិតកម្រិតខ្ពស់

អ្នកសម្របសម្រួលប្រាប់សិក្ខាកាមថាឥឡូវនេះពួកគាត់ត្រូវបំបែកទៅជាក្រុមតូចៗ។ កិច្ចការដែលត្រូវធ្វើគឺត្រូវអាន និង ពិភាក្សាលើការពិពណ៌នាចំនួនពីរអំពីសកម្មភាពសិក្សា និង កម្រងសំណួរបន្ទាប់ពីការអានចប់ការពិពណ៌នានីមួយៗ។ ការពិពណ៌នាទី១គឺជាសកម្មភាពមុខវិជ្ជាវិទ្យាសាស្ត្រ និង ទី២ ក្នុងមុខវិជ្ជាគណិតវិទ្យា។ ពួកគេត្រូវយល់ស្របគ្នាលើចម្លើយចំពោះសំណួរដែលគ្រូកំពុងប្រើនៅក្នុងសកម្មភាពសិក្សានីមួយៗ ហើយធ្វើការសម្រេចចិត្តថា សំណួរនីមួយៗចូលទៅក្នុងប្រភេទមួយណា-ចងចាំ យល់ដឹង ឬ ការគិតកម្រិតខ្ពស់...។

**ឧទាហរណ៍ទី១: មុខវិជ្ជាវិទ្យាសាស្ត្រ**

គ្រូបង្រៀន និង កូនសិស្សដាំគ្រាប់ផ្កាតូចៗនៅក្នុងសួនច្បារខាងក្រៅថ្នាក់រៀន។ សិស្សទាំងអស់គ្រូបែងចែកជា៦ក្រុមតូច។ កុមារនៅក្នុងក្រុមត្រូវមានតួនាទីថែរក្សាផ្កានោះ (ស្រោចទឹក។ល។)។ កុមារសង្កេតមើលផ្កាចំនួនម្ដងក្នុងមួយសប្ដាហ៍ ហើយគ្រូបង្រៀនសួរពួកគេឱ្យរៀបរាប់ពីអ្វីដែលបានសង្កេតឃើញ។ នៅលើកដំបូងពុំឃើញមានអ្វីកើតឡើងទេ តែក្រោយមកកូនរុក្ខជាតិក៏ដុះឡើង។ បន្ទាប់ពីរយៈពេលមួយខែដែលកុមារបានដាំ គេឃើញផ្កាទីមួយដុះឡើង។ បន្ទាប់ពីរយៈពេលពីរខែផ្ការបស់ក្រុមមួយបានងាប់។ មួយថ្ងៃបន្ទាប់ពីផ្កានោះងាប់ គ្រូបង្រៀនធ្វើផែនការមេរៀនអំពីផ្កា និង សួនច្បារ។ គាត់បានផ្ដល់សំណួរចំនួន៦ឱ្យកុមារដើម្បីពិភាក្សាជាក្រុមតូច។

| សំណួរ | ចម្លើយរំពឹងទុក | ប្រភេទសំណួរ |
|---|---|---|
| តើផ្កាមានឈ្មោះអ្វី? | ឈ្មោះ | ចងចាំ |
| តើយើងបានដាំគ្រាប់ផ្កានៅពេលណា? | ២ ខែកន្លងមកហើយ | ចងចាំ |
| តើផ្កាមានពណ៌អ្វី? | ពណ៌ស ។ល។ | ចងចាំ |
| តើផ្កាត្រូវការអ្វីដើម្បីលូតលាស់? | ទឹក ដី ពន្លឺព្រះអាទិត្យ | យល់ដឹង |
| ហេតុអ្វីបានជាផ្កាមួយចំនួនងាប់? | ទឹកច្រើនពេក<br>ពន្លឺច្រើនពេក<br>ទឹកមិនគ្រប់គ្រាន់<br>ផ្កាចាស់<br>ផ្កាមានជំងឺ | គិតកម្រិតខ្ពស់ |
| តើអ្នកគិតថា ហេតុអ្វីបានជាដើមផ្កាមួយចំនួនដុះលូតលាស់បានខ្ពស់ និង មានផ្កាច្រើនជាងដើមផ្កាផ្សេងៗទៀត? | ដាំនៅលើដីដែលមានជីជាតិល្អ<br>ពូជមានគុណភាពល្អ<br>ផ្កាមានសុខភាពល្អ គ្មានជំងឺ<br>កុមារនៅក្នុងក្រុមយកចិត្តទុកដាក់ថែរក្សាបានល្អ<br>ផ្កាទទួលបានពន្លឺព្រះអាទិត្យ | គិតកម្រិតខ្ពស់ |

កុមារអាចឆ្លើយសំណួរបីដំបូងដោយការចងចាំ។ សំណួរទី៤ត្រូវការការយល់ដឹងខ្លះពីស្ថានភាពនៃការដាំផ្កា។ សំណួរពីរចុងក្រោយតម្រូវឱ្យកុមារប្រើប្រាស់ការយល់ដឹងរបស់ពួកគេ និង បទពិសោធន៍ បូករួមនឹងគំនិតថ្មីៗផ្ទាល់ខ្លួន ដើម្បីឆ្លើយសំណួរ។

ឧទាហរណ៍ទី២

គ្រូបង្រៀនផ្ដល់គ្រាប់ឈើគូសចំនួន២០ទៅក្រុមតូចនីមួយៗនៅក្នុងថ្នាក់ទី២។ បន្ទាប់មកគ្រូប្រាប់ឱ្យសិស្សធ្វើការរួមគ្នា ដើម្បីយល់ស្រប គ្នាទៅនឹងសំណួរដែលគ្រូនឹងសួរពួកគេ...

| សំណួរ | ចម្លើយរំពឹងទុក | ប្រភេទសំណួរ |
|---|---|---|
| តើមានគ្រាប់ឈើគូសចំនួនប៉ុន្មាន? | ២០ | ចងចាំ |
| ក្នុងចំណោមគ្រាប់ឈើគូសចំនួន២០នេះ បើយើងបែងចែកមួយក្រុម៥ដើម តើមានប៉ុន្មានក្រុម? | ៤ | ចងចាំ |
| កុមារម្នាក់មានកូនឃ្លី២០ នៅក្នុងហោប៉ៅខោ។ ហោប៉ៅខោនោះមានប្រហោង ហើយនៅពេលវាមកដល់សាលារៀន ឃើញនៅសល់តែកូនឃ្លី១៣។ តើកូនឃ្លីបាត់ចំនួនប៉ុន្មាននៅតាមផ្លូវ? | ៧ | ចងចាំ??<br>យល់ដឹង |
| កុមារម្នាក់មានកូនឃ្លី២០ ហើយវាបានឱ្យកូនឃ្លីទៅមិត្តរបស់វាម្នាក់ៗចំនួន៤។ តើកុមារនេះមានមិត្តប៉ុន្មាននាក់? | ៥ | ចងចាំ??<br>យល់ដឹង |
| តើអ្នកអាចបង្កើតការ៉េឱ្យបានធំបំផុត ដោយរបៀបណា?<br>តើអ្នកនៅសល់គ្រាប់ឈើគូសឬទេ?<br>តើអ្នកអាចបង្កើតការ៉េដោយប្រើគ្រាប់ឈើគូសនោះឬទេ? | ៥×៥ គ្រាប់ឈើគូស | គិតកម្រិតខ្ពស់ |
| តើអ្នកអាចបង្កើចតុកោណឱ្យបានវែងបំផុត ដោយប្រើគ្រាប់ឈើគូសចំនួន២០ បានដោយរបៀបណា?<br>តើអ្នកអាចបង្កើតចតុកោណដែលមានរូបផ្សេងៗទៀតឬទេ? | ៩×១ គ្រាប់ឈើគូស<br>៨×២ គ្រាប់ឈើគូស<br>៧×៣ គ្រាប់ឈើគូស ។ល។ | គិតកម្រិតខ្ពស់ |

កុមារអាចឆ្លើយសំណួរពីរដំបូងដោយ**ការរាប់**។ កុមារត្រូវស្តាប់រឿងពីរអំពីចំនួនដើម្បី **ស្វែងយល់អត្ថន័យ** ហើយបន្ទាប់មកធ្វើតាមអ្វីដែលកើតឡើងនៅក្នុងរឿង ដើម្បីឆ្លើយសំណួរ។ នៅក្នុងសំណួរគិតកម្រិតខ្ពស់ទាំងពីរ កុមារត្រូវ**ស្តាប់ ស្វែងយល់** និង **ប្រើប្រាស់ការយល់ដឹង**របស់ពួកគេ អំពីអ្វីដែលជារូបការ៉េ និង ចតុកោណ ទៅក្នុងការពិសោធន៍ ដើម្បីរកចម្លើយ។

នៅពេលសិក្ខាកាមបំពេញកិច្ចការចប់ អ្នកសម្របសម្រួលសុំឱ្យក្រុមចំនួនពីរឡើងស្ម័គ្រចិត្តបង្ហាញការរកឃើញរបស់ពួកគេសម្រាប់ឧទាហរណ៍ទី១ និង ឧទាហរណ៍ទី២។ នៅក្នុងខណៈក្រុមឡើងបង្ហាញ អ្នកសម្របសម្រួលសួរសិក្ខាកាមផ្សេងទៀត ថាតើពួកគេយល់ស្របទៅនឹងកាបង្ហាញនេះឬទេ។ បន្ទាប់មក អ្នកសម្របសម្រួលចែកឯកសារទី១១ អំពីការសួរសំណួរ និង ការគិតកម្រិតខ្ពស់។

**ដំណាក់កាលបង្រៀនទី ២.៥: រចនាសម្ព័ន្ធនៃភាសាដែលប្រើប្រាស់ដើម្បីសួរសំណួរទៅតាមកម្រិតផ្សេងៗ** **៦០ នាទី**

**សម្ភារៈ**

អ្នកសម្របសម្រួលនិយាយថា សិក្ខាកាមអាចកត់សម្គាល់ថាប្រភេទនៃភាសាដែលប្រើប្រាស់ក្នុងការសួរសំណួរ គឺជាញឹកញាប់ស្រដៀងគ្នាទៅនឹងប្រភេទទាំងបីនេះ។

**ដំណាក់កាលបង្រៀនទី ២.៦: ការសរសេរសំណួរដែលមានកម្រិតខ្ពស់** **៦០ នាទី**

**សម្ភារៈ** សៀវភៅសិក្សាគ្រប់កម្រិតថ្នាក់

អ្នកសម្របសម្រួលនិយាយថា ឥឡូវនេះសិក្ខាកាមត្រូវអនុវត្តសរសេរសំណួរនៅក្នុងប្រភេទទាំងបីដោយខ្លួនឯង ដោយផ្អែកលើមេរៀន ពីសៀវភៅសិក្សាសង្គមរបស់ក្រសួងអប់រំ យុវជន និង កីឡា ទៅតាមកម្រិតថ្នាក់របស់ខ្លួន។

សម្រាប់កិច្ចការនេះ សិក្ខាកាមជាតំបូងត្រូវជ្រើសរើសមេរៀន។ បន្ទាប់មកត្រូវជ្រើសរើសសកម្មភាពសិក្សា។ សកម្មភាពនេះអាចជាសកម្មភាពសិក្សាដែលផ្អែកលើអត្ថបទ (ដូចជាអត្ថបទមួយដំបូងនៅក្នុងសិក្ខាសាលា) ឬ សកម្មភាពសិក្សាអ្វីក៏ដោយ ឱ្យតែសិក្ខាកាមយល់ស្របគ្នា។ បន្ទាប់មកសិក្ខាកាមគួរសរសេរការពណ៌នាខ្លីមួយអំពីមេរៀន និង សកម្មភាពសិក្សារបស់កុមារ (៣-៥ បន្ទាត់) រួចហើយសរសេរសំណួរចំនួន៦ដែលអាចប្រើប្រាស់ក្នុងកំឡុង ឬ បន្ទាប់សកម្មភាព។ សំណួរពីរស្ថិតក្នុងកម្រិតចងចាំ សំណួរពីរទៀតកម្រិតយល់ដឹង និង សំណួរពីរផ្សេងទៀតជាប្រភេទគិតកម្រិតខ្ពស់។ សិក្ខាកាមត្រូវបង្ហាញលទ្ធផលរបស់ពួកគេនៅលើក្រដាសរ៉ាមធំ ទៅតាមគំរូខាងក្រោម...

<table>
<tr><td colspan="2">ចំណងជើងមេរៀន<br>(ឯកសារយោងរបស់សៀវភៅ ទំព័រទី...)<br>ការពិពណ៌នាមេរៀន និងសកម្មភាពសិក្សារបស់សិស្ស<br>----------------------------------------------------------------------------<br>---------------------------------------------------------------------------</td></tr>
<tr><td>សំណួរចងចាំទី១</td><td></td></tr>
<tr><td>សំណួរចងចាំទី២</td><td></td></tr>
<tr><td>សំណួរយល់ដឹងទី១</td><td></td></tr>
<tr><td>សំណួរយល់ដឹងទី២</td><td></td></tr>
<tr><td>សំណួរគិតកម្រិតខ្ពស់ទី១</td><td></td></tr>
<tr><td>សំណួរគិតកម្រិតខ្ពស់ទី២</td><td></td></tr>
</table>

**ដំណាក់កាលបង្រៀនទី ២.៧: សកម្មភាពសិក្សាដើម្បីជួយសិស្សឱ្យគិតកម្រិតខ្ពស់** ៦០ នាទី

**១.ការស្រាវជ្រាវដោយសិស្ស** (ការប្រមូលភស្តុតាង/ទិន្នន័យ...រួចទាញការសន្និដ្ឋានពីវត្ថុទាំងនោះ)

**សម្ភារៈ ឯកសារទី១២** ឧទាហរណ៍អំពីកិច្ចការស្រាវជ្រាវ សម្រាប់ថ្នាក់ទី១ ៣ និង ទី៥

អ្នកសម្របសម្រួលនិយាយថា: ការរៀបចំសកម្មភាពសិក្សាងាយៗសម្រាប់សិស្សគឺជារបៀបមួយប្រសើរណាស់ក្នុងការជំរុញការគិតកម្រិតខ្ពស់។ ដោយសារសកម្មភាពនេះ កុមារ "កំពុងបង្កើត" ចំណេះដឹងសម្រាប់ខ្លួនពួកគេ តាមរយៈការស្រាវជ្រាវរបស់ពួកគេ មិនមែនគ្រាន់តែចាំស្តាប់ និង អានអ្វីមួយប៉ុណ្ណោះទេ។

អ្នកសម្របសម្រួលនិយាយថា: ទោះបីជាយើងស្តាប់ទៅវាហាក់ដូចជាស្មុគ្រស្មាញ និង លំបាក ការងារស្រាវជ្រាវងាយៗនេះគឺកុមារគ្រប់អាយុទាំងអស់អាចធ្វើបាន។ គ្រូបង្រៀនគួរសួរសំណួរ និង ផ្តល់នូវសេចក្តីណែនាំឱ្យបានច្បាស់ (ឬ គំរោង) អំពីរបៀបធ្វើកិច្ចការនោះ។ នៅពេលកុមារបានធ្វើការងារស្រាវជ្រាវរួចហើយ គ្រូបង្រៀនគួររៀបចំសំណួរ ឬ សំណួរដែលអាចជួយសិស្សគិតឱ្យបានជ្រៅអំពីព័ត៌មានដែលពួកគេបានប្រមូល និង ព្យាយាមទាញការសន្និដ្ឋានពីព័ត៌មាននោះ។

នៅទីនេះគឺជាឧទាហរណ៍មួយចំនួន...

| ថ្នាក់ទី | កិច្ចការស្រាវជ្រាវ | សំណួរស្រាវជ្រាវ ដំណើរការ និងសំណួរគិតកម្រិតខ្ពស់ |
|---|---|---|
| ១ | ការស្រាវជ្រាវពីអាហារពេលព្រឹក | **តើយើងបានអ្វីបរិភោគសម្រាប់អាហារពេលព្រឹកកាលពីព្រឹកមិញ?**<br>កុមារបង្កើតជាក្រុមទៅតាមប្រភេទអាហារ ដែលពួកគេបរិភោគកាលពីព្រឹក (បាយ មី គ្មាន ។ល។)។ អ្នកដឹកនាំក្រុមរាប់ក្រុមរបស់ពួកគេ។ កុមារសរសេរចំនួនក្រុមនីមួយៗនៅលើក្តារខៀន។ គ្រូបង្រៀនសួរសំណួរបន្ថែម...អាហារដែលពេញនិយមបំផុត ។ល។<br><br>**តើយើងបានរៀនអ្វីខ្លះពីការសិក្សាស្រាវជ្រាវរបស់ពួកយើង?**<br>• កុមារភាគច្រើននៅក្នុងថ្នាក់បរិភោគបាយកកនៅពេលព្រឹក<br>• កុមារមួយចំនួនបរិភោគមី<br>• កុមារមួយចំនួនទៀតមិនបរិភោគអ្វីទេនៅពេលព្រឹក មុនមកមកសាលារៀន |
| ៣ | ការស្រាវជ្រាវពីកូនរុក្ខជាតិ | តើប្រភេទរុក្ខជាតិដែលមានផ្កាអ្វីខ្លះដែលដាំនៅផ្ទះរបស់ពួកយើង? |

| | | |
|---|---|---|
| | | សម្រាប់កិច្ចការធ្វើនៅផ្ទះ កុមារទាំងអស់ត្រូវនាំយកឧទាហរណ៍មួយនៃផ្កា និង ស្លឹកពីកូនរុក្ខជាតិ ដែលដុះនៅក្បែរ ឬ ក្នុងផ្ទះ។ នៅឯសាលារៀនពួកគេជួបជុំជាក្រុមដើម្បីពិនិត្យមើល រាប់ និង ប្រាប់ឈ្មោះ រាល់ផ្កាដែលសមាជិកក្រុមនាំយកមក។ ក្រុមនីមួយបង្ហាញលទ្ធផលរបស់ខ្លួន។<br><br>**តើយើងបានរៀនអ្វីខ្លះពីការសិក្សាស្រាវជ្រាវរបស់ពួកយើង?**<br>• សិស្សជាច្រើនដាំផ្កាស្បៃរឿង<br>• សិស្សជាច្រើនចូលចិត្តផ្កាពណ៌លឿង និង ក្រហម<br>• យើងបានដឹងថា មានផ្កាពីរប្រភេទដែលគេមិនស្គាល់ឈ្មោះ |
| ៥ | ការស្រាវជ្រាវពីចរាចរ | **តើផ្លូវនៅក្រៅរបងសាលារៀនរបស់ មានភាពមមាញឹកយ៉ាងណា? តើឡានធំនិងកូនឡានបន្ថយល្បឿនឬទេ នៅពេលឆ្លងកាត់សាលារៀន?**<br>បើសិនជាសាលារៀននៅជាប់នឹងផ្លូវដែលមានចរាចរមមាញឹក សិស្សអាចរាប់ និង ធ្វើចំណាត់ថ្នាក់ប្រភេទឡាន (ឡានក្រុង ឡានទីសាន់ កូនឡាន ម៉ូតូ រម៉ក រទេះគោ កង់ ។ល។ ដែលឆ្លងកាត់សាលារៀន ចន្លោះម៉ោង៧ និង ម៉ោង៧:៣០នាទី។ សិស្សអាចធ្វើកំណត់សម្គាល់ អំពីឡានធំ និង ឡានតូចដែលបើកក្នុងល្បឿនលឿនផងដែរ។<br><br>**តើយើងបានរៀនអ្វីខ្លះពីការសិក្សាស្រាវជ្រាវរបស់ពួកយើង?**<br>• ឡានធំចំនួន៣០ និង កូនឡាន៦០ បានឆ្លងកាត់ក្នុងរយៈពេល ៣០នាទី<br>• យានយន្តមួយចំនួនបើកបរយ៉ាងលឿន។ ចំនួនពាក់កណ្តាលនៃឡានធំ និង ឡានតូចមិនបានបន្ថយល្បឿនទេនៅពេលបើកបរឆ្លងកាត់សាលារៀន។<br>• យើងគួរបង្កើតផ្លាកសញ្ញាថ្មី និងមានទំហំធំ ជាសញ្ញាឱ្យយានយន្តបន្ថយល្បឿន ដើម្បីឱ្យមានសុវត្ថិភាពដល់កុមារនៅពេលចូលសាលារៀន។ |

កិច្ចការស្រាវជ្រាវជាច្រើនទាក់ទងនឹងជំហានចំនួនបីសំខាន់ៗខាងក្រោម

**ធ្វើ** សិស្សធ្វើអ្វីមួយរួមគ្នា

**ពិភាក្សា** សិស្សពិភាក្សាអំពីអ្វីដែលពួកគេបានរកឃើញ និង អត្ថន័យរបស់វា

**កត់ត្រា/បង្ហាញ** សិស្សកត់ត្រាពីលទ្ធផលរបស់ពួកគេ ទៅតាមរបៀបណាមួយ

កិច្ចការរបស់សិក្ខាកាមៈ ធ្វើការជាក្រុមតូចដើម្បីជ្រើសរើសសកម្មភាពស្រាវជ្រាវងាយៗសម្រាប់កុមារថ្នាក់ទី២ ទី៤ និង ទី៦ ទៅតាមរបៀបដែលខ្ញុំបានបង្ហាញ សម្រាប់ថ្នាក់ទី១ ទី៣ និង ទី៥

**ដំណាក់កាលបង្រៀនទី ២.៨: សកម្មភាពសិក្សាដើម្បីជួយសិស្សឱ្យគិតកម្រិតខ្ពស់** ៦០ នាទី

**ល្បែងសិក្សាដើម្បីជំរុញការគិតកម្រិតខ្ពស់**...ការធ្វើចំណាត់ថ្នាក់

**សម្ភារៈ** គំរូល្បែងសិក្សា

អ្នកសម្របសម្រួលនិយាយថាៈ សិក្ខាកាមបានដឹងហើយពីល្បែងសិក្សាក្នុងវគ្គបណ្តុះបណ្តាលគ្រូសហគមន៍កាលពីឆ្នាំមុន។ មានគ្រូសហគមន៍ជាច្រើនប្រើប្រាស់ល្បែងសិក្សានៅក្នុងឆ្នាំសិក្សាកន្លងមក។ យើងបានដឹងរួចមកហើយថា ល្បែងមានប្រយោជន៍ណាស់ក្នុងការជំរុញការសិក្សា និង ធ្វើឱ្យការសិក្សាកាន់តែមានភាពសប្បាយរីករាយ។ នៅក្នុងដំណាក់កាលបង្រៀននាពេលនេះ យើងនឹងបង្ហាញថាល្បែងសិក្សាក៏ជាមធ្យោបាយមួយល្អក្នុងការអភិវឌ្ឍន៍ការគិតកម្រិតខ្ពស់។

អ្នកសម្របសម្រួលនិយាយថាៈ កាលពីព្រឹកមិញ យើងពិភាក្សាពី "តាក់សូណូមី" ដែលយើងបកស្រាយថាជា "ប្រព័ន្ធមួយនៃការធ្វើចំណាត់ថ្នាក់" ។ ប្រភេទមួយក្នុងចំណោមប្រភេទទូទៅទាំងឡាយនៃល្បែងសិក្សាគឺ **ការធ្វើចំណាត់ថ្នាក់**។ នៅពេលនេះ យើងដឹងហើយថាគ្រូសហគមន៍មានបទពិសោធន៍ និង គំនិតច្រើន ពីការធ្វើចំណាត់ថ្នាក់នេះ។ នៅក្នុងឆ្នាំនេះ (២០០៦-២០០៧) គ្រូឧទ្ទេសរបស់អេស្កាប់នឹងធ្វើការជាមួយអ្នក អំពីរបៀបដែលគ្រូសហគមន៍អាចបង្កើតល្បែងសិក្សាដើម្បីលើកទឹកចិត្តសិស្សឱ្យគិតកម្រិតខ្ពស់។ សិស្សអាចបង្ហាញការយល់ដឹងរបស់ពួកគេតាមរយៈការលេងល្បែងសិក្សាដែលបានជោគជ័យ។ គ្រូបង្រៀនគួរតែឱ្យសិស្សពន្យល់ពីអ្វីដែលពួកគេបានធ្វើ ដើម្បីជួយឱ្យពួកគេបានយល់កាន់តែច្បាស់ថែមទៀត។

បន្ទាប់មកអ្នកសម្របសម្រួល បកស្រាយបង្ហាញ **ល្បែងចំណាត់ថ្នាក់** ពីរដោយប្រើប្រាស់ប័ណ្ណធំ និង រៀបចំប័ណ្ណនោះជាក្រុមនៅលើក្តារខៀន។ អ្នកសម្របសម្រួលពន្យល់ពីល្បែងសិក្សាទៅកាន់សិក្ខាកាមជាមុនសិន និង អនុញ្ញាតឱ្យពួកគាត់ជ្រើសរើសកន្លែងដែលអាចដាក់ប័ណ្ណនោះ។ នៅពេលប័ណ្ណទាំងត្រូវបានរៀបចំរួចហើយ អ្នកសម្របសម្រួលសួរសិក្ខាកាមថា តើពួកគាត់យល់ស្របលើការរៀបចំនេះឬទេ។ បើសិនជាពួកគេនិយាយថា "បាទ" អ្នកសម្របសម្រួលសួរសំណួរអំពីប័ណ្ណនីមួយៗ និង ហេតុអ្វីបានជាដាក់ប័ណ្ណទៅតាមកន្លែងនេះ ឬ នោះ។ សិក្ខាកាមស្ម័គ្រចិត្តឡើងនិយាយ។

**ល្បែងទី១ គណិតវិទ្យា**

ចូរធ្វើចំណាត់ថ្នាក់ចតុរង្ស (មុខបួន) ជាពីរក្រុម និង ដាក់ឈ្មោះក្រុមនីមួយៗ។ បន្ទាប់មក ធ្វើចំណាត់ថ្នាក់ក្រុមនីមួយៗ ជាអនុក្រុមពីរទៀត ព្រមទាំងដាក់ឈ្មោះក្រុម។



**ល្បែងទី២ សិក្សាសង្គម**

ការធ្វើចំណាត់ថ្នាក់ មានន័យថាជាការដាក់អ្វីមួយជាពីរក្រុម បន្ទាប់មកធ្វើការបែងចែកជាអនុក្រុម ព្រមទាំងដាក់ឈ្មោះឱ្យក្រុមនីមួយៗនោះ។

សាឡាង ឡានធំ កូនឡាន ម៉ូតូ កង់ រទេះគោ រមកម៉ូតូ ទូកចែវ ទូកល្បឿន កប៉ាល់ ឡានសណ្តោង រម៉កកង់បី រទេះរុញអាហារ

*ការបែងចែកទី១* *លើគោក-លើទឹក ឬ មានម៉ាស៊ីន-គ្មានម៉ាស៊ីន ឬ លើផ្លូវ-ក្រៅផ្លូវ*

*ការបែងចែកទី២* *ធ្វើដូចខាងលើ ឬ ក៏អាចរៀបចំផ្សេងទៀតទៅតាមការពិភាក្សាគ្នា*

អ្នកសម្របសម្រួលនិយាយថា ការផលិតល្បែងសិក្សាដើម្បីជំរុញការគិតកម្រិតខ្ពស់ នឹងត្រូវបានពង្រីកបន្ថែមនៅក្នុងការប្រជុំនៅក្នុងឆ្នាំសិក្សានេះ។

**សរុប ៦ម៉ោង ៣០នាទី**

# ថ្ងៃទី៣

## ប្រធានរឿងទី៣: ការអភិវឌ្ឍន៍បំនិនភាសា-ការអាន និង ការសរសេរ

**ដំណាក់កាលបង្រៀនទី ៣.១: ការបង្កើតបរិស្ថានបន្ទប់រៀន ដើម្បីជួយអភិវឌ្ឍភាសា ២០ នាទី**

**សម្ភារៈ ឯកសារទី១៣** ការបង្កើតបរិស្ថានថ្នាក់រៀនសំបូរបែប

អ្នកសម្របសម្រួលពន្យលថាៈ គ្រូបង្រៀនគឺជាអ្នកគ្រប់គ្រងថ្នាក់រៀន។ ការទទួលខុសត្រូវរបស់គ្រូបង្រៀនគឺធ្វើការជាមួយសិស្ស ដើម្បីបង្កើតបរិស្ថាន "សំបូរបែប" សម្រាប់ការសិក្សា។ នេះមានន័យថាបន្ទប់រៀនគួរមានផាសុខភាព (ស្អាត) ទាក់ទាញទឹកចិត្ត និង ជាកន្លែងជំរុញឱ្យមានការរៀនសូត្រ។ គោលបំណងគឺចង់ឱ្យកុមារមានការសប្បាយរីករាយមកសាលារៀនជារៀងរាល់ថ្ងៃ និង អាចស្វែងរកអ្វីៗដែលថ្មី ដើម្បីមើល និង ស្រាវជ្រាវ។

អ្នកសម្របសម្រួលនិយាយថាៈ បរិស្ថាន "សំបូរបែប" មិនមែនមានន័យថា គ្រូបង្រៀនត្រូវតែចំណាយលុយច្រើនទៅលើការតុបតែងនោះទេ។ បន្ទប់រៀនគួរមានសម្ភារៈដែលជំរុញការសិក្សា "សំបូរបែប"។ សម្ភារៈមួយចំនួនអាចទិញដោយប្រើប្រាក់ PAP (ឧ.តារាងអក្ខរក្រម តារាងចំនួន ផែនទី ។ល។)។ សម្ភារមួយចំនួនទៀតអាចផ្តល់ដោយក្រសួងអប់រំ យុវជន និង កីឡា ឬ តាមរយៈកម្មវិធីផ្សេងៗរបស់រដ្ឋាភិបាល (ឧ. អេស្កាប់ ការអប់រំពីមីន ហ៊ីវ/អេដស៍ អាហាររូបត្ថម្ភ ការអប់រំសម្រាប់ទាំងអស់គ្នា ។ល។) និង សម្ភារផ្សេងៗទៀតអាចរៀបចំដោយគ្រូបង្រៀន និង សិស្ស។ សម្ភារទាំងនេះរួមមាន

- ឧទាហរណ៍ ឬ កាតាំងបង្ហាញការសរសេររបស់សិស្ស គំនូរ ឬ ហត្ថកម្ម
- ការងារដែលផលិតនៅក្នុងមូលដ្ឋាន និង គ្រឿងសម្ភារផ្ទះបាយ (សំណាញ់ ឧបករណ៍ផ្សេងៗ កន្ត្រក...)
- សម្ភារពីបរិស្ថានដូចជា ការបង្ហាញពីស្លឹកឈើ ផ្កា សត្វល្អិត...
- ការពិសោធន៍ងាយៗដើម្បីឱ្យកុមារសង្កេត និង ចងក្រងជាឯកសារ (ការបណ្តុះគ្រាប់ ឬ ការដាំកូនរុក្ខជាតិនៅក្នុងទឹក និង ក្នុងផើង កូនក្អុក សួនសត្វល្អិត ផ្លែឈើដែលពុកផុយ...)

អ្នកសម្របសម្រួលនិយាយថាៈ គ្រូបង្រៀនអាចស្វែងរកធនធានគ្រប់ទីកន្លែង។ ទស្សនាវដ្តី និង កាសែតចាស់ៗ ដែលសម្ភារនេះ តែងតែជាការចាប់អារម្មណ៍មួយ។ តារាងប៉ូស្ទ័រដែលផុតកាលបរិច្ឆេទ ឬ ឈប់ប្រើប្រាស់របស់ការប្រជុំ និង ព្រឹត្តិការណ៍ ឬ យុទ្ធនាការបង្កើនការយល់ដឹងរបស់រដ្ឋាភិបាល ដែលមានរូបភាព និង អត្ថបទពិតជាក់ស្តែង គួរឱ្យចាប់អារម្មណ៍ សម្រាប់យកមក ធ្វើការពិភាក្សា និង ការវិភាគ។ គ្រូបង្រៀនអាចធ្វើការជាមួយសិស្ស ដើម្បីបន្ថែមតម្លៃទៅលើតារាងផ្សេងៗ និង ប៉ូស្ទ័រចាស់ៗ ដោយការដាក់ស្លាក ដាក់ចំណងជើង ។ល។

គ្រូបង្រៀន និងសិស្សមិនគួររៀបចំតាំងបង្ហាញ រួចហើយបំភ្លេចចោលសម្ភារនោះទេ។ សម្ភារទាំងនោះអាចប្រើប្រាស់សម្រាប់ការ បង្រៀន និង រៀន នៅក្នុងមេរៀនទាំងឡាយ។ សម្ភារទាំងនេះគួរតែមានការផ្លាស់ប្តូរនៅពេលតាំងបានរយៈពេលមួយ ឬ ពីរខែ

ដើម្បីរក្សាចំណាប់អារម្មណ៍របស់សិស្ស។

អ្នកសម្របសម្រួលបែងចែក **ឯកសារទី១៣** អំពីការបង្កើតបរិស្ថានបន្ទប់រៀនសំបូរបែប។

**ដំណាក់កាលបង្រៀនទី ៣.២៖ ភាសានៅក្នុងកម្មវិធីសិក្សា** **១៥ នាទី**

**សម្ភារៈ** តារាងបង្ហាញពីរបៀបបីយ៉ាងនៃការរៀនភាសា

អ្នកសម្របសម្រួលសួរសិក្ខាកាមៈ *នៅសាលារៀន តើមានមុខវិជ្ជាអ្វីខ្លះដែលសិស្សរៀនដោយប្រើភាសា?* ចម្លើយរំពឹងទុកៈ *គ្រប់មុខវិជ្ជាទាំងអស់*។ អ្នកសម្របសម្រួលយល់ស្រប និង និយាយថា គ្រប់មេរៀនទាំងអស់ ទោះបីមុខវិជ្ជាណាក៏ដោយ គឺសុទ្ធតែជាមេរៀនភាសា។

បន្ទាប់មកអ្នកសម្របសម្រួលនិយាយថា អ្នកអប់រំហៅគ្រប់មេរៀនដែលប្រើភាសានេះថា-"ភាសានៅក្នុងកម្មវិធីសិក្សា"។

អ្នកសម្របសម្រួលនិយាយថាៈ តាមរបៀបមួយផ្សេងទៀត អ្នកអប់រំកំណត់ថារាល់មេរៀនទាំងអស់សិស្ស

កំពុងរៀនភាសា

កំពុងរៀន អំពី ភាសា

កំពុងរៀនតាមរយៈភាសា

តើអ្នកគិតថាចំនុចខាងលើនេះមានន័យដូចម្ដេច?

| **ការរៀនភាសាមាន ៣របៀប** | **អត្ថន័យ** |
|---|---|
| ការរៀនភាសា | ការរៀនពាក្យថ្មីៗ |
| ការរៀនអំពីភាសា | ការរៀនពីរចនាសម្ព័ន្ធភាសា ក្បួន វេយ្យាករណ៍ របៀបប្រើប្រាស់ភាសាដើម្បីបង្ហាញពីអត្ថន័យ |
| ការរៀនតាមរយៈភាសា | ការប្រើភាសាជាមធ្យោបាយក្នុងការពន្យល់ និង ការស្វែងយល់គំនិត និង ព័ត៌មាន ពីមុខវិជ្ជាផ្សេងៗជាច្រើនទៀត។ |

**ដំណាក់កាលបង្រៀនទី ៣.៣៖ ការប្រើប្រាស់ប៉ូស្ទ័រ និង រូបភាព...បំនិនស្ដាប់ និង និយាយ** **៤៥ នាទី**

**សម្ភារៈ** ឧទាហរណ៍បី ឬ បួន នៃប៉ូស្ទ័រដែលអាចរកបាននៅក្នុងថ្នាក់រៀនសាលាបឋមសិក្សា (ឧ. ការអប់រំពីគ្រោះថ្នាក់ដោយមីន (របស់ក្រសួងអប់រំ-អង្គការអប់រំពិភពលោក) ការចុះឈ្មោះចូលរៀន (របស់ក្រសួងអប់រំ) ។ល។)

**ការប្រើប្រាស់ប៉ូស្ទ័រសម្រាប់ការបង្រៀន**

អ្នកសម្របសម្រួលនិយាយថាៈ ប៉ូស្ទ័រដែលមានរូបភាព និង/ឬអត្ថបទគឺជាសម្ភារបង្រៀនដ៏មានប្រយោជន៍។ វាមានការងាយស្រួលដល់គ្រូបង្រៀនក្នុងការសួរសំណួរអំពីសម្ភារនេះ ដែលជាឱកាសមួយសម្រាប់កុមារអនុវត្តបំនិនស្តាប់ និង និយាយ។ ចំពោះសំណួរគ្រូអាចសួរបានគ្រប់កម្រិត ដូចឧទាហរណ៍បង្ហាញជូនខាងក្រោម...

| ឧទាហរណ៍សំណួរ | ឧទាហរណ៍ចម្លើយ | កម្រិតសំណួរ |
|---|---|---|
| តើអ្នកឃើញអ្វីខ្លះនៅក្នុងរូបភាព | ខ្ញុំអាចមើលឃើញ... | ចងចាំ |
| តើប៉ូស្ទ័រនេះបង្ហាញពីអ្វី? | បង្ហាញពី... | យល់ដឹង |
| តើអ្នកគិតថាហេតុអ្វី...? | ខ្ញុំគិតថា...ពីព្រោះ... | គិតកម្រិតខ្ពស់ |
| តើអ្វីដែលអ្នកចូលចិត្តបំផុតអំពី...? | ខ្ញុំចូលចិត្ត...ពីព្រោះ... | គិតកម្រិតខ្ពស់ |

បន្ទាប់មកអ្នកសម្របសម្រួលបែងចែកសិក្ខាកាមជាចំនួនក្រុមដូចៗគ្នា ទៅនឹងចំនួនប៉ូស្ទ័រ។ ហើយផ្តល់ចំណិតក្រដាសចំនួនបីទៅឱ្យសិក្ខាកាមនីមួយៗនៅក្នុងក្រុម ដើម្បីសរសេរសំណួបីអំពីប៉ូស្ទ័រនោះ។ ប្រធានក្រុមត្រូវប្រមូលសំណួរទាំងអស់ រើសចេញនូវសំណួរដែលដូចគ្នា រួចហើយបង្ហាញសំណួរផ្សេងៗទៅកាន់ថ្នាក់ទាំងមូល។

អ្នកសម្របសម្រួលនិយាយថាៈ គ្រូបង្រៀនក៏អាចប្រើប៉ូស្ទ័រ សម្រាប់ល្បែងសិក្សាដូចជា

- តើអ្នកអាចមើលឃើញអ្វីមួយនៅក្នុងប៉ូស្ទ័រដែលចាប់ផ្តើមដោយអក្សរ...?
- តើអ្នកអាចបិទស្លាកនេះនៅលើកន្លែងដែលត្រឹមត្រូវនៅលើប៉ូស្ទ័របានឬទេ?
- តើអ្នកអាចមើលឃើញវត្ថុអ្វីខ្លះដែលធំបំផុតចំនួន៥នៅក្នុងប៉ូស្ទ័រ? ចូរដាក់ចំនួន ១ ២ ៣ ៤ និង ៥ នៅលើវត្ថុដែលអ្នករកឃើញ។
- តើអ្នកអាចរកឃើញវត្ថុចំនួនប៉ុន្មាននៅក្នុងប៉ុស្ទ័រដែលមានពណ៌បៃតង/ក្រហម/ស...?

អ្នកសម្របសម្របសន្និដ្ឋានដោយនិយាយថាៈ ល្បែងទាំងអស់នេះគឺមានប្រយោជន៍សម្រាប់ផ្តល់អ្វីមួយឱ្យសិស្សធ្វើ បើសិនជាពួកបញ្ចប់មេរៀនមុនម៉ោង ឬក៏ បើសិនជាសិស្សមួយចំនួនបញ្ចប់កិច្ចការមុនអ្នកដទៃ។

**ដំណាក់កាលបង្រៀនទី ៣.៤ៈ ការប្រើប្រាស់ផែនទី...ការអភិវឌ្ឍន៍ភាសាដោយផ្ទាល់មាត់ ៤៥ នាទី**

**សម្ភារៈ** ឧទាហរណ៍នៃផែនទីដែលសមស្របតាមកម្រិតថ្នាក់នីមួយៗ (ភូមិ ឃុំ ស្រុក ប្រទេសកម្ពុជា តំបន់ ពិភពលោក)

**ការប្រើប្រាស់ផែនទីសម្រាប់ការបង្រៀន**

អ្នកសម្របសម្រួលនិយាយថាៈ ផែនទីគឺជាសម្ភារបង្រៀនដែលមានប្រយោជន៍ណាស់។ គ្រូបង្រៀនអាចប្រើប្រាស់ផែនទីជាប្រភពធនធានសម្រាប់ការសិក្សារបស់សិស្ស ក្នុងមុខវិជ្ជាភាសា គណិត និង សិក្សាសង្គម។ ក្នុងខណៈពេលដែលសិស្សលូតលាស់ធំឡើងៗ

ការយល់ឃើញរបស់ពួកគេក៏រីកលូតលាស់ផងដែរ។ នៅក្នុងថ្នាក់ទី១ កុមារផ្តោតទៅលើខ្លួនឯង គ្រួសារ និង លំនៅដ្ឋានរបស់ពួកគេ។ នៅថ្នាក់ទី២ និង ទី៣ ពួកគេចាប់ផ្តើមគិត និង រៀនពីភូមិ ឃុំ និង អាចរហូតដល់ខេត្តរបស់ពួកគេ។ នៅក្នុងថ្នាក់កម្រិតខ្ពស់ជាងនេះ ពួកគេរៀនអំពីខេត្ត ប្រទេស តំបន់ របស់ពួកគេ និង ពិភពលោក។

| ថ្នាក់ទី | សិស្សផ្តោតទៅលើ | ផែនទី |
|---|---|---|
| ១ | ផ្ទះរបស់ខ្ញុំ សាលារៀនរបស់ខ្ញុំ ការធ្វើដំណើរទៅសាលារៀន | បន្ទប់រៀន |
| ២ | ភូមិរបស់ខ្ញុំ ឃុំរបស់ខ្ញុំ | តំបន់នៅក្នុងមូលដ្ឋាន ប្រទេសកម្ពុជា |
| ៣ | ឃុំរបស់ខ្ញុំ ខេត្តរបស់ខ្ញុំ | ខេត្ត ប្រទេសកម្ពុជា |
| ៤ | ខេត្តរបស់ខ្ញុំ ប្រទេសរបស់ខ្ញុំ | ប្រទេសកម្ពុជា ឬ អាស៊ីអាគ្នេយ៍ |
| ៥ | ប្រទេសរបស់ខ្ញុំ តំបន់របស់ខ្ញុំ ពិភពលោក | អាស៊ីអាគ្នេយ៍ ពិភពលោក |
| ៦ | ពិភពលោក | ពិភពលោក |

គ្រូបង្រៀនអាចសួរសំណួរ ដែលសំណួរនោះកុមារត្រូវតែស្តាប់ដោយប្រុងប្រយ័ត្ន និង ពន្យល់បានច្បាស់ដោយប្រើភាសាផ្ទាល់របស់ពួកគេ។ គ្រូអាចសួរសំណួរដែលតម្រូវឱ្យសិស្ស...

| ស្វែងរកទីកន្លែងនៅលើផែនទី | និយាយអំពីមាត់សមុទ្រ និង កោះ |
|---|---|
| ពណ៌នាទីតាំង (ដោយប្រើពាក្យ ខាងជើង ខាងត្បូង ខាងកើត ខាងលិច) | និយាយអំពីផ្លូវ នឹងទន្លេ |
| ពិពណ៌នាទីតាំងនៃកន្លែងមួយដែលទាក់ទងកន្លែងមួយផ្សេងទៀត | និយាយ និង ប្រៀបធៀបចំងាយ |
| និយាយអំពីព្រំដែន | និយាយអំពីការធ្វើដំណើរពី A ទៅ B |
| ស្វែងរក និង ដាក់ឈ្មោះស្រុក/ខេត្ត/ប្រទេសដែលនៅជាប់ព្រំដែន | |

បន្ទាប់មកអ្នកសម្របសម្រួលបែងចែកសិក្ខាកាមទៅតាមចំនួនស្មើគ្នានឹងចំនួនផែនទី។ ហើយផ្តល់ចំណិតក្រដាសចំនួនបីទៅឱ្យសិក្ខាកាមនីមួយៗនៅក្នុងក្រុម ដើម្បីសរសេរសំណួរបីអំពីប៉ូស្ទ័រនោះ។ ប្រធានក្រុមត្រូវប្រមូលសំណួរទាំងអស់ រើសចេញនូវសំណួរដែលដូចគ្នា រួចហើយបង្ហាញសំណួរផ្សេងៗទៅកាន់ថ្នាក់ទាំងមូល។

ដូចគ្នាទៅនឹងប៉ូស្ទ័ និង រូបភាព ផែនទីក៏មានប្រយោជន៍សម្រាប់ផ្តល់អ្វីមួយឱ្យសិស្សធ្វើ បើសិនជាពួកគេ បញ្ចប់មេរៀនមុនម៉ោង ឬក៏ បើសិនជាសិស្សមួយចំនួនបញ្ចប់កិច្ចការមុនអ្នកដទៃផងដែរ។

**ដំណាក់កាលបង្រៀនទី ៣.៥: បច្ចេកទេសបង្រៀនជាក់ស្តែងសម្រាប់អភិវឌ្ឍន៍បំនិនអាន ៤៥ នាទី**

**អំនានឮដោយគ្រូ និង សិស្ស**

**សម្ភារៈ** ប៉ូស្ទ័រដែលបង្ហាញពីបែបបទនៃការអានអក្សរ (ការអាន) សៀវភៅរឿង (មានរូបភាព) ដែលសមស្របសម្រាប់ថ្នាក់ទី១ និង ទី២

អ្នកសម្របសម្រួលនិយាយថាៈ គ្រូបង្រៀននៅបឋមសិក្សាជាច្រើន មានក្តីបារម្ភថាកុមារកម្ពុជាមានការអភិវឌ្ឍន៍បំនិនសរសេរ និង អានយឺតណាស់។ គ្រូដែលបង្រៀននៅថ្នាក់ខ្ពស់ត្អូញត្អែថាសិស្សដែលឡើងមកថ្នាក់របស់គាត់មានចំណេះដឹងអន់។ មានហេតុផលមួយក្នុងចំណោមហេតុផលផ្សេងៗគឺដោយសារ កុមារកម្ពុជាភាគច្រើនធំដឹងក្តីឡើងនៅក្នុងផ្ទះ ដែលមិនមានសៀវភៅច្រើន ទស្សនាវដ្តី និង សារព័ត៌មាន។ កុមារជាញឹកញាប់មិនបានឃើញបងប្អូនបង្កើត ឬ មនុស្សចាស់អានសៀវភៅ។ នេះមានន័យថា កុមារជាច្រើនមកសាលារៀនដោយពុំមានការយល់ដឹងផ្នែកមូលដ្ឋានអំពីអក្សរ ឬ ចំណេះដឹង ដែលមានសភាពខុសៗគ្នា និង គោលបំណងផ្សេងៗនៃប្រភេទអត្ថបទ។

អ្នកសម្របសម្រួលនិយាយថាៈ មុននឹងកុមារអាចអានដោយខ្លួនឯង គ្រូអាចជួយពួកគេរៀនក្បួនជាមូលដ្ឋានមួយចំនួនអំពីការអាន ដោយការបង្ហាញ និង និយាយអំពីពួកគេ។ ក្បួនទាំងអស់នេះ អ្នកអប់រំហៅថា **បែបបទនៃការអានអក្សរ** (conventions of print)។ បែបបទនៃការអានអក្សរមួយចំនួនមានលក្ខណៈជាក់ស្តែងណាស់ រហូតដល់គ្រូបង្រៀនអាចនឹងភ្លេចថាកុមារអាចនឹងមិនដឹងអំពីបែបបទនោះ។ ឧទាហរណ៍មួយចំនួនអំពីបែបបទនៃការអានអក្សរសម្រាប់ភាសាខ្មែរគឺ...

- ត្រូវអានអត្ថបទ តាមលំដាប់លំដោយទំព័រនៃសៀវភៅ
- ត្រូវចាប់ផ្តើមអានពីផ្នែកខាងលើនៃទំព័រ
- ត្រូវអានអត្ថបទពីឆ្វេងទៅស្តាំតាមបន្ទាត់នីមួយៗ
- ត្រូវអានដោយពុំមានការដកឃ្លាឡើយ នៅចន្លោះពាក្យជាច្រើន
- ត្រូវអានដោយមានការដកឃ្លានៅចន្លោះឃ្លា អនុប្រយោគ និងប្រយោគមួយចំនួន

បែបបទនៃការអានអក្សរ**មិន**មានលក្ខណៈដូចគ្នាទេ សម្រាប់ភាសាទាំងអស់។

អ្នកសម្របសម្រួលនិយាយថាៈ គ្រូបង្រៀនអាចជួយឱ្យសិស្សយល់ពីបែបបទនៃការអានអក្សរ និង អភិវឌ្ឍន៍បំនិនអានដោយការប្រើបច្ចេកទេសងាយៗមួយចំនួន។ គ្រូបង្រៀនគួរប្រើបច្ចេកទេសទាំងនេះ នៅពេលកំពុងអានអត្ថបទណាមួយទៅឱ្យ ឬ ជាមួយសិស្ស។ ភាគច្រើននៃបច្ចេកទេសទាំងនេះ មានលក្ខណៈសមស្របសម្រាប់សិស្សថ្នាក់ទី១-៣។ គ្រូបង្រៀនអាចប្រើប្រាស់បច្ចេកទេសខ្លះ ក្នុងចំណោម បច្ចេកទេសផ្សេងទៀត ដូចជា ការទស្សន៍ទាយ សម្រាប់គ្រប់កម្រិតថ្នាក់។

អ្នកសម្របសម្រួលសួរថ្នាក់ទាំងមូលៈ តើមានបច្ចេកទេសងាយៗអ្វីខ្លះដែលគ្រូបង្រៀនអាចប្រើនៅពេលអានអត្ថបទ/រឿងទៅ

កាន់សិស្សដែលអាចជួយពួកគេឱ្យរៀនអាន? អ្នកស្ម័គ្រចិត្តម្នាក់ឡើងសរសេរគំនិតនៅលើក្តារខៀន ក្នុងខណៈសិក្ខាកាមផ្សេងៗទៀតឆ្លើយ ។

ចម្លើយរំពឹងទុកៈ

- *មុននឹងគ្រូអាន គាត់បង្ហាញរូបភាព និង សួរសិស្សថាតើពួកគេអាចទស្សន៍ទាយថា អត្ថបទនេះនឹងនិយាយអំពីអ្វី ។*
- *គ្រូអានអត្ថបទមួយលើកសិន ដោយឱ្យសិស្សស្តាប់តែប៉ុណ្ណោះ*
- *បន្ទាប់មកគ្រូអានដោយកាន់សៀវភៅ ដូច្នេះសិស្សទាំងអស់អាចមើលឃើញ*
- *នៅពេលគ្រូអាន គាត់អានតាមអត្ថបទដោយយកម្រាមដៃដាក់លើកន្លែងអានពីឆ្វេងទៅស្តាំ*
- *នៅពេលគ្រូអាន គ្រូបង្ហាញពីរបៀបនៅពេលដល់ចុងបន្ទាត់មួយ ភ្នែក/ម្រាមដៃរបស់គាត់ត្រឡប់ទៅរកជួរបន្ទាប់ទៀត និងចាប់ពីឆ្វេងទៅ ស្តាំ*
- *គ្រូបង្រៀនប្រាប់សិស្សឱ្យធ្វើតាមដោយមើលអត្ថបទនៅក្នុងសៀវភៅរបស់ពួកគេ ដោយប្រើម្រាមដៃ ក្នុងពេលគ្រូអាន*
- *គ្រូបង្រៀនឈរនៅគ្រប់កន្លែងក្នុងបន្ទប់ដើម្បីត្រួតពិនិត្យមើល ថាតើកុមារកំពុងធ្វើតាមឬទេ*
- *គ្រូបង្រៀនបញ្ឈប់ការអានក្នុងខណៈពេលណាមួយៗ ហើយសួរសិស្សថាតើពួកគេអាចទស្សន៍ទាយពាក្យឬឃ្លាបន្ទាប់បានឬទេ តាមរយៈការយល់ដឹងអត្ថន័យនៃរឿង ។*

អ្នកសម្របសម្រួលហៅសិក្ខាកាមម្នាក់ឱ្យឡើងបង្ហាញពីបច្ចេកទេសនេះក្នុងខណៈពេលអានអត្ថបទរឿង ។

**ដំណាក់កាលបង្រៀនទី ៣.៦ៈ បច្ចេកទេសបង្រៀនជាក់ស្តែងសម្រាប់អភិវឌ្ឍន៍បំនិនអាន** **៦០ នាទី**

**ការអភិវឌ្ឍន៍ចំណេះដឹងរបស់កុមារអំពីរចនាសម្ព័ន្ធនៃអត្ថបទ "ពេញលេញ"**

**សម្ភារៈ** តារាងបង្ហាញពីសំណួររបស់គ្រូ និង លក្ខណៈនៃអត្ថបទពេញលេញ

អ្នកសម្របសម្រួលនិយាយថាៈ នៅក្នុងការបង្រៀនសរសេរ គ្រូភាគច្រើនផ្តោតអារម្មណ៍យ៉ាងខ្លាំងទៅលើអក្សរ និង ពាក្យច្រើនជាងទៅលើអត្ថបទទាំងមូល ។ ជាលទ្ធផលនោះគឺថា កុមារមិនមានឱកាសច្រើនដើម្បីគិតអំពីអត្ថន័យ និង អ្វីដែលបង្កើតជាអត្ថបទមួយ "ពេញលេញ" ។ វាធ្វើឱ្យកុមារជួបការលំបាកដើម្បីក្លាយជាអ្នកដែលមានជំនាញក្នុងការអាន និង ការសរសេរ បើសិនជាពួកគេពុំមានឱកាសគិតអំពីអត្ថបទទាំងមូល ។ ទោះបីជាកុមារតូច ក៏ពួកគេចេះវិភាគអត្ថបទទៅតាមរបៀបងាយណាមួយផងដែរ បើសិនជាគ្រូសួរសំណួរបានត្រឹមត្រូវ ។ កុមារនឹងទទួលបានអត្ថប្រយោជន៍យ៉ាងច្រើន នៅក្នុងឆ្នាំបន្ទាប់លើការយល់ដឹងទាំងអស់នេះ នៅពេលពួកគេចាប់ផ្តើមសរសេរអត្ថបទផ្ទាល់ខ្លួន ។

អ្នកសម្របសម្រួលនិយាយថាៈ នៅពេលគ្រូ និង សិស្សអានចប់ គ្រូបង្រៀនគួរសួរសំណួរដល់សិស្សអំពីអត្ថបទទាំងមូល ។

អ្នកសម្របសម្រួលសួរសិក្ខាកាមៈ *តើអ្នកអាចផ្តល់ឧទាហរណ៍ពីសំណួរមួយចំនួន ដែលគ្រូអាចសួរដើម្បីជួយសិស្សអភិវឌ្ឍន៍ការយល់ដឹងថាអ្វីជាអត្ថបទពេញលេញបានឬទេ?* អ្នកស្ម័គ្រចិត្តម្នាក់ឡើងសរសេរលើក្តារខៀន ក្នុងខណៈពេលសិក្ខាកាមផ្សេងទៀតផ្តល់ចម្លើយ ។

ចម្លើយរំពឹងទុក

- *តើនរណាជាតួអង្គសំខាន់នៅក្នុងរឿង?*
- *តើអ្វីបានកើតឡើងនៅក្នុងអត្ថបទ ( ព្រឹត្តិការណ៍សំខាន់) ?*
- *តើព្រឹត្តិការណ៍ក្នុងរឿងកើតឡើងនៅឯណា?*
- *តើព្រឹត្តិការណ៍ក្នុងរឿងកើតឡើងនៅពេលណា?*
- *តើរឿងនេះចាប់ផ្តើមដោយរបៀបណា?*
- *តើអ្វីបានកើតឡើងនៅពេលបន្ទាប់... (ឱ្យកុមារនិយាយរឿងឡើងវិញដោយប្រើពាក្យផ្ទាល់របស់ពួកគេ) ?*
- *តើអ្វីកើតឡើងនៅពេលបញ្ចប់រឿង?*

| **សំណួររបស់គ្រូបង្រៀន** | **លក្ខណៈនៃអត្ថបទពេញលេញ** |
|---|---|
| តើនរណាជាតួអង្គសំខាន់នៅក្នុងរឿង? | តួអង្គ |
| តើអ្វីបានកើតឡើងនៅក្នុងអត្ថបទ ( ព្រឹត្តិការណ៍សំខាន់) ? | ព្រឹត្តិការណ៍ |
| តើព្រឹត្តិការណ៍ក្នុងរឿងកើតឡើងនៅឯណា? | ទីកន្លែង |
| តើព្រឹត្តិការណ៍ក្នុងរឿងកើតឡើងនៅពេលណា? | ពេលវេលា |
| តើរឿងនេះចាប់ផ្តើមដោយរបៀបណា? | សេចក្តីផ្តើម |
| តើអ្វីបានកើតឡើងនៅពេលបន្ទាប់... (ឱ្យកុមារនិយាយរឿងឡើងវិញដោយប្រើពាក្យផ្ទាល់របស់ពួកគេ) ? | តួសេចក្តី សាច់រឿងទាំងមូល |
| តើអ្វីកើតឡើងនៅពេលបញ្ចប់រឿង? | សេចក្តីបញ្ចប់ |
| | |
| នៅក្នុងអត្ថបទរឿងនេះ តើអ្នកចូលចិត្តផ្នែកណា? ហេតុអ្វី? | គិតកម្រិតខ្ពស់ |
| តើតួអង្គណាមួយក្នុងរឿងដែលអ្នកចូលចិត្ត? | គិតកម្រិតខ្ពស់ |

អ្នកសម្របសម្រួលហៅអ្នកស្ម័គ្រចិត្តម្នាក់ឱ្យអានរឿងនៅក្នុងដំណាក់កាលបង្រៀនមុន ហើយសួរសំណួរទៅក្រុមធំអំពីរឿងនោះ... សិក្ខាកាមផ្សេងទៀតឆ្លើយ ។

**ដំណាក់កាលបង្រៀនទី ៣.៧៖ បច្ចេកទេសបង្រៀនជាក់ស្តែងសម្រាប់អភិវឌ្ឍន៍បំនិនសរសេរ ៤៥ នាទី**

**សំណេរដើម និង អត្ថបទចរចា**

**សម្ភារៈ** តារាងសង្ខេបពីលទ្ធផលនៃការស្រាវជ្រាវអំពីការសរសេរដែលល្អ

អ្នកសម្របសម្រួលនិយាយថាៈ មនុស្សមួយចំនួនដែលមិនបានធ្វើការនៅក្នុងសាលារៀនគិតថា"បំនិនសរសេរ" គឺមានលក្ខណៈដូចគ្នានឹង "បំនិនសរសេរដៃ"។ ពួកគេគិតថាបើសិនជា មនុស្សចេះតួអក្សរ ហើយអាចសរសេរអក្សរដោយប្រើខ្មៅដៃបាន នោះពួកគេចេះសរសេរហើយ។

អ្នកសម្របសម្រួលនិយាយថាៈ ជាការពិតណាស់ការរៀនសរសេរអក្សរ និង ពាក្យគឺជាផ្នែកមួយសំខាន់ណាស់នៅក្នុងការងាររបស់សិស្សនៅក្នុងថ្នាក់ទី១ ២ និង ទី៣។ ទោះបីជាយ៉ាងណាក៏ដោយ នៅថ្នាក់ទី៤ សិស្សគួរតែចាប់ផ្តើមអភិវឌ្ឍបំនិនផ្សេងទៀត ព្រមទាំងសមត្ថភាពសរសេរបានស្អាត និង ប្រកបបានត្រឹមត្រូវ។

អ្នកសម្រសម្រួលសួរៈ បើសិនជាការសរសេរបានល្អ ប្រសើរជាងការសរសេរដៃបានស្អាត និង ប្រកបបានត្រឹមត្រូវនោះ តើការសរសេរបានល្អនោះមានន័យដូចម្តេច? អ្នកសម្របសម្រួលផ្តល់ចំណិតក្រដាសទៅសិក្ខាកាមដើម្បីធ្វើការជាក្រុមដែលមានសមាជិក៥នាក់ ហើយព្យាយាមសរសេរនិយមន័យខ្លីមួយអំពី ការសរសេរល្អ។ ក្រុមទាំងឡាយឡើងបិទប័ណ្ណ និង តំណាងក្រុមឡើងអាន។

អ្នកសម្របសម្រួលនិយាយថាៈ អ្នកអប់រំជាច្រើនយល់ស្របថា **អ្នកនិពន្ធល្អគឺជាអ្នកដែលអាចបញ្ចូលអត្ថន័យបានច្បាស់លាស់ និង ប្រើប្រាស់អក្សរដោយសន្សំសំចៃ។**

អ្នកសម្របសម្រួលបិទតារាងនៅលើក្តារខៀនហើយនិយាយថាៈ មានការសិក្សាពីការសរសេរជាច្រើននៅក្នុងភាសាផ្សេងៗគ្នាលើពិភពលោកយើងនេះ។ ការសិក្សាទាំងអស់យល់ស្របថា

- មធ្យោបាយល្អដើម្បីក្លាយជាអ្នកសរសេរគឺត្រូវសរសេរអត្ថបទផ្ទាល់ខ្លួនឯង (ពោលគឺ ដោយការអនុវត្ត)
- ការចម្លងសំណេរពីអ្នកដទៃទៃមិនមែនជាមធ្យោបាយល្អបំផុតដើម្បីបង្កើនបំណិនសរសេរនោះទេ (លើកលែងតែកុមារដែលនៅក្មេងពេក និង មិនទាន់ហ្វឹកហាត់សរសេរដៃនៅឡើយ)
- ការសរសេរគឺជាដំណើរការមួយដែលអ្នកសរសេរត្រូវតែសរសេរអ្វីមួយជាច្រើនដង (សរសេរពង្រាងច្រើនដង) មុននឹងបានជាអត្ថបទពេញលេញមួយ។

- វាជាការល្អគឺត្រូវពិភាក្សាអត្ថបទសរសេរជាមួយអ្នកដទៃមុននឹងបញ្ចប់
- អត្ថបទទាំងឡាយត្រូវបែងចែកទៅជាច្រើនប្រភេទ ហើយប្រភេទនីមួយៗមានចរិកលក្ខណៈផ្ទាល់របស់វា
- សិស្សដែលបានយល់ពីរចនាសម្ព័ន្ធមូលដ្ឋាន និង លក្ខណៈប្រភេទផ្សេងៗនៃការសរសេរ គឺជាអ្នកសរសេរដ៏ល្អ

អ្នកសម្របសម្រួលនិយាយថាៈ វាជាការសំខាន់ចំពោះគ្រូបង្រៀនដែលត្រូវផ្តល់ឱកាសឱ្យសិស្ស ទោះបីជាកុមារតូចៗក៏ដោយ ឱ្យបង្កើតសំណេរដើមរបស់ខ្លួន។ នេះមានន័យថាការសរសេរមានផ្ទុកនូវគំនិតផ្ទាល់របស់កុមារ វាមិនមែនជាការចម្លងពីក្តារខៀន ឬ សៀវភៅទេ។ កុមារដែលសរសេរផ្ទាល់ខ្លួន នឹងលូតលាស់ឡើងដោយមានជំនឿចិត្ត ក្នុងខណៈដែលពួកគេអនុវត្ត... ប្រយោគមួយនឹងក្លាយទៅជាប្រយោគពីរ បន្ទាប់មកក្លាយទៅជាប្រយោគបី... នឹងបន្ទាប់មកទៀតក្លាយទៅជាកថាខណ្ឌមួយ...ចំនុចនីមួយៗក្លាយជាអត្ថបទពេញលេញ។ វាជាការសំខាន់ផងដែរថា គ្រូបង្រៀនត្រូវអនុញ្ញាតឱ្យកុមារមើលឧទាហរណ៍នៃសំណេរដើមរបស់គេដែលតាំងបង្ហាញនៅលើជញ្ជាំងថ្នាក់រៀន គៀបភ្ជាប់នឹងខ្សែរនៅខាងលើតុសិស្ស ឬ សរសេរបង្ហាញនៅលើក្តារខៀន។

អ្នកសម្របសម្រួលនិយាយថាៈ ប៉ុន្តែចំពោះកុមារដែលមិនទាន់ចេះសរសេរនៅឡើយ តើពួកគេអាចបង្កើតសំណេរដើមរបស់ខ្លួនដោយរបៀបណា? ពួកគេអាចធ្វើបាន តាមដំណើរការមួយដែលហៅថា "អត្ថបទចរចា"។ នេះមានន័យថា គ្រូបង្រៀន និងកុមារត្រូវពិភាក្សាគ្នាអំពីអ្វីដែលកុមារចង់និយាយ ហើយនៅពេលកុមារយល់ព្រម គ្រូបង្រៀនសរសេរឱ្យពួកគេ។ គ្រូបង្រៀន និងកុមារអានអត្ថបទនោះជាមួយគ្នា។ ទោះបីជាពួកគេមិនបានសរសេរដោយខ្លួនពួកគេក៏ដោយ កុមារមានអារម្មណ៍ជាកម្មសិទ្ធិទៅលើអត្ថបទ ពីព្រោះវាជាគំនិតរបស់ពួកគេ។ ដំណើរការដូចគ្នានេះ អាចប្រើប្រាស់រនៅពេលកុមារគូរគំនូរ។ គ្រូបង្រៀនអាចសួរពីអ្វីដែលកុមារចង់សរសេរនៅខាងក្រោមគំនូរ បន្ទាប់មកគ្រូសរសេរអ្វីដែលពួកគេនិយាយនោះ។

គ្រូបង្រៀនអាចប្រើប្រាស់វិធីចរចាអត្ថបទប្រកបដោយជោគជ័យបាន ជាមួយសិស្សថ្នាក់ខ្ពស់ដែលអាចពិភាក្សាក្នុងក្រុមនូវអ្វីដែលពួកគេនិយាយ (ការចរចា) បន្ទាប់មកសមាជិកម្នាក់អាចសរសេរគំនិតរបស់ក្រុមនោះ។

បន្ទាប់មកអ្នកសម្របសម្រួលធ្វើការបង្ហាញពីដំណើរការ ដោយការចរចាអត្ថបទជាមួយក្រុមមួយដែលមានអ្នកស្ម័គ្រចិត្ត៦នាក់ចំណែកអ្នកផ្សេងទៀតសង្កេតមើល។

**ដំណាក់កាលបង្រៀនទី ៣.៨ៈ បច្ចេកទេសបង្រៀនជាក់ស្តែងដើម្បីអភិវឌ្ឍន៍បំនិនសរសេរ ៤៥ នាទី**

**ដំណើរការសរសេរ (ការធ្វើពង្រាង និង ការប្រជុំពិភាក្សា- Drafting and Conferencing)**

**សម្ភារៈ**

អ្នកសម្របសម្រួលនិយាយថាៈ មានអ្នកសរសេរមួយចំនួនតូច ដែលអាចសរសេរអត្ថបទល្អឥតខ្ចោះក្នុងរយៈពេលតែមួយលើក។ ការសរសេរភាគច្រើនត្រូវឆ្លងកាត់ដំណើរការ**ពង្រាង**មួយ ពីរ ឬច្រើនមុននឹងអ្នកសរសេរពេញចិត្តនឹងអត្ថបទនោះ។ នៅពេល

បច្ចុប្បន្ននេះមានការងាយស្រួលណាស់ ដោយប្រើកុំព្យូទ័រជាអ្នកកែរតម្រូវ ដែលគេអាចធ្វើបានគ្រប់ពេលវេលា។ បើសរសេរដៃវាមានការលំបាកច្រើន ហើយមានភាពរញ៉េរញ៉ៃទៀតផង។ ការគូសខ្វែងចោល ការបញ្ចូលព័ត៌មានថ្មី និង ការកែតម្រូវផ្សេងទៀតគឺត្រូវធ្វើនៅលើក្រដាស ឬ ក្តារឆ្នួន ឬ លើក្តារខៀន។ ភាពជាអ្នកសរសេរមិនត្រូវរិះគន់ចំពោះពង្រាងដែលគ្មានសណ្តាប់ធ្នាប់នេះឡើយ-ការផ្លាស់ប្តូរច្រើនបង្ហាញថាអ្នកសរសេរយកចិត្តទុកដាក់ខ្លាំងអំពីការបង្កើត**ពង្រាងចុងក្រោយ**ដែលមានគុណភាពខ្ពស់។

អ្នកសម្របសម្រួលនិយាយថា: អ្នកសរសេរជាច្រើនទទួលបានផលប្រយោជន៍ពីការដែលឱ្យអ្នកផ្សេងអាន និង ផ្តល់នូវគំនិតយោបល់លើពង្រាងសំណេររបស់ពួកគេ។ ការធ្វើបែបនេះ គេហៅថា **ការប្រជុំពិភាក្សា**។ នៅក្នុងសន្និសិទប្រជុំ អ្នកដែលអានពង្រាងគួរផ្តោតជាសំខាន់ទៅលើអត្ថន័យ-តើវាច្បាស់លាស់ឬទេ? តើវាគួរឱ្យច្រឡំបល់ឬទេ? តើផ្នែកដែលល្អ អាចធ្វើឱ្យកាន់តែល្អថែមទៀតឬទេ? កំហុសនៅក្នុងការប្រកបមិនសំខាន់ទេ (ពីព្រោះវាមិនមែនជាពង្រាងចុងក្រោយ) នៅក្នុងការប្រជុំពិភាក្សា។ នៅក្នុង **ពង្រាងចុងក្រោយ** អត្ថន័យគួរតែមានលក្ខណៈច្បាស់លាស់ ហើយរាល់កំហុសទាំងឡាយ រួមមាន ការប្រកប និង សញ្ញាវណ្ណយុត្តិត្រូវកែតម្រូវ។

អ្នកសម្របសម្រួលនិយាយថា: ពង្រាងទាំងឡាយអាចធ្វើនៅលើក្រដាសចោលចាស់ៗ លើក្តារឆ្នួន ឬ លើក្តារខៀនតូច។ ការសរសេរនៅលើក្តារខៀនតូច អាចធ្វើការកែតម្រូវងាយជាង។ វាក៏មានលក្ខណៈប្រសើរផងដែរ បើសិនជាក្រុមតូចកំពុងធ្វើការរួមគ្នានៅលើអត្ថបទមួយ ពីព្រោះពួកគេទាំងអស់អាចនៅជុំគ្នា និង ពិនិត្យមើលអត្ថបទរួមគ្នា។

**ដំណាក់កាលបង្រៀនទី ៣.៩: ការផ្លាស់ប្តូរធាតុនៃអត្ថបទ-ការប្រើប្រាស់អត្ថបទជាក់ស្តែង (Authentic texts) ៤៥ នាទី**

**សម្ភារៈ ឯកសារទី១៥** អំពីប្រភពនៃអត្ថបទជាក់ស្តែង

**អត្ថបទជាក់ស្តែង (សម្រាប់សិស្សថ្នាក់ខ្ពស់)**

អ្នកសម្របសម្រួលនិយាយថា: សិស្សជាច្រើនគ្រាន់តែអានអត្ថបទដែលមាននៅក្នុងសៀវភៅសិក្សា ឬ នៅក្នុងសៀវភៅរឿងដែលបានពីបណ្ណាល័យប៉ុណ្ណោះ។ គ្រូបង្រៀនអាចជួយពង្រីកបទពិសោធន៍របស់កុមារក្នុងភាពជាអ្នកអាន ដោយបង្ហាញពួកគេនូវប្រភេទអត្ថបទផ្សេងទៀត។ អត្ថបទភាគច្រើនគឺជួបប្រទះនៅក្នុងជីវិតប្រចាំថ្ងៃ ប៉ុន្តែកម្រយកមកប្រើនៅក្នុងការសិក្សាណាស់។ អត្ថបទទូទៅបំផុតត្រូវបានគេប្រើនៅក្នុងការផ្សាយពាណិជ្ជកម្ម និង លើផលិតផល។ អត្ថបទទាំងនេះអាចមានលក្ខណៈងាយ (ប្រទេសរបស់ខ្ញុំ ស្រាបៀរខ្ញុំ) ឬ មានលក្ខណៈស្មុគ្រស្មាញ (ធាតុផ្សំគីមីនៅក្នុងកំប៉ុងភេសជ្ជៈ)។ ដូចគ្នានោះផងដែរ គេអាចអាន និង ស្វែងយល់ អត្ថន័យអត្ថបទទាំងអស់នេះនៅលើផ្ទៃកំប៉ុង និងគ្រូអាចសួរសំណួរលើកទឹកចិត្តឱ្យកុមារគិតអំពីមូលហេតុដែលគេសរសេរអត្ថបទទាំងនេះ (គោលបំណង) និង ថាតើគេសរសេរសម្រាប់នរណា (ទស្សនិកជន)។

អ្នកសម្របសម្រួលបែងចែកសិក្ខាកាមជាក្រុមតូចដើម្បីពិភាក្សា និង ធ្វើបញ្ជីពី អត្ថបទជាក់ស្តែង នៅក្នុងសហគមន៍ និង សាលារៀនរបស់ពួកគាត់។ នៅពេលពួកគាត់ធ្វើចប់ តំណាងក្រុមតាមក្រុមនីមួយៗឡើងរាយការណ៍អ្វីដែលបានរកឃើញ។

តំណាងក្រុមផ្សេងៗទៀតអាចបន្ថែមគំនិតដែលខុសប្លែកគ្នា ។

ចម្លើយរំពឹងទុក

| **អត្ថបទជាក់ស្តែង** | **ឧទាហរណ៍** | **គោលបំណង** | **ទស្សនិកជន** |
|---|---|---|---|
| ការផ្សាយពាណិជ្ជកម្ម | គ្រប់ផលិតផល | ដើម្បីលក់ផលិតផល | គ្រប់គ្នាដែលចង់ទិញផលិតផល |
| សេចក្តីណែនាំពីរបៀបប្រើ | ម៉ាស៊ីនចាក់វីស៊ីឌី | ជម្រាបជូន ការពារការខូចខាត | គ្រប់គ្នាដែលទិញ និង ប្រើប្រាស់ផលិតផល |
| រូបមន្តធ្វើម្ហូប | ផលិតផលអាហារ | បង្ហាញពីសេចក្តីណែនាំសម្រាប់ចម្អិន | គ្រប់គ្នាដែលចង់ចម្អិនអាហារនោះ |
| ព័ត៌មាន | ប៉ូស្ទ័រអំពីការបោះឆ្នោត | បញ្ចុះបញ្ចូលប្រជាជនឱ្យបោះឆ្នោតជូនគណបក្សណាមួយ | គ្រប់គ្នាដែលមានសិទ្ធិបោះឆ្នោត |
| ព័ត៌មាន | ប៉ូស្ទ័រយល់ដឹងពីសុខភាព | បង្ហាញពីរបៀបដែលធ្វើឱ្យមានសុខភាពល្អ ឬ ការប្រថុយគ្រោះថ្នាក់ | គ្រប់គ្នាដែលចេះអាន |
| ព័ត៌មាន | សញ្ញាបម្រាមតាមផ្លូវ | បង្កើនការពិចារណា ប្រាប់ដំណឹង បញ្ចុះបញ្ចូល | គ្រប់គ្នាដែលចេះអាន និង យល់ |
| | | | |

**ដំណាក់កាលបង្រៀនទី ៣.១០: ការបែងចែកកញ្ចប់សម្ភារៈ** **២០ នាទី**

**សម្ភារៈ** បញ្ជីសម្ភារ

អ្នកសម្របសម្រួលបែងចែកកាតាបដែលមានសម្ភារ ព្រមទាំងបញ្ជីសម្ភារដែលសិក្ខាកាមអាចគូសប្រៀបធៀបចំនួនសម្ភារ ។

**សរុប ៦ម៉ោង ១០ នាទី**

# កម្មវិធីគាំទ្រវិស័យអប់រំកុមារដែលរស់នៅតំបន់ដាច់ស្រយាល

## (អេស្កាប់)

EQUIP1
Educational Quality Improvement Program
Classrooms • Schools • Communities

## វគ្គបណ្តុះបណ្តាលបន្ថែមសម្រាប់គ្រូសហគមន៍

## រយៈពេល ៣ ថ្ងៃ

# ឯកសារសិក្ខាកាម

ខេត្តកំពង់ចាម ប្រទេសកម្ពុជា

ខែតុលា ឆ្នាំ២០០៦

# វគ្គបណ្តុះបណ្តាល៣ថ្ងៃសម្រាប់គ្រូសហគមន៍

## ខែតុលា ឆ្នាំ២០០៦

# ឯកសាររបស់សិក្ខាកាម

| លរ | ចំណងជើងឯកសារ | ទំព័រ |
|---|---|---|
| ១ | ផែនការបណ្តុះបណ្តាល និង តារាងពេលវេលា | |
| ២ | គំរូកិច្ចតែងការបង្រៀនដោយប្រើប្រាស់ប្លង់របស់ក្រសួងអប់រំ យុវជន និង កីឡា | |
| ៣ | ករណីសិក្សា អំពីមេរៀនចំនួនបី | |
| ៤ | តារាងវិភាគករណីសិក្សា | |
| ៥ | ដ្យាក្រាម/រូបថតអំពីសកម្មភាពសិក្សាក្រុមតូចពីរ | |
| ៦ | ការវាយតម្លៃ | |
| ៧ | ការឆ្លុះបញ្ចាំងរបស់គ្រូបង្រៀន | |
| ៨ | ដ្យាក្រាមតាក់សូណូមីអំពីឈ្មោះប្រទេស និង សត្វ | |
| ៩ | ករណីសិក្សាអំពីកម្រិតនៃការសួរសំណួរ និង ការគិត | |
| ១០ | សកម្មភាពសិក្សាពីរ និង សំណួរសម្រាប់វិភាគ | |
| ១១ | ការសួរសំណួរ និង ការគិតកម្រិតខ្ពស់ | |
| ១២ | ការប្រើកិច្ចការស្រាវជ្រាវដើម្បីជួយសិស្សឱ្យគិតកម្រិតខ្ពស់ | |
| ១៣ | ការបង្កើតភាសា-បរិស្ថានថ្នាក់រៀនសំបូរបែប | |
| ១៤ | គំនិតជាក់ស្តែងសម្រាប់អភិវឌ្ឍន៍បំនិនភាសាទាំងបួន | |
| ១៥ | អត្ថបទជាក់ស្តែងៈ ប្រភព ឧទាហរណ៍ គោលបំណង ទស្សនិកជន | |
| ១៦ | បញ្ជីសម្ភារ | |

ឯកសារទី១

ផែនការបណ្តុះបណ្តាល និង តារាងពេលវេលា

# ខ្លឹមសារសំខាន់ៗ

| **ថ្ងៃទី១ សេចក្តីផ្តើម និង ការឆ្លុះបញ្ចាំងការបង្រៀន** | **រយៈពេល** |
|---|---|
| ការស្វាគមន៍ និង ការបង្ហាញពីកម្មវិធីសិក្ខាសាលារយៈពេលបីថ្ងៃ | ១៥ នាទី |
| ការបង្ហាញពីស្ថានភាពនៃកម្មវិធីអេស្កាប់ | ២០ នាទី |
| ផែនការគាំទ្រគ្រូសហគមន៍ក្នុងកម្មវិធីអេស្កាប់សម្រាប់ឆ្នាំសិក្សា ២០០៦-២០០៧ | ១០ នាទី |
| ខ្លឹមសារសំខាន់ៗដែលគ្រូសហគមន៍លើកឡើងសម្រាប់វគ្គបណ្តុះបណ្តាលបន្ថែមរយៈពេល៣ថ្ងៃ...(១) ការធ្វើកិច្ចតែងការបង្រៀន (២) ការគ្រប់គ្រងថ្នាក់រៀន (៣) ការផលិតសម្ភារសម្រាប់ការបង្រៀន និង រៀន (៤) សម្ភារសម្រាប់ការបង្រៀន និង រៀន | ១៥ នាទី |
| ការធ្វើផែនការ ការបង្រៀន/រៀន ការឆ្លុះបញ្ចាំង (វដ្តបង្រៀន) | |
| ការធ្វើកិច្ចតែងការបង្រៀន...ធាតុនៃកិច្ចតែងការបង្រៀន និង កិច្ចតែងការគំរូរបស់ក្រសួងអប់រំ យុវជន និង កីឡា | ៦០ នាទី |
| ការរៀបចំសកម្មភាពសិក្សាក្រុមតូច | ១២០ នាទី |
| ការវាយតម្លៃសិស្ស...បែបជាដំណាក់ និង បែបបូកសរុប...យុទ្ធសាស្ត្រចម្រុះ | ៦០ នាទី |
| ការឆ្លុះបញ្ចាំងរបស់គ្រូ (ស្វ័យវាយតម្លៃ) ទៅលើការរីកចម្រើនតាមរយៈការផ្លាស់ប្តូរការអនុវត្តផ្ទាល់ | ៦០ នាទី |
| **សរុប** | **៦ម៉ោង** |
| **ថ្ងៃទី២ វិធីសាស្ត្រទំនាក់ទំនង-បំនិននៃការសួរសំណួរ និង ការគិតកម្រិតខ្ពស់** | |
| បំនិននៃការសួរសំណួរ...មូលហេតុដែលគ្រូបង្រៀនសួរសំណួរ | ១៥ នាទី |
| សំណួរតាក់សូណូមី: សំណួរចងចាំ យល់ដឹង រិះគិត (រួមទាំង សំណួរអនុវត្ត វិភាគ សំយោគ និង វាយតម្លៃ) | ៦០ នាទី |
| វចនាសម្ព័ន្ធនៃភាសា និង កម្រិតនៃការសួរសំណួរ | ៦០ នាទី |
| ការសរសេរសំណួរដែលមានកម្រិតខ្ពស់ជាង-កិច្ចការសិក្ខាកាម | ៦០ នាទី |
| ការគិតកម្រិតខ្ពស់-ការគិតដែលទាក់ទងនឹងសំណួរកម្រិតខ្ពស់ទាំង៤ | ៤៥ នាទី |
| សកម្មភាពសិក្សាពីរប្រភេទដែលជួយឱ្យសិស្សគិតកម្រិតខ្ពស់: ១. ការស្រាវជ្រាវ | ៦០ នាទី |
| សកម្មភាពសិក្សាពីរប្រភេទដែលជួយឱ្យសិស្សគិតកម្រិតខ្ពស់: ២. ការលេងល្បែងសិក្សា | ៦០ នាទី |
| **សរុប** | **៦ម៉ោង** |

| | |
|---|---|
| **ថ្ងៃទី៣ ការរៀបចំថ្នាក់កុមារមេត្រី ដើម្បីបង្កើនការអភិវឌ្ឍន៍ភាសា** | |
| ភាសាក្នុងកម្មវិធីសិក្សា...កុមាររៀនភាសា ការរៀនអំពីភាសា ការរៀនតាមរយៈការប្រើភាសាលើគ្រប់មុខវិជ្ជា | ៣០ នាទី |
| ការបង្កើតបរិស្ថានថ្នាក់កុមារមេត្រីដែលជំរុញការអភិវឌ្ឍន៍ភាសា | ៣០ នាទី |
| បច្ចេកទេសជាក់ស្តែងទី១: ការប្រើប៉ូស្ទ័រ ផែនទី រូបភាព...ភាសាផ្ទាល់មាត់ | ៤៥ នាទី |
| បច្ចេកទេសជាក់ស្តែងទី២: ធនាគារពាក្យ | ៤៥ នាទី |
| បច្ចេកទេសជាក់ស្តែងទី៣: ពាក្យសំណួរ "សំណួរអំពីថ្ងៃ" "សៀវភៅសំណួរ" | ៤៥ នាទី |
| បច្ចេកទេសជាក់ស្តែងទី៤: អំនានឮដើម្បីអភិវឌ្ឍន៍បំនិនស្តាប់ និង ការយល់ដឹងសាច់រឿង | ៤៥ នាទី |
| បច្ចេកទេសជាក់ស្តែងទី៥: ការលើកទឹកចិត្តឱ្យកុមារសរសេរ....អត្ថបទចចារ | ៤៥ នាទី |
| បច្ចេកទេសជាក់ស្តែងទី៦: ការប្រើប្រាស់អត្ថបទពិតជាក់ស្តែង បំនិនជីវិត ភាពមានទំនាក់ទំនងគ្នា | ៤៥ នាទី |
| លំដាប់លំដោយនៃការសរសេរសកម្មភាព ពីថ្នាក់ទី១-៦ (កិច្ចការ) ដែលបង្ហាញពីលក្ខណៈ ការរៀបចំលំដាប់លំដោយតាមកម្រិតថ្នាក់ | ៦០ នាទី |
| **ការបែងចែកកញ្ចប់សម្ភារ** | ២០ នាទី |
| **សរុប** | **៦ម៉ោង ០៥នាទី** |

## ឯកសារទី២

## គំរូកិច្ចតែងការបង្រៀនដោយប្រើប្រាស់ប្លង់របស់ក្រសួងអប់រំ យុវជន និង កីឡា

កិច្ចតែងការបង្រៀន

មុខវិជ្ជាភាសាខ្មែរ (លំហាត់សរសេរ ការសិក្សាកថាខណ្ឌគំរូ និង ការប្រមូលគំនិត)

ចំណងជើងមេរៀន: ការរៀបរាប់ពីមនុស្សល្អ មេរៀនទី១ ជំពូកទី២

រយៈពេល ២ម៉ោង

ថ្នាក់ទី៦

ដកស្រង់ពី: សៀវភៅសិស្សទំព័រទី ៥១ បោះពុម្ព ឆ្នាំ២០០១

សៀវភៅគ្រូទំព័រទី៧៧ បោះពុម្ព ឆ្នាំ២០០១

I. វត្ថុបំណង

ចំណេះដឹង: -សិស្សប្រាប់ពីសេចក្តីលំអិតរបស់អត្ថបទគំរូបានត្រឹមត្រូវតាមរយៈការអានអត្ថបទគំរូ និង សំណួររបស់គ្រូ។

ចំណេះដឹង: -សិស្សប្រមូលគំនិតទាក់ទងនឹងមនុស្សល្អម្នាក់បានត្រឹមត្រូវតាមរយៈសំណួររបស់គ្រូ និង ការផ្តល់គំនិតរួមគ្នា។

ឥរិយាបថ: -សិស្សខិតខំកសាងខ្លួនជាមនុស្សល្អតាមរយៈការអនុវត្តជាក់ស្តែង។

II. សម្ភារ

ចំពោះគ្រូ: សៀវភៅសិស្ស និង សៀវភៅគ្រូ ថ្នាក់ទី៦។

ចំពោះសិស្ស: សៀវភៅសិស្ស ថ្នាក់ទី៦។

III. ដំណើរការបង្រៀន

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| | ជំហានទី១ | |
| -ពិនិត្យអវត្តមាន និង អនាម័យសិស្ស។<br>-បំពេញតារាងវត្តមានលើក្តារខៀន។ | ជំហានទី២<br>១. កែកិច្ចការចាស់ | -ប្រធានថ្នាក់រាយការណ៍ពីវត្តមានសិស្ស |
| | ២. រំលឹកមេរៀនចាស់<br>-លំហាត់សរសេរ ការរៀបរាប់ពីបទពិសោធល្អក្នុងការសិក្សា | |
| គ្រូសួរ:<br>-តើលំហាត់សរសេរនៅក្នុងមេរៀនមុនឱ្យប្អូនសរសេរអំពីអ្វី? | ៣. ទំនាក់ទំនងមេរៀន | -សិស្សឆ្លើយនឹងសំណួររបស់គ្រូ។ |

| | | |
|---|---|---|
| | <u>ជំហានទី៣</u> | |
| -តើប្អូនធ្លាប់ពេញចិត្តមនុស្សបែបណា? | ១. ការសិក្សាអត្ថបទគំរូៈ មនុស្សដែលខ្ញុំពេញចិត្ត | -សិស្សឆ្លើយជាបុគ្គល។ |
| គ្រូឱ្យសិស្សម្នាក់ៗអានអត្ថបទគំរូក្នុងសៀវភៅសិស្សទំព័រ៩១ ដោយស្ងៀមស្ងាត់។ | | -សិស្សម្នាក់ៗអានអត្ថបទដោយស្ងៀមស្ងាត់។ |
| គ្រូសួរៈ | | |
| -តើមនុស្សដែលគេពេញចិត្តឈ្មោះអ្វី? | -ឈ្មោះចាន់ | -សិស្សឆ្លើយតាមខ្លឹមសារអត្ថបទ។ |
| -តើពូចាន់មានរូបរាងដូចម្តេច? | -ពិការជើង | |
| -តើពូចាន់ប្រកបរបរអ្វី? | -ធ្វើប៉ោត | |
| -ក្រៅពីរបរធ្វើប៉ោត តើគាត់ធ្វើអ្វីទៀត? | -ដាំបន្លែ និង ចិញ្ចឹមត្រី | |
| -តើគ្រួសារពូចាន់មានជីវភាពដូចម្តេច? | -ជីវភាពសមរម្យ | |
| -តើពូចាន់មានទំនាក់ទំនងដូចម្តេចជាមួយអ្នកជិតខាង និង អ្នកដទៃ? | -មានទំនាក់ទំនងល្អ | |
| -តើអ្នកជិតខាងមានទឹកចិត្តដូចម្តេចចំពោះគាត់? | -ស្រលាញ់រាប់អានគាត់ដូចបងប្អូន។ | |
| -តើគាត់អប់រំកូនដូចម្តេចខ្លះ? | -ខំរៀនសូត្រ ស្រលាញ់ពលកម្ម គោរព ស្រលាញ់ញាតិសន្តាន មានអធ្យាស្រ័យល្អ | |
| -តើកថាខណ្ឌទី១ គេរៀបរាប់ពីអ្វី? | -ពូចាន់ជាមនុស្សឧស្សាហ៍ព្យាយាមក្នុងការងារ | |
| -តើកថាខណ្ឌទី២ គេរៀបរាប់ពីអ្វី? | -ពូចាន់មានទំនាក់ទំនងល្អជាមួយអ្នកដទៃ និង គ្រប់គ្រងគ្រួសារបានល្អ។ | |
| -តើក្នុងអត្ថបទនេះគេរៀបរាប់អ្វីខ្លះពីមនុស្សដែលគេពេញចិត្ត? | -ឈ្មោះ រូបរាង មុខរបរ ជីវភាព ចរិតឧស្សាហ៍ព្យាយាម ទំនាក់ទំនងល្អ អធ្យាស្រ័យល្អ ការអត់អោន ការជួយធុរៈអ្នកដទៃ ការរាប់អានញាតិ ការអប់រំកូន។ | |
| | ២. ការប្រមូលគំនិត<br>លំហាត់ៈចូរអ្នកសរសេរកថាខណ្ឌរៀបរាប់ពីមនុស្សល្អម្នាក់ដែលអ្នកពេញចិត្ត។ | |

| | | |
|---|---|---|
| គ្រូឱ្យសិស្សអានលំហាត់ក្នុងសៀវភៅសិស្សទំព័រ៩១ ដោយស្ងៀមស្ងាត់ ។<br>គ្រូនាំសិស្សប្រមូលគំនិតដោយចោទសួរៈ<br>-ដើម្បីរៀបរាប់ពីមនុស្សល្អ តើអ្នកគិតថាអ្នកត្រូវរៀបរាប់ពីអ្វីខ្លះ? ឬ តើមនុស្សដែលអ្នកពេញចិត្តជាមនុស្សដូចម្តេច?<br>-គ្រូសរសេរគំនិតដែលសិស្សផ្តល់ជាហូរហែពីលើចុះមកក្រោម ។ | ឧទាហរណ៍ៈ គំនិតដែលសិស្សផ្តល់<br>-ចិត្តល្អ<br>-ជីវភាព<br>-មុខរបរ<br>-ឈ្មោះ<br>-គ្រប់គ្រងគ្រួសារល្អ<br>-ស្លូតបូត<br>-ឧស្សាហ៍<br>-ជួយអ្នកដទៃ<br>-រាប់អានញាតិ<br>-មាឌ<br>-ទៀងត្រង់<br>-ចេះអធ្យាស្រ័យ<br>-មានទំនាក់ទំនងល្អ<br>............................................. | -សិស្សម្នាក់ៗអានលំហាត់ដោយយកចិត្តទុកដាក់ ។<br>-សិស្សម្នាក់ៗផ្តល់គំនិតមួយជាបន្តបន្ទាប់ ។<br>-សិស្សម្នាក់ៗសង្កេតគំនិតដែលគ្រូបានសរសេរ ។ |
| -តើគំនិតទាំងនេះគ្រប់គ្រាន់ ឬ នៅ? តើមានគំនិតត្រូវបន្ថែមទៀត ឬទេ?<br>-ឱ្យសិស្សម្នាក់អានគំនិតទាំងអស់ឡើងវិញ? | | -សិស្សឆ្លើយតាមការជាក់ស្តែង ។<br>-សិស្សម្នាក់អានតាមការណែនាំរបស់គ្រូ ។ |
| - ដើម្បីរៀបរាប់ពីមនុស្ស តើគេត្រូវរៀបរាប់គំនិតធំៗអ្វីខ្លះ? | <u>ជំហានទី៤</u><br>-ឈ្មោះ<br>-រូបរាង<br>-អាកប្បកិរិយា ( ខ្ជិល ឧស្សាហ៍ ស្លូត...)<br>-សីលធម៌ ( អធ្យាស្រ័យ អត់អោនចិត្តល្អ រាប់អានអ្នកដទៃ... ។ | -សិស្សឆ្លើយ ។ |

| | | |
|---|---|---|
| -ចូរប្អូនកត់គំនិតទាំងអស់ដាក់ក្នុងក្រដាសព្រាង រួចយកទៅពិនិត្យមើលថាតើត្រូវដាក់គំនិតណាមុន? គំនិតណាបន្ទាប់? | <u>ជំហានទី៥</u> | -សិស្សធ្វើតាមលំណែនាំរបស់គ្រូ។ |

ឯកសារទី៣

## ករណីសិក្សាអំពីការបង្រៀនមេរៀនបី

នៅក្នុងមេរៀនទីមួយៗ គ្រូបង្រៀនមេរៀនគណិតវិទ្យាអំពីប្រភាគ។ បន្ទាប់ពីបង្ហាញប្រធានបទ គ្រូគូរដ្យាក្រាមមួយចំនួននៅលើក្តារខៀន និង ពន្យល់សិស្សអំពីរបៀបបូកប្រភាគដែលមានភាគបែងដូចគ្នា។ បន្ទាប់ពីគូរដ្យាក្រាម គ្រូបង្ហាញកុមារពីរបៀបដែលប្រភាគនៅក្នុងដ្យាក្រាមអាចសរសេរទៅជាលេខបាន ដោយដាក់ភាគយកនៅផ្នែកខាងលើ និង ភាគបែងនៅផ្នែកខាងក្រោម។

**ករណីសិក្សាទី១:** គ្រូឱ្យសិស្សធ្វើការជាក្រុមតូច។ គ្រូសរសេរលំហាត់ផលបូកប្រភាគចំនួន៥នៅលើក្តារខៀន ហើយឱ្យសិស្សធ្វើលំហាត់នោះនៅក្នុងសៀវភៅសរសេររៀងៗខ្លួន។ លំហាត់ទាំងនេះ កុមារត្រូវបូកប្រភាគដែលមានភាគបែងដូចគ្នា (ឧ.១/៤+២/៤=? ២/១០+៥/១០=?...)។ នៅពេលកុមារធ្វើលំហាត់ចប់ គ្រូប្រាប់ឱ្យពួកគេផ្តល់សៀវភៅកិច្ចការនោះទៅអ្នកផ្សេងទៀត។ បន្ទាប់មកគ្រូសរសេរចម្លើយត្រឹមត្រូវនៅលើក្តារខៀន ហើយប្រាប់សិស្សឱ្យកែកិច្ចការនោះ (ខុស និង ត្រូវ) ដោយដាក់ពិន្ទុខ្ពស់បំផុតស្មើ១០។ បន្ទាប់មកទៀត ពួកគេផ្តល់សៀវភៅកិច្ចការទៅម្ចាស់ដើមវិញ។ គ្រូបង្រៀនសួរសិស្សទាំងអស់ថា តើនរណាខ្លះបានពិន្ទុតិចជាង៥ ដោយឱ្យលើកដៃឡើង។ នៅពេលនោះសិស្សជាងពាក់កណ្តាលថ្នាក់លើកដៃឡើង។

ករណីសិក្សាទី២: គ្រូឱ្យសិស្សធ្វើការជាក្រុមតូច។ គ្រូឱ្យក្រុមនីមួយៗនូវក្រដាសមួយសន្លឹក។ គ្រូសរសេរលំហាត់ផលបូកប្រភាគចំនួន១០នៅលើក្តារខៀន ហើយឱ្យសិស្សជ្រើសរើសសមាជិកម្នាក់ៗពីក្រុមនីមួយៗដើម្បីកត់ត្រាលំហាត់នោះទៅក្នុងក្រដាស។ លំហាត់ផលបូកនោះតម្រូវឱ្យសិស្សបូកប្រភាគដែលមានភាគបែងដូចគ្នា (ឧ.១/៤+២/៤=? ២/១០+៥/១០=?.....)។ បន្ទាប់មកគ្រូប្រាប់ឱ្យសិស្សនៅក្នុងក្រុមនីមួយៗពិភាក្សាគ្នាដើម្បីរកចម្លើយ។ នៅពេលក្រុមនីមួយធ្វើលំហាត់ចប់ គ្រូបានឱ្យពួកគេផ្តល់ក្រដាសកិច្ចការទៅកាន់ក្រុមផ្សេង។ បន្ទាប់មកគ្រូសរសេរចម្លើយត្រឹមត្រូវនៅលើក្តារខៀន ហើយឱ្យក្រុមនីមួយៗកែកិច្ចការនោះព្រមទាំងដាក់ពិន្ទុដែលពិន្ទុខ្ពស់បំផុតស្មើ១០។ បន្ទាប់ពីកែហើយ ក្រុមនីមួយៗផ្តល់ក្រដាសកិច្ចការទៅឱ្យក្រុមដើមវិញ។ គ្រូសួរក្រុមទាំងអស់ថា តើក្រុមណា ខ្លះដែលបានពិន្ទុច្រើនជាង៥ ឱ្យលើកដៃឡើង។ នៅពេលនោះ ក្រុមទាំងអស់លើកដៃឡើង។

ករណីសិក្សាទី៣: គ្រូឱ្យសិស្សធ្វើការជាក្រុមតូច។ គ្រូឱ្យក្រុមនីមួយៗនូវក្រដាសមួយសន្លឹក។ គ្រូសរសេរលំហាត់ផលបូកចំនួន១០នៅលើក្តារខៀន ហើយឱ្យសិស្សជ្រើសរើសសមាជិកម្នាក់ៗពីក្រុមនីមួយៗដើម្បីកត់ត្រាលំហាត់នោះទៅក្នុងក្រដាស។ លំហាត់ផលបូកនោះតម្រូវឱ្យសិស្សបូកប្រភាគដែលមានភាគបែងដូចគ្នា (ឧ.១/៤+២/៤=? ២/១០+៥/១០=?.....)។ បន្ទាប់មកគ្រូប្រាប់ឱ្យសិស្សនៅក្នុងក្រុមនីមួយៗគូរដ្យាក្រាមសម្រាប់ផលបូកប្រភាគនីមួយៗ និង ពិភាក្សារួមគ្នាលើផលបូកប្រភាគផ្សេងទៀតដើម្បីរកចម្លើយ។ នៅពេលពួកគេធ្វើកិច្ចការចប់ គ្រូហៅអ្នកស្ម័គ្រចិត្តឱ្យឡើងមកគូរដ្យាក្រាមនៅលើក្តារខៀនព្រមទាំងពន្យល់ចម្លើយសម្រាប់លំហាត់ផលបូកទី១។ សិស្សផ្សេងៗទៀតឡើងមកគូរដ្យាក្រាម និង ធ្វើការពន្យល់រាល់លំហាត់ផលបូកនីមួយៗដូចគ្នា។ បន្ទាប់មកគ្រូឱ្យក្រុមនីមួយៗកែលំហាត់ក្នុងក្រុមរបស់ពួកគេ។ គ្រូសួរក្រុមទាំងអស់ថាតើក្រុមណាខ្លះដែលបានពិន្ទុច្រើនជាង៥ ឱ្យលើកដៃឡើង។ នៅពេលនោះសិស្សទាំងអស់នៅក្នុងក្រុមនីមួយៗលើកដៃឡើង។

ឯកសារទី៤

## តារាងវិភាគករណីសិក្សាទាំងបី

| ចំនុចប្រៀបធៀប | ករណីសិក្សាទី១ | ករណីសិក្សាទី២ | ករណីសិក្សាទី៣ |
|---|---|---|---|
| តើកិច្ចការនេះ តម្រូវឱ្យសិស្សគ្រាន់តែចងចាំប៉ុណ្ណោះ ឬក៏ តម្រូវឱ្យសិស្សធ្វើការគិតឱ្យបានច្រើន? | | | |
| តើកិច្ចការតម្រូវឱ្យមានសកម្មភាពក្រុម(ការពិភាក្សា ការយល់ស្របគ្នា) ឬទេ? | | | |
| តើក្រុមសិស្សត្រូវតែបង្កើតអ្វីមួយដើម្បីបំពេញកិច្ចការនោះឬទេ? | | | |
| តើសិស្សមានឱកាសពិភាក្សាកិច្ចការជាមួយសិស្សផ្សេងទៀតឬទេ? | | | |
| តើសិស្សមានឱកាសពន្យល់ការគិតរបស់ពួកគេទៅកាន់គ្រូ និង សិស្សទាំងអស់ឬទេ? | | | |
| តើមានចម្លើយត្រឹមត្រូវមួយសម្រាប់សកម្មភាពសិក្សានេះឬទេ? តើជានិច្ចកាលត្រូវមានចម្លើយតែមួយបែបនេះឬ? | | | |
| ចូររៀបលំដាប់លំដោយសកម្មភាពសិក្សាទៅតាមកម្រិតប្រសិទ្ធភាព (១ ២ និង ៣ )។ ចូរសរសេរហេតុផលចំពោះមូលហេតុរបស់អ្នក។ | | | |

ឯកសារទី៥

# រូបថតអំពីសកម្មភាពសិក្សាក្រុមតូចពីរ

## រូបថតទី១




## រូបថតទី២



ឯកសារទី៦

## ការវាយតម្លៃ

តើគ្រូបង្រៀនត្រូវធ្វើដោយរបៀបណាដើម្បីឱ្យដឹងថាការងាររបស់ខ្លួនមានប្រសិទ្ធភាពជាមួយកុមារ ឬ មិនមាននោះ? មធ្យោបាយមួយគឺដោយធ្វើការវាយតម្លៃ-គឺធ្វើការវាយតម្លៃពីអ្វីដែលកុមារបានរៀន និង ការវាយតម្លៃអំពីការងាររបស់ខ្លួន ក្នុងភាពជាគ្រូបង្រៀនម្នាក់។

តើគ្រូបង្រៀនអាចវាយតម្លៃការសិក្សារបស់កុមារតាមរបៀបអ្វីខ្លះ? មានមធ្យោបាយផ្សេងៗជាច្រើនដែលគ្រូនៅជុំវិញពិភពលោកធ្វើការវាយតម្លៃ ដែលរួមមាន

- ការសួរសំណួរ
- ការសង្កេតអាកប្បកិរិយារបស់កុមារ
- ការពិនិត្យកិច្ចការ (ការសរសេរ...) របស់កុមារ
- ការសួរដើម្បីឱ្យកុមារពន្យល់ពីអ្វីមួយ
- ការធ្វើតេស្តផ្ទាល់មាត់ និង ការចោទសួរ
- រៀបចំ និង កែតេស្ត/កិច្ចការសិស្ស

គ្រូបង្រៀនល្អធ្វើការវាយតម្លៃដោយប្រើប្រភេទមួយចំនួនខាងលើ ជាផ្នែកនៃទម្លាប់ការងារប្រចាំថ្ងៃដូចជា ការសួរសំណួរ ការសង្កេតអាកប្បកិរិយា និង ពិនិត្យមើលកិច្ចការរបស់សិស្ស។ ការវាយតម្លៃប្រភេទទាំងនេះគេហៅថា **ការវាយតម្លៃក្រៅផ្លូវការ** ពីព្រោះពួកគេមិនបានធ្វើផែនការ និង អាចកើតឡើងគ្រប់ពេលវេលា។ ការរៀបចំការដាក់ឱ្យសិស្សអនុវត្ត និង ការកែតេស្ត ជាធម្មតាគេហៅថា **ការវាយតម្លៃផ្លូវការ** ពីព្រោះពួកគេបានធ្វើផែនការដោយយកចិត្តទុកដាក់ និង រៀបចំជាសកម្មភាពពិសេសៗទៅតាមពេលវេលាជាក់លាក់ណាមួយក្នុងឆ្នាំសិក្សា។

ប្រភេទនៃការវាយតម្លៃមួយចំនួនត្រូវបានធ្វើនៅក្នុងកំឡុងវគ្គសិក្សា ដែលគេហៅថា **ការវាយតម្លៃជាដំណាក់ៗ**។ ការវាយតម្លៃប្រភេទផ្សេងៗទៀតគេធ្វើនៅចុងបញ្ចប់វគ្គសិក្សា ដែលគេហៅថា **ការវាយតម្លៃបូកសរុប**។ ការវាយតម្លៃជាដំណាក់ មានប្រយោជន៍ណាស់សម្រាប់គ្រូបង្រៀន និង កុមារ ពីព្រោះវាបង្ហាញពីបញ្ហា ឬ អ្វីមួយដែលកុមារកំពុងជួបប្រទះក្នុងការសិក្សា។ ដូចនេះគ្រូ និង កុមារអាចព្យាយាមដោះស្រាយបញ្ហានោះ។ បើសិនជាយើង យកតែការវាយតម្លៃបូកសរុប នោះវាអាចជាការយឺត ពេលក្នុងការជួយកុមារ។

រាល់ប្រភេទវាយតម្លៃទាំងអស់សុទ្ធតែមានប្រយោជន៍សម្រាប់គ្រូបង្រៀន ក្នុងការកសាងការយល់ដឹងរបស់គាត់អំពីដំណើរការនៃការសិក្សារបស់កុមារនីមួយៗក្នុងថ្នាក់រៀន។ កុមារទាំងអស់ត្រូវការការយកចិត្តទុកដាក់ ប៉ុន្តែមានកុមារជាច្រើនមាន ជំនឿចិត្ត និង ភាពឯករាជ្យ។ ពួកគេរៀនចេះបានឆាប់រហ័ស និង រីករាយក្នុងការធ្វើការដោយខ្លួនឯង ឬ ជាមួយកុមារផ្សេង ទៀត។

កុមារមួយចំនួនមិនអាចរៀនចេះដោយងាយស្រួលនោះទេ ហើយត្រូវការការគាំទ្រដឹកនាំច្រើន ព្រមទាំងការលើកទឹកចិត្តពីគ្រូរបស់គេទៀតផង។ គ្រូបង្រៀនអាចប្រើការវាយតម្លៃដើម្បីស្វែងរកកុមារណាខ្លះដែលត្រូវការជំនួយ និង ត្រូវជួយដោយ របៀបណាទើបមានប្រយោជន៍បំផុតដល់កុមារ។

នៅចុងឆ្នាំនីមួយៗ គ្រូផ្តល់អនុសាសន៍ ថាតើកុមារណាខ្លះត្រូវឡើងថ្នាក់ និង កុមារណាខ្លះត្រូវត្រួតថ្នាក់។ នេះគឺជាការសម្រេចចិត្តដ៏សំខាន់បំផុត។ កុមារណាដែលអាចគ្រប់គ្រងនៅថ្នាក់បន្ទាប់បានគួរតែឱ្យឡើងថ្នាក់ ពីព្រោះការរៀនត្រួតថ្នាក់គឺជា បុព្វហេតុចម្បងនៃការបោះបង់ពីសាលារៀន។ ប៉ុន្តែបើកុមារពិតជាមិនមានការយល់ដឹងពីការងារដែលខ្លួនបានធ្វើនៅក្នុងថ្នាក់ក្នុង ពេលបច្ចុប្បន្ននេះទេ គឺមិនមានសារៈប្រយោជន៍ក្នុងការឱ្យឡើងថ្នាក់ឡើយ ពីព្រោះពួកគេនឹងមិនអាចទទួលជោគជ័យលើការសិក្សានៅថ្នាក់ខ្ពស់ឡើយ។

គ្រូបង្រៀនដែលបានធ្វើការវាយតម្លៃក្រៅផ្លូវការ និង ការវាយតម្លៃជាដំណាក់ក្នុងកំឡុងឆ្នាំសិក្សារួចហើយ កុមារនឹងមានចំណេះល្អនិងអាចសម្រេចបានជោគជ័យ។

គ្រូបង្រៀនអាចនឹងធ្វើការបង្រៀនកែលំអកុមារទាំងនេះដើម្បីជួយពួកគេឱ្យអភិវឌ្ឍ បំនិនទាំងឡាយ។ គ្រូបង្រៀនគួរប្រើប្រាស់ចំណេះដឹងអំពីការសិក្សាដែលសម្រេចបានរបស់កុមារក្នុងកំឡុងឆ្នាំសិក្សា នៅពេលធ្វើការវាយតម្លៃការសិក្សារបស់កុមារនៅចុងឆ្នាំ។ **គ្រូបង្រៀនមិនគួរពឹងផ្អែកតែលទ្ធផលការសិក្សានៅចុងឆ្នាំដើម្បីធ្វើការសម្រេចចិត្តឱ្យឡើងថ្នាក់នោះទេ**។ ជួនកាលកុមារធ្វើតេស្តមិនទទួលបានពិន្ទុល្អទេ ទោះបីជាពួកគេមានបំនិនល្អក៏ដោយ។ ប្រហែល ជានៅពេលដែលពួកគេធ្វើតេស្ត ពួកគេមានអារម្មណ៍មិនល្អ (ឈឺ) ឬ ពួកគេមានអារម្មណ៍ភ័យ រំភើប ឬ ពួកគេមានកំហុសមួយ ចំនួនដោយការធ្វេសប្រហែស។ បើសិនជាគ្រូបង្រៀនបានដឹងពីការវាយតម្លៃផ្សេងទៀតថាការសិក្សារបស់កុមារមានលទ្ធផលល្អ នោះគ្រូអាចសម្រេចចិត្តឱ្យកុមារឡើងថ្នាក់បាន។ ពីព្រោះចំនុចនេះមានសារៈសំខាន់ណាស់សម្រាប់កុមារ និង គ្រួសារ។

## ឯកសារទី៧

## ការឆ្លុះបញ្ចាំងរបស់គ្រូបង្រៀន

ការឆ្លុះបញ្ចាំងគឺជាការអនុវត្តមួយដែលគ្រូល្អៗជាច្រើនធ្វើជាទម្លាប់ ។ វាមានន័យថា ពួកគេជាញឹកញាប់គិតអំពីដំណើរការសិស្សនៅក្នុងថ្នាក់ ថាតើពួកគេកំពុងធ្វើជាអ្នកសិក្សាមួយឬទេ ។ គ្រូប្រភេទនោះតែងតែសួរសំណួរខ្លួនឯងថា...

តើកុមារគ្រប់រូបរៀនបានចេះឬទេ?

តើកុមារណាខ្លះមានការតស៊ូ? តើអ្វីដែលជាបុព្វហេតុនៃការលំបាករបស់ពួកគេ?

តើអ្នកគ្រប់គ្នានៅក្នុងថ្នាក់ចូលចិត្តកម្មវិធីសិក្សាឬទេ?

តើកុមារទាំងអស់មករៀនទៀងទាត់ និង រីករាយនឹងអ្វីដែលពួកគេធ្វើឬទេ?

ជាធម្មតាតែងតែមានកុមារមួយចំនួនដែលត្រូវការយកចិត្តទុកដាក់បន្ថែម ។

ការឆ្លុះបញ្ចាំងរបស់គ្រូ គឺជាស្វ័យវាយតម្លៃ ។ គោលបំណងសំខាន់នៃការឆ្លុះបញ្ចាំងរបស់គ្រូបង្រៀនគឺ...

| |
|---|
| តើខ្ញុំអាចផ្លាស់ប្តូរការបង្រៀនអ្វីខ្លះដើម្បីឱ្យសិស្សនៅក្នុងថ្នាក់របស់ខ្ញុំមានការរីកចម្រើនឡើង? |

ចំនុចសំខាន់គឺស្ថិតនៅលើការផ្លាស់ប្តូរការអនុវត្តការបង្រៀនរបស់គ្រូ ដើម្បីបង្កើនលទ្ធផលការសិក្សាឱ្យប្រសើរឡើង ។

នៅពេលគ្រូបង្រៀនសម្រេចចិត្តថានឹងត្រូវធ្វើអ្វីមួយឱ្យមានលក្ខណៈខុសប្លែកពីមុន នោះគាត់នឹងធ្វើផែនការដើម្បីអនុវត្ត ។ គ្រូបង្រៀនអាចធ្វើផែនការរៀបចំសកម្មភាពសិក្សាក្រុមតូចឱ្យបានច្រើន (យ៉ាងហោចណាស់ម្តង ឬ ពីរក្នុងមួយសប្តាហ៍) ឬ ប្រមូល និង តាំងគំនូររបស់សិស្ស ។ នៅពេលគ្រូបង្រៀនបានសាកល្បងនូវគំនិតថ្មី គាត់គួរតែធ្វើការឆ្លុះបញ្ចាំងម្តងទៀត ហើយគិតថា តើវាមានដំណើរការឬទេ? តើកុមាររីករាយឬទេ? តើវាជួយឱ្យកុមារអភិវឌ្ឍន៍ការយល់ដឹង និង បំនិនឬទេ? បើសិនជាកុមារ ទទួលបានអត្ថប្រយោជន៍ពីគំនិតថ្មីនេះ នោះគ្រូអាចយកធ្វើជាចំណែកមួយក្នុងការអនុវត្តការបង្រៀនទៀងទាត់ ។ ជួនកាលនៅ ពេលគ្រូបង្រៀនព្យាយាមសាកល្បងគំនិតថ្មី គាត់នឹងគិតទៅដល់គំនិតថ្មីផ្សេងៗទៀត ។ ដូច្នេះគ្រូក៏អាចសាកល្បងនូវគំនិតទាំងនោះ ទៅតាមរបៀបដូចគ្នានេះផងដែរ ។

ដូច្នោះ គ្រូបង្រៀនបានចាប់ផ្តើមប្រើប្រាស់ដំណើរការដែលជួយពួកគាត់ក្នុងការផ្លាស់ប្តូរ និង រីកចម្រើន ។ ជំហានទាំងនេះមាន

- ឆ្លុះបញ្ចាំងពីបញ្ហាដែលកុមារជួបប្រទះនៅក្នុងថ្នាក់

- គិតពីរបៀបផ្លាស់ប្តូរការបង្រៀន ដែលជួយដល់ការដោះស្រាយបញ្ហា
- ធ្វើផែនការដើម្បីប្រើគំនិតថ្មីនោះ
- ប្រើប្រាស់គំនិតថ្មីនោះក្នុងការបង្រៀន
- គិតថាតើគំនិតមានជោគជ័យ ឬពុំមាន

ពេលខ្លះគេអាចគូសដំណើការខាងលើនេះជាដ្យាក្រាមមួយ ដែលឱ្យឈ្មោះថា **វដ្តនៃការឆ្លុះបញ្ចាំងការបង្រៀន។**




ហើយពេលខ្លះទៀតគេអាចគូសជាឬស័រ ដើម្បីបង្ហាញថាដំណើរការខាងលើមិនមែនមានតែមួយជុំ (វដ្ត)នេះទេ វាជាដំណើរការបន្តជានិរន្តរ៍ ដែលអាចក្លាយទៅជាផ្នែកមួយនៃទម្លាប់របស់គ្រូបង្រៀន។

ឯកសារទី៨

## ដ្យាក្រាមតាក់សូណូមីអំពីឈ្មោះប្រទេស និង សត្វ

<table>
<tr><td colspan="4">ក្រុមទី១</td></tr>
<tr><td colspan="4">ប្រភេទៈ ប្រទេសក្នុងពិភពលោក<br>កម្ពុជា បារាំង វៀតណាម ចិន អាឡឺម៉ង់ អ៊ីតាលី ម៉ាឡេស៊ី ជប៉ុន ហ្វីលីពីន ស្រីលង្កា ឥណ្ឌា អេស្ប៉ាញ ឡាវ អៀរឡង់</td></tr>
<tr><td colspan="2">ប្រភេទៈ អាស៊ី<br>កម្ពុជា វៀតណាម ចិន ម៉ាឡេស៊ី ជប៉ុន ហ្វីលីពីន ស្រីលង្កា ឥណ្ឌា ឡាវ</td><td colspan="2">ប្រភេទៈ អ៊ឺរ៉ុប<br>បារាំង អាឡឺម៉ង់ អ៊ីតាលី អេស្ប៉ាញ ចក្រភពអង់គ្លេស ស៊ុយអែត អៀរឡង់</td></tr>
<tr><td>ប្រភេទៈ អាស៊ាន<br>កម្ពុជា វៀតណាម ឡាវ ម៉ាឡេស៊ី ហ្វីលីពីន</td><td>ប្រភេទៈ មិនមែនអាស៊ាន<br>ចិន ជប៉ុន ស្រីលង្កា ឥណ្ឌា</td><td>ប្រភេទៈ អ៊ឺរ៉ុបទ្វីប<br>បារាំង អាឡឺម៉ង់ អ៊ីតាលី អេស្ប៉ាញ</td><td>ប្រភេទៈ តំបន់កោះនៅអ៊ឺរ៉ុប<br>ចក្រភពអង់គ្លេស ស៊ុយអែត អៀរឡង់</td></tr>
</table>

<table>
<tr><td colspan="4">ក្រុមទី២</td></tr>
<tr><td colspan="4">ប្រភេទៈ សត្វ<br>ឆ្កែ ឆ្មា បង្កង បង្គារ មាន់ ឆ្លាម ទា ខ្លា មឹក បាឡែន ខ្លាឃ្មុំ ឥន្ទ្រី ត្រីរ៉ស់ ត្រីក្រាញ់ ក្រៀល ក្ងាន ភេ ក្របី</td></tr>
<tr><td colspan="2">ប្រភេទៈ សត្វលើគោក<br>ឆ្កែ ឆ្មា មាន់ ខ្លា ខ្លាឃ្មុំ ឥន្ទ្រី ក្រៀល ក្ងាន អាកេងកង ក្របី</td><td colspan="2">ប្រភេទៈ សត្វក្នុងទឹក<br>បង្កង បង្គារ ឆ្លាម មឹក បាឡែន ត្រីរ៉ស់ ត្រីក្រាញ់ ភេ</td></tr>
<tr><td>ប្រភេទៈ ថនិកសត្វ<br>ឆ្កែ ឆ្មា ខ្លា ខ្លាឃ្មុំ ក្របី</td><td>ប្រភេទៈ បក្សី<br>មាន់ ទា ឥន្ទ្រី ក្រៀល ក្ងាន អាកេងកង</td><td>ប្រភេទៈ ទឹកសាប<br>បង្កង ត្រីរ៉ស់ ភេ ត្រីក្រាញ់</td><td>ប្រភេទៈ ទឹកប្រៃ<br>បង្គារ ឆ្លាម បាឡែន</td></tr>
</table>

## ឯកសារទី៩

## ករណីសិក្សាអំពីកម្រិតនៃការសួរសំណួរ និង ការរិះគិត

*គ្រូបង្រៀនអានអត្ថបទខ្លីនេះទៅកាន់សិស្សថ្នាក់ទី៥ ឬ សរសេរនៅលើចំណិតក្រដាស រួចហើយផ្តល់ឱ្យសិស្សក្នុងក្រុមតូច ដើម្បីអាន និង ពិភាក្សា...*

*មានម៉ូតូ ឡាន និង យានយន្តជាច្រើន កំពុងធ្វើចរាចរ នៅលើដងផ្លូវដីហុយ នៅខាង មុខផ្ទះរបស់ខ្ញុំ ដែលមានកុមារតូចៗ តែងតែលេងនៅទីនោះ ។ យានយន្តមួយចំនួនបើកក្នុង ល្បឿនលឿន ដែលបញ្ហានេះវាអាចបង្កឱ្យរងរបួសធ្ងន់ធ្ងរដល់កុមារ និង អាចបណ្តាលឱ្យ កុមារស្លាប់បាត់បង់ជីវិតទៀតផង ។ ខ្ញុំមិនអាចដឹងពីរបៀបដោះស្រាយបញ្ហានេះបានទេ ។*

ភាពជាគ្រូបង្រៀន តើអ្នកអាចប្រើប្រាស់សំណួរប្រភេទអ្វីដើម្បីសួរកុមារទៅលើអត្ថបទនេះ? មានឧទាហរណ៍មួយចំនួន សរសេរបង្ហាញនៅខាងក្រោម ។ ចូរអាន និង ពិភាក្សាជាមួយដៃគូ ហើយធ្វើការសម្រេចចិត្ត ថាតើសំណួរទាំងនេះស្ថិតនៅក្នុងសំណួរប្រភេទណា ( សំណួរចងចាំ សំណួរយល់ដឹង ឬ សំណួរគិតកម្រិតខ្ពស់)

| សំណួរ | ចម្លើយដែលអាចកើតឡើង | ប្រភេទសំណួរ |
|---|---|---|
| តើមានយានយន្តអ្វីខ្លះ កំពុងចរាចរនៅលើផ្លូវ? | | |
| តើផ្លូវនេះស្ថិតនៅឯណា? | | |
| ហេតុអ្វីកុមារត្រូវប្រឈមមុខនិង ការរងរបួស? | | |
| តើអ្នកគិតថា ហេតុអ្វីបានជាកុមារលេងនៅក្បែរផ្លូវ? | | |
| តើអ្វីទៅដែលអ្នកនិពន្ធព្រួយបារម្ភជាងគេបំផុត? | | |
| តើអ្នកគិតថា មនុស្សដែលរស់នៅក្បែរដងផ្លូវត្រូវធ្វើអ្វីខ្លះ ដើម្បីការពារកុមារកុំឱ្យរងរបួស ឬ អាចនឹងស្លាប់? | | |

ឯកសារទី១០

## សកម្មភាពសិក្សាពីរ និង សំណួរសម្រាប់វិភាគ

**ឧទាហរណ៍ទី១: មុខវិជ្ជាវិទ្យាសាស្ត្រ**

គ្រូបង្រៀន និង កូនសិស្សដាំគ្រាប់ផ្កាតូចៗនៅក្នុងសួនច្បារខាងក្រៅថ្នាក់រៀន។ សិស្សទាំងអស់ត្រូវបែងចែកជា៦ក្រុមតូច។ កុមារនៅក្នុងក្រុមត្រូវមានតួនាទីថែរក្សាផ្កានោះ (ស្រោចទឹក។ល។)។ កុមារសង្កេតមើលផ្កាចំនួនម្តងក្នុងមួយសប្តាហ៍ ហើយគ្រូបង្រៀនសួរពួកគេឱ្យរៀបរាប់ពីអ្វីដែលបានសង្កេតឃើញ។ នៅលើកដំបូងពុំឃើញមានអ្វីកើតឡើងទេ តែក្រោយមកកូនរុក្ខជាតិក៏ដុះឡើង។ បន្ទាប់ពីរយៈពេលមួយខែដែលកុមារបានដាំ គេឃើញផ្កាទីមួយដុះឡើង។ បន្ទាប់ពីរយៈពេលពីរខែផ្ការបស់ក្រុមមួយបានងាប់។ មួយថ្ងៃបន្ទាប់ពីផ្កានោះងាប់ គ្រូបង្រៀនធ្វើផែនការមេរៀនអំពីផ្កា និង សួនច្បារ។ គាត់បានផ្តល់សំណួរចំនួន៦ឱ្យកុមារដើម្បីពិភាក្សាជាក្រុមតូច។

| សំណួរ | ចម្លើយរំពឹងទុក | ប្រភេទសំណួរ |
|---|---|---|
| តើផ្កាមានឈ្មោះអ្វី? | | |
| តើយើងបានដាំគ្រាប់ផ្កានៅពេលណា? | | |
| តើផ្កាមានពណ៌អ្វី? | | |
| តើផ្កាត្រូវការអ្វីដើម្បីលូតលាស់? | | |
| ហេតុអ្វីបានជាផ្កាមួយចំនួនងាប់? | | |
| តើអ្នកគិតថា ហេតុអ្វីបានជាដើមផ្កាមួយចំនួនដុះលូតលាស់បានខ្ពស់ និង មានផ្កាច្រើនជាងដើមផ្កាផ្សេងៗទៀត? | | |

**ឧទាហរណ៍ទី២: មុខវិជ្ជាគណិតវិទ្យា**

គ្រូបង្រៀនផ្តល់គ្រាប់ឈើគូសចំនួន២០ទៅក្រុមតូចនីមួយៗនៅក្នុងថ្នាក់ទី២។ បន្ទាប់គ្រូប្រាប់ឱ្យសិស្សធ្វើការរួមគ្នា ដើម្បីយល់ស្រប គ្នាទៅនឹងសំណួរដែលគ្រូនឹងសួរពួកគេ...

| សំណួរ | ចម្លើយរំពឹងទុក | ប្រភេទសំណួរ |
|---|---|---|
| តើមានគ្រាប់ឈើគូសចំនួនប៉ុន្មាន? | | |
| ក្នុងចំណោមគ្រាប់ឈើគូសចំនួន២០នេះ បើយើងបែងចែកមួយក្រុម៥ដើម តើមានប៉ុន្មានក្រុម? | | |
| កុមារម្នាក់មានកូនឃ្លី២០ នៅក្នុងហោប៉ៅខោ។ ហោប៉ៅខោនោះមានប្រហោង ហើយនៅពេលវាមកដល់សាលារៀន ឃើញនៅសល់តែកូនឃ្លី១៣។ តើកូនឃ្លីបាត់ចំនួនប៉ុន្មាននៅតាមផ្លូវ? | | |
| កុមារម្នាក់មានកូនឃ្លី២០ ហើយវាបានឱ្យកូនឃ្លីទៅមិត្តរបស់វាម្នាក់ៗចំនួន៤។ តើកុមារនេះមានមិត្តប៉ុន្មាននាក់? | | |
| តើអ្នកអាចបង្កើតការ៉េឱ្យបានធំបំផុត ដោយរបៀបណា?<br>តើអ្នកនៅសល់គ្រាប់ឈើគូសឬទេ?<br>តើអ្នកអាចបង្កើតការ៉េដោយប្រើគ្រាប់ឈើគូសនោះឬទេ? | | |
| តើអ្នកអាចបង្កើតចតុកោណឱ្យបានវែងបំផុត ដោយប្រើគ្រាប់ឈើគូសចំនួន២០ បានដោយរបៀបណា?<br>តើអ្នកអាចបង្កើតចតុកោណដែលមានរូបផ្សេងៗទៀតឬទេ? | | |

## ឯកសារទី ១១
## ការសួរសំណួរ និង ការគិតកម្រិតខ្ពស់

ការសួរសំណួរគឺឧបករណ៍ដ៏សំខាន់របស់គ្រូបង្រៀន។ ការសួរសំណួរគឺជាបំនិនមួយដែលគ្រូបង្រៀនទាំងឡាយអាចធ្វើឱ្យរីកចម្រើនលូតលាស់បានតាមរយៈការអនុវត្ត។ គ្រូបង្រៀនអាចប្រើសំណួរដើម្បី

- ស្វែងរកអ្វីដែលកុមារបានដឹងរួចហើយពីប្រធានបទណាមួយ (មុននឹងចាប់ផ្តើមបង្រៀនពួកគេ)
- ត្រួតពិនិត្យការយល់ដឹងរបស់សិស្សអំពីអ្វីដែលពួកគេបាននឹងកំពុងរៀន
- អភិវឌ្ឍបំនិនស្តាប់ និង និយាយរបស់កុមារ
- ឱ្យកុមារពិភាក្សាគ្នាពីបទពិសោធន៍របស់ពួកគេ
- ឱ្យកុមារបង្ហាញពីគំនិត និង យោបល់របស់ពួកគេ
- ជួយធ្វើឱ្យការបង្រៀនមានលក្ខណៈកាន់តែសិស្សមជ្ឈមណ្ឌល

គ្រូបង្រៀនគួរលើកទឹកចិត្តឱ្យកុមារសួរសំណួរផងដែរ-អាចសួរទៅកាន់សិស្សផ្សេងៗទៀត និង គ្រូបង្រៀន។

គ្រូភាគច្រើននៅក្នុងប្រទេសកម្ពុជាបានដឹងរួចហើយថា មានប្រភេទសំណួរខុសៗគ្នាជាច្រើន។ ឧទាហរណ៍ គ្រូបង្រៀនសួរសំណួរដើម្បីស្វែងរក ថាតើពួកគេចងចាំអ្វីមួយដែលពួកគេបានរៀនរួចហើយនៅសាលារៀនឬទេ។ សំណួរទាំងនេះគេហៅថា **សំណួរចងចាំ**។ ប៉ុន្តែគ្រូបង្រៀនក៏អាចសួរសំណួរដែលកុមារមិនអាចឆ្លើយដោយប្រើការចងចាំផងដែរ។ សំណួរទាំងនេះគេហៅថា **សំណួររិះគិត** ពីព្រោះត្រូវតែគិតមុននឹងឆ្លើយសំណួរ។

សំណួរបែបរិះគិតមានច្រើនប្រភេទខុសៗគ្នា។ សំណួររិះគិតមួយចំនួនតម្រូវឱ្យសិស្សពិនិត្យមើល ស្តាប់ រួចហើយបង្ហាញថាពួកគេយល់តាមរយៈការពន្យល់។ សំណួរទាំងនេះគេហៅថា **សំណួរយល់ដឹង**។ សំណួរផ្សេងៗទៀត មានលក្ខណៈកាន់តែលំបាកឡើង ពីព្រោះវាមានលក្ខណៈពាក់ព័ន្ធច្រើន។ ដើម្បីឆ្លើយសំណួរទាំងអស់នេះ ជាដំបូងកុមារត្រូវយល់ដឹង បន្ទាប់មកធ្វើការគិតឱ្យបានច្រើនដើម្បីបង្កើតជាចម្លើយមួយ។ សំណួររិះគិតផ្សេងទៀតតម្រូវឱ្យ

- យល់ដឹងពីក្បួន ឬ ច្បាប់ និង អនុវត្តក្បួនច្បាប់ទាំងនេះទៅក្នុងស្ថានភាពមួយផ្សេងទៀត (សំណួរអនុវត្ត)
- ចងភ្ជាប់គំនិតពីររួមគ្នាដើម្បីបង្កើតជាគំនិតទី៣ថ្មីមួយ (សំណួរសំយោគ)
- ពិនិត្យមើលបណ្តុំគំនិត ឬ ព័ត៌មាន ហើយស្វែងរកភាពដូច/ស្រដៀងគ្នា និង ខុសគ្នា ព្រមទាំងទំនាក់ទំនងរបស់វា (សំណួរវិភាគ)
- ត្រួតពិនិត្យបណ្តុំគំនិត និង ព័ត៌មាន និងផ្តល់ជាគំនិតផ្ទាល់ខ្លួនអំពីវត្ថុនោះដែលទាក់ទងនឹងគុណភាព (ចំនួន ទំហំ ប្រសិទ្ធភាព តម្លៃ។ល។) (វាយតម្លៃ)

សំណួរប្រភេទទាំងអស់នេះគេហៅថា **សំណួរគិតកម្រិតខ្ពស់** ពីព្រោះគេត្រូវតែគិតដោយខ្លួនឯង និង បង្កើតគំនិត ឬ ព័ត៌មានថ្មីដើម្បីឆ្លើយ។

តារាងខាងក្រោមនេះបង្ហាញពីប្រភេទសំណួរមូលដ្ឋានចំនួនបី និង លក្ខណៈរបស់វា

| ប្រភេទសំណួរ | ដើម្បីឆ្លើយសំណួរ គេត្រូវ... | ប្រភេទនៃការគិត/សកម្មភាពដែលចាំបាច់ដើម្បីឆ្លើយ |
|---|---|---|
| ចងចាំ | **ចងចាំ និង និយាយ**អ្វីមួយដែលបានរៀនរួចហើយ | នឹកឃើញ ចងចាំ |
| យល់ដឹង | **យល់ដឹង និង ពន្យល់**ទៅតាមរបៀបផ្សេងនូវគំនិត ឬ ព័ត៌មានដែលបានផ្តល់រួចហើយ | យល់ដឹង ពន្យល់ |
| គិតកម្រិតខ្ពស់ | **យល់ដឹង និង បង្កើតគំនិតថ្មី** ចេញពីគំនិត ឬ ព័ត៌មានដែលមាន និង **អាចពន្យល់**គំនិតនោះបាន... | ប្រៀបធៀប បង្ហាញភាពផ្ទុយគ្នា បកស្រាយ អនុវត្ត ស្រាវជ្រាវរកហេតុផល វិភាគ ធ្វើសម្មតិកម្ម វាយតម្លៃ កំណត់អទិភាព |

គ្រូបង្រៀនអាចប្រើសំណួរទាំងបីប្រភេទនេះនៅគ្រប់កម្រិតថ្នាក់ទាំងអស់។ វាមិនមែនជាបញ្ហាទេដែលគ្រូប្រើសំណួរចងចាំ និង យល់ដឹង ពីព្រោះសំណួរទាំងនេះមានសារៈសំខាន់ណាស់ក្នុងការបង្កើតភាពរហ័ស ទោះបីជាកុមារមិនកំពុងរៀន ឬរៀនក៏ដោយ។ ទោះបីជាយ៉ាងណាក៏ដោយ នៅពេលកុមាររីកលូតលាស់ធំឡើងៗ វាជាការសំខាន់ណាស់ដែលគ្រូត្រូវផ្តល់សំណួរគិតកម្រិតខ្ពស់ឱ្យបានច្រើន និង បង្កើតសំណួរទាំងនេះប្រកបដោយភាពប្រកួតប្រជែង។ និយាយរួមសំណួរទាំងនេះតែងតែមានន័យ ថាជាការសួរកុមារដោយផ្ទាល់ ដើម្បីឱ្យពួកគេផ្តល់គំនិត និង ពន្យល់ហេតុផលទៅលើអ្វីមួយនោះ។

# ឯកសារទី១២

# ការប្រើប្រាស់កិច្ចការស្រាវជ្រាវដើម្បីជួយកុមារឱ្យគិតកម្រិតខ្ពស់

| ថ្នាក់ទី | កិច្ចការស្រាវជ្រាវ | សំណួរស្រាវជ្រាវ ដំណើរការ និងសំណួរគិតកម្រិតខ្ពស់ |
|---|---|---|
| ១ | ការស្រាវជ្រាវពីអាហារពេលព្រឹក | តើយើងបានអ្វីបរិភោគសម្រាប់អាហារពេលព្រឹកកាលពីព្រឹកមិញ? កុមារបង្កើតជាក្រុមទៅតាមប្រភេទអាហារ ដែលពួកគេបរិភោគកាលពីព្រឹក (បាយ មី គ្មាន ។ល។)។ អ្នកដឹកនាំក្រុមរាប់ក្រុមរបស់ពួកគេ។ កុមារសរសេរចំនួនក្រុមនីមួយៗនៅលើក្តារខៀន។ គ្រូបង្រៀនសួរសំណួរបន្ថែម...អាហារដែលពេញនិយមបំផុត ។ល។<br><br>តើយើងបានរៀនអ្វីខ្លះពីការសិក្សាស្រាវជ្រាវរបស់ពួកយើង?<br>• កុមារភាគច្រើននៅក្នុងថ្នាក់បរិភោគបាយកកនៅពេលព្រឹក<br>• កុមារមួយចំនួនបរិភោគមី<br>• កុមារមួយចំនួនទៀតមិនបរិភោគអ្វីទេនៅពេលព្រឹក មុនមកមកសាលារៀន |
| ៣ | ការស្រាវជ្រាវពីកូនរុក្ខជាតិ | **តើប្រភេទរុក្ខជាតិដែលមានផ្កាអ្វីខ្លះដែលដាំនៅផ្ទះរបស់ពួកយើង?** សម្រាប់កិច្ចការធ្វើនៅផ្ទះ កុមារទាំងអស់ត្រូវនាំយកឧទាហរណ៍មួយនៃផ្កា និង ស្លឹកពីកូនរុក្ខជាតិ ដែលដុះនៅក្បែរ ឬ ក្នុងផ្ទះ។ នៅឯសាលារៀនពួកគេជួបជុំជាក្រុមដើម្បីពិនិត្យមើល រាប់ និង ប្រាប់ឈ្មោះ រាល់ផ្កាដែលសមាជិកក្រុមនាំយកមក។ ក្រុមនីមួយបង្ហាញលទ្ធផលរបស់ខ្លួន។<br><br>តើយើងបានរៀនអ្វីខ្លះពីការសិក្សាស្រាវជ្រាវរបស់ពួកយើង?<br>• សិស្សជាច្រើនដាំផ្កាស្មៃរឿង<br>• សិស្សជាច្រើនចូលចិត្តផ្កាពណ៌លឿង និង ក្រហម<br>• យើងបានដឹងថា មានផ្កាពីរប្រភេទដែលគេមិនស្គាល់ឈ្មោះ |
| ៥ | ការស្រាវជ្រាវពីចរាចរ | តើផ្លូវនៅក្រៅរបងសាលារៀនរបស់ មានភាពមមាញឹកយ៉ាងណា? តើឡានធំនិងកូនឡានបន្ថយល្បឿនឬទេ នៅពេលឆ្លងកាត់សាលារៀន? **បើសិនជាសាលារៀននៅជាប់នឹងផ្លូវដែលមានចរាចរមមាញឹក សិស្ស** |

| | | |
|---|---|---|
| | | **អាចរាប់ និង ធ្វើចំណាត់ថ្នាក់ប្រភេទឡាន (ឡានក្រុង ឡានទីសាន់ កូនឡាន ម៉ូតូ រម៉ក រទេះគោ កង់ ។ល។ ដែលឆ្លងកាត់សាលារៀនរវាង ម៉ោង៧ និង ម៉ោង៧:៣០នាទី។ សិស្សអាចធ្វើកំណត់សម្គាល់អំពីឡាន ធំ និង ឡានតូចដែលបើកក្នុងល្បឿនលឿនផងដែរ។**<br><br>តើយើងបានរៀនអ្វីខ្លះពីការសិក្សាស្រាវជ្រាវរបស់ពួកយើង?<br>• ឡានធំចំនួន៣០ និង កូនឡាន៦០ បានឆ្លងកាត់ក្នុងរយៈពេល ៣០នាទី<br>• យានយន្តមួយចំនួនបើកបរយ៉ាងលឿន។ ចំនួនពាក់កណ្តាល នៃឡានធំ និង ឡានតូចមិនបានបន្ថយល្បឿនទេនៅពេលបើក បរឆ្លងកាត់សាលារៀន។<br>• យើងគួរបង្កើតផ្លាកសញ្ញាថ្មី និងមានទំហំធំ ជាសញ្ញាឱ្យ យានយន្តបន្ថយល្បឿន ដើម្បីឱ្យមានសុវត្ថិភាពដល់កុមារនៅ ពេលចូលសាលារៀន។ |

## ឯកសារទី១៣

## ការបង្កើតភាសា-បរិស្ថានបន្ទប់រៀនសំបូរបែប

*គ្រូបង្រៀនគឺជាអ្នកគ្រប់គ្រងថ្នាក់រៀន។ ការទទួលខុសត្រូវរបស់គ្រូបង្រៀនគឺធ្វើការជាមួយសិស្ស ដើម្បីបង្កើតបរិស្ថាន "សំបូរបែប" សម្រាប់ការសិក្សា។ នេះមានន័យថាបន្ទប់រៀនគួរមានផាសុខភាព (ស្អាត) ទាក់ទាញទឹកចិត្ត និង ជាកន្លែងជំរុញឱ្យមានការរៀនសូត្រ។ គោលបំណងគឺចង់ឱ្យកុមារមានការសប្បាយរីករាយមកសាលារៀនជារៀងរាល់ថ្ងៃ និង អាចស្វែងរកអ្វីៗដែលថ្មី ដើម្បីមើល និង ស្រាវជ្រាវ។*

បរិស្ថាន "សំបូរបែប" មិនមែនមានន័យថា គ្រូបង្រៀនត្រូវតែចំណាយលុយច្រើនទៅលើការតុបតែងនោះទេ។ បន្ទប់រៀនគួរមានសម្ភារៈដែលជំរុញការសិក្សា "សំបូរបែប"។ សម្ភារៈមួយចំនួនអាចទិញដោយប្រើប្រាក់ PAP (ឧ.តារាងអក្ខរក្រម តារាងចំនួន ផែនទី ។ល។)។ សម្ភារមួយចំនួនទៀតអាចផ្តល់ដោយក្រសួងអប់រំ យុវជន និង កីឡា ឬ តាមរយៈកម្មវិធីផ្សេងៗរបស់រដ្ឋាភិបាល (ឧ. អេស្កាប់ ការអប់រំពីមីន ហ៊ីវ/អេដស៍ អាហាររូបត្ថម្ភ ការអប់រំសម្រាប់ទាំងអស់គ្នា ។ល។) និង សម្ភារផ្សេងៗទៀតអាចរៀបចំដោយគ្រូបង្រៀន និង សិស្ស។ សម្ភារទាំងនេះរួមមាន

- ឧទាហរណ៍ ឬ កាតាំងបង្ហាញការសរសេររបស់សិស្ស គំនូរ ឬ ហត្ថកម្ម
- ការងារដែលផលិតនៅក្នុងមូលដ្ឋាន និង គ្រឿងសម្ភារផ្ទះបាយ (សំណាញ់ ឧបករណ៍ផ្សេងៗ កន្ត្រក...)
- សម្ភារពីបរិស្ថានដូចជា ការបង្ហាញពីស្លឹកឈើ ផ្កា សត្វល្អិត...
- ការពិសោធន៍ងាយៗដើម្បីឱ្យកុមារសង្កេត និង ចងក្រងជាឯកសារ (ការបណ្តុះគ្រាប់ ឬ ការដាំកូនរុក្ខជាតិនៅក្នុងទឹក និង ក្នុងផើង កូនក្អុក សួនសត្វល្អិត ផ្លែឈើដែលពុកផុយ...)

គ្រូបង្រៀនអាចស្វែងរកធនធានគ្រប់ទីកន្លែង។ ទស្សនាវដ្តី និង កាសែតចាស់ៗ ដែលសម្ភារនេះ តែងតែជាការចាប់អារម្មណ៍មួយ។ តារាងប៉ូស្ទ័រដែលផុតកាលបរិច្ឆេទ ឬ ឈប់ប្រើប្រាស់របស់ការប្រជុំ និង ព្រឹត្តិការណ៍ ឬ យុទ្ធនាការបង្កើនការយល់ដឹងរបស់រដ្ឋាភិបាល ដែលមានរូបភាព និង អត្ថបទពិតជាក់ស្តែង គួរឱ្យចាប់អារម្មណ៍ សម្រាប់យកមក ធ្វើការពិភាក្សា និង ការវិភាគ។ គ្រូបង្រៀនអាចធ្វើការជាមួយសិស្ស ដើម្បីបន្ថែមតម្លៃទៅលើតារាងផ្សេងៗ និង ប៉ូស្ទ័រចាស់ៗ ដោយការដាក់ស្លាកដាក់ចំណងជើង ។ល។

គ្រូបង្រៀន និងសិស្សមិនគួររៀបចំតាំងបង្ហាញ រួចហើយបំភ្លេចចោលសម្ភារនោះទេ។ សម្ភារទាំងនោះអាចប្រើប្រាស់សម្រាប់ការបង្រៀន និង រៀន នៅក្នុងមេរៀនទាំងឡាយ។ សម្ភារទាំងនេះគួរតែមានការផ្លាស់ប្តូរនៅពេលតាំងបានរយៈពេលមួយ ឬ ពីរខែ ដើម្បីរក្សាចំណាប់អារម្មណ៍របស់សិស្ស។

## ឯកសារទី១៤
## គំនិតជាក់ស្តែងសម្រាប់អភិវឌ្ឍបំនិនភាសា-ស្តាប់ និយាយ អាន និង សរសេរ

### គំនិតបង្រៀនទី១: ការប្រើប្រាស់ប៉ូស្ទ័រ/រូបភាព

ប៉ូស្ទ័រដែលមានរូបភាព និង/ឬអត្ថបទគឺជាសម្ភារបង្រៀនដ៏មានប្រយោជន៍។ វាមានការងាយស្រួល ដល់គ្រូបង្រៀនក្នុងការសួរសំណួរអំពីសម្ភារនេះ ដែលជាឱកាសមួយសម្រាប់កុមារអនុវត្តបំនិនស្តាប់ និង និយាយ។ ចំពោះសំណួរគ្រូអាចសួរបានគ្រប់កម្រិត ដូចឧទាហរណ៍បង្ហាញជូនខាងក្រោម...

| ឧទាហរណ៍សំណួរ | ឧទាហរណ៍ចម្លើយ | កម្រិតសំណួរ |
|---|---|---|
| តើអ្នកឃើញអ្វីខ្លះនៅក្នុងរូបភាព | ខ្ញុំអាចមើលឃើញ... | ចងចាំ |
| តើប៉ូស្ទ័រនេះបង្ហាញពីអ្វី? | បង្ហាញពី... | យល់ដឹង |
| តើអ្នកគិតថាហេតុអ្វី...? | ខ្ញុំគិតថា...ពីព្រោះ... | គិតកម្រិតខ្ពស់ |
| តើអ្វីដែលអ្នកចូលចិត្តបំផុតអំពី...? | ខ្ញុំចូលចិត្ត...ពីព្រោះ... | គិតកម្រិតខ្ពស់ |

គ្រូបង្រៀនក៏អាចប្រើប៉ូស្ទ័រ សម្រាប់ល្បែងសិក្សាដូចជា

- តើអ្នកអាចមើលឃើញអ្វីមួយនៅក្នុងប៉ូស្ទ័រដែលចាប់ផ្តើមដោយអក្សរ...?
- តើអ្នកអាចបិទស្លាកនេះនៅលើកន្លែងដែលត្រឹមត្រូវនៅលើប៉ូស្ទ័របានឬទេ?
- តើអ្នកអាចមើលឃើញវត្ថុអ្វីខ្លះដែលធំបំផុតចំនួន៥នៅក្នុងប៉ូស្ទ័រ? ចូរដាក់ចំនួន ១ ២ ៣ ៤ និង ៥ នៅលើវត្ថុដែលអ្នករកឃើញ។
- តើអ្នកអាចរកឃើញវត្ថុចំនួនប៉ុន្មាននៅក្នុងប៉ុស្ទ័រដែលមានពណ៌បៃតង/ក្រហម/ស...?

ល្បែងទាំងអស់នេះគឺមានប្រយោជន៍សម្រាប់ផ្តល់អ្វីមួយឱ្យសិស្សធ្វើ បើសិនជាពួក បញ្ចប់មេរៀនមុនម៉ោង ឬ បើសិនជាសិស្សមួយចំនួនបញ្ចប់កិច្ចការមុនអ្នកដទៃ។

### គំនិតបង្រៀនទី២: ការប្រើប្រាស់ផែនទី

ផែនទីគឺជាសម្ភារបង្រៀនដែលមានប្រយោជន៍ណាស់។ គ្រូបង្រៀនអាចប្រើប្រាស់ផែនទីជាប្រភពធនធានសម្រាប់ការសិក្សារបស់សិស្ស ក្នុងមុខវិជ្ជាភាសា គណិត និង សិក្សាសង្គម។ ក្នុងខណៈពេលដែលសិស្សលូតលាស់ធំឡើង១ ការយល់ឃើញរបស់ពួកគេក៏រីកលូតលាស់ផងដែរ។ នៅក្នុងថ្នាក់ទី១ កុមារផ្តោតទៅលើខ្លួនឯង គ្រួសារ និង លំនៅដ្ឋានរបស់ពួកគេ។ នៅថ្នាក់ទី២

និង ទី៣ ពួកគេចាប់ផ្តើមគិត និង រៀនពីភូមិ ឃុំ និង អាចរហូតដល់ខេត្តរបស់ពួកគេ។ នៅក្នុងថ្នាក់កម្រិតខ្ពស់ជាងនេះ ពួកគេរៀនអំពីខេត្ត ប្រទេស តំបន់ របស់ពួកគេ និង ពិភពលោក។

| ថ្នាក់ទី | សិស្សផ្តោតទៅលើ | ផែនទី |
|---|---|---|
| ១ | ផ្ទះរបស់ខ្ញុំ សាលារៀនរបស់ខ្ញុំ ការធ្វើដំណើរទៅសាលារៀន | បន្ទប់រៀន |
| ២ | ភូមិរបស់ខ្ញុំ ឃុំរបស់ខ្ញុំ | តំបន់នៅក្នុងមូលដ្ឋាន ប្រទេសកម្ពុជា |
| ៣ | ឃុំរបស់ខ្ញុំ ខេត្តរបស់ខ្ញុំ | ខេត្ត ប្រទេសកម្ពុជា |
| ៤ | ខេត្តរបស់ខ្ញុំ ប្រទេសរបស់ខ្ញុំ | ប្រទេសកម្ពុជា ឬ អាស៊ីអាគ្នេយ៍ |
| ៥ | ប្រទេសរបស់ខ្ញុំ តំបន់របស់ខ្ញុំ ពិភពលោក | អាស៊ីអាគ្នេយ៍ ពិភពលោក |
| ៦ | ពិភពលោក | ពិភពលោក |

ដូចគ្នាទៅនឹងប៉ូស្ទ័ និង រូបភាព ផែនទីក៏មានប្រយោជន៍សម្រាប់ផ្តល់អ្វីមួយឱ្យសិស្សធ្វើ បើសិនជាពួកគេបញ្ចប់មេរៀនមុនម៉ោង ឬ បើសិនជាសិស្សមួយចំនួនបញ្ចប់កិច្ចការមុនអ្នកដទៃផងដែរ។

**គំនិតបង្រៀនទី៣: អំណានឮ និង ការបង្រៀនពីបែបបទនៃការអានអក្សរ (Conventions of print)**

*គ្រូបង្រៀននៅបឋមសិក្សាជាច្រើន មានក្តីបារម្ភថាកុមារកម្ពុជាមានការអភិវឌ្ឍន៍បំនិនសរសេរ និង អានយឺតណាស់។ គ្រូដែលបង្រៀននៅថ្នាក់ខ្ពស់តួញត្អែថាសិស្សដែលឡើងមកថ្នាក់របស់គាត់មានចំណេះដឹងអន់។ មានហេតុផលមួយក្នុងចំណោមហេតុផលផ្សេងៗគឺដោយសារ កុមារកម្ពុជាភាគច្រើនធំដឹងក្តីឡើងនៅក្នុងផ្ទះ ដែលមិនមានសៀវភៅ ទស្សនាវដ្តី និង សារព័ត៌មានច្រើន។ កុមារជាញឹកញាប់មិនបានឃើញបងប្អូនបង្កើត ឬ មនុស្សចាស់អានសៀវភៅទេ។ នេះមានន័យថា កុមារជាច្រើនមកសាលារៀនដោយពុំមានការយល់ដឹងផ្នែកមូលដ្ឋានអំពីអក្សរ ឬ ចំណេះដឹង ដែលមានសភាពខុសៗគ្នា និង គោលបំណងផ្សេងៗនៃប្រភេទអត្ថបទ។*

មុននឹងកុមារអាចអានដោយខ្លួនឯង គ្រូអាចជួយពួកគេរៀនក្បួនជាមូលដ្ឋានមួយចំនួនអំពីការអាន ដោយការបង្ហាញ និង និយាយអំពីពួកគេ។ ក្បួនទាំងអស់នេះ អ្នកអប់រំហៅថា **បែបបទនៃការអានអក្សរ** (conventions of print)។ បែបបទនៃការអានអក្សរ មួយចំនួនគឺមានលក្ខណៈជាក់ស្តែងពេក រហូតដល់គ្រូបង្រៀនអាចនឹងភ្លេចថាកុមារអាចនឹងមិនដឹងអំពីបែបបទនោះ។ ឧទាហរណ៍មួយចំនួនអំពីបែបបទនៃការអានអក្សរសម្រាប់ភាសាខ្មែរគឺ...

- ត្រូវអានអត្ថបទតាមលំដាប់ទំព័រនៃសៀវភៅ
- ត្រូវចាប់ផ្តើមអានពីផ្នែកខាងលើនៃទំព័រ
- ត្រូវអានអត្ថបទពីឆ្វេងទៅស្តាំតាមបន្ទាត់នីមួយៗ
- ត្រូវអានដោយពុំមានការដកឃ្លាឡើយ នៅចន្លោះពាក្យជាច្រើន

- ត្រូវអានដោយមានការដកឃ្លានៅចន្លោះឃ្លា អនុប្រយោគ និងប្រយោគមួយចំនួន

បែបបទនៃការអានអក្សរមិនមានលក្ខណៈដូចគ្នាទេ សម្រាប់ភាសាទាំងអស់។

គ្រូបង្រៀនអាចជួយឱ្យសិស្សយល់ពីបែបបទនៃការអានអក្សរ និង អភិវឌ្ឍន៍បំនិនអានដោយការប្រើបច្ចេកទេសងាយៗមួយចំនួន។ គ្រូបង្រៀនគួរប្រើបច្ចេកទេសទាំងនេះ នៅពេលកំពុងអានអត្ថបទណាមួយទៅឱ្យ ឬ ជាមួយសិស្ស។ ភាគច្រើននៃបច្ចេកទេស ទាំងនេះមានលក្ខណៈសមស្របសម្រាប់សិស្សថ្នាក់ទី១-៣។ គ្រូបង្រៀនអាចប្រើប្រាស់បច្ចេកទេសខ្លះក្នុងចំណោមបច្ចេកទេសផ្សេងទៀត ដូចជា ការទស្សន៍ទាយ សម្រាប់គ្រប់កម្រិតថ្នាក់។

តើមានបច្ចេកទេសងាយៗអ្វីខ្លះ ដែលគ្រូបង្រៀនអាចប្រើនៅពេលអានអត្ថបទ/រឿងទៅកាន់សិស្សដែលអាចជួយពួកគេឱ្យរៀនអាន?

- មុននឹងគ្រូអាន គាត់បង្ហាញរូបភាព និង សួរសិស្សថាតើពួកគេអាចទស្សន៍ទាយថា អត្ថបទនេះនឹងនិយាយអំពីអ្វី។
- គ្រូអានអត្ថបទមួយលើកសិន ដោយឱ្យសិស្សស្តាប់តែប៉ុណ្ណោះ
- បន្ទាប់មកគ្រូអានដោយកាន់សៀវភៅ ដូច្នោះសិស្សទាំងអស់អាចមើលឃើញ
- នៅពេលគ្រូអាន គាត់អានតាមអត្ថបទដោយយកម្រាមដៃដាក់លើកន្លែងអានពីឆ្វេងទៅស្តាំ
- នៅពេលគ្រូអាន គ្រូបង្ហាញពីរបៀបនៅពេលដល់ចុងបន្ទាត់មួយ ភ្នែក/ម្រាមដៃរបស់គាត់ត្រឡប់ទៅរកជួរបន្ទាប់ទៀត និងចាប់ពីឆ្វេងទៅ ស្តាំ
- គ្រូបង្រៀនប្រាប់សិស្សឱ្យធ្វើតាមដោយមើលអត្ថបទនៅក្នុងសៀវភៅរបស់ពួកគេ ដោយប្រើម្រាមដៃ ក្នុងពេលគ្រូអាន
- គ្រូបង្រៀនឈរនៅគ្រប់កន្លែងក្នុងបន្ទប់ដើម្បីត្រួតពិនិត្យមើល ថាតើកុមារកំពុងធ្វើតាមឬទេ
- គ្រូបង្រៀនបញ្ឈប់ការអានក្នុងខណៈពេលណាមួយ ហើយសួរសិស្សថាតើពួកគេអាចទស្សន៍ទាយពាក្យឬឃ្លាបន្ទាប់បាន ឬទេ តាមរយៈការយល់ដឹងអត្ថន័យនៃរឿង។

គំនិតបង្រៀនទី៤: ការអភិវឌ្ឍន៍ការយល់ដឹងពី អត្ថបទ "ពេញលេញ"

*នៅក្នុងការបង្រៀនសរសេរ គ្រូភាគច្រើនផ្តោតអារម្មណ៍យ៉ាងខ្លាំងទៅលើអក្សរ និង ពាក្យ ច្រើនជាងទៅលើអត្ថបទទាំងមូល។ ជាលទ្ធផលនោះគឺថា កុមារមិនមានឱកាសច្រើនដើម្បីគិតអំពីអត្ថន័យ និង អ្វីដែលបង្កើតជាអត្ថបទមួយ "ពេញលេញ"។ វាធ្វើឱ្យកុមារជួបការលំបាកដើម្បីក្លាយជាអ្នកដែលមានជំនាញក្នុងការអាន និង ការសរសេរ បើសិនជាពួកគេពុំមានឱកាសគិតអំពីអត្ថបទទាំងមូល។ ទោះបីជាកុមារតូច ក៏ពួកគេចេះវិភាគអត្ថបទទៅតាមរបៀបងាយណាមួយផងដែរ បើសិនជាគ្រូចេះសួរសំណួរបានត្រឹមត្រូវ។ កុមារនឹងទទួលបានអត្ថប្រយោជន៍យ៉ាងច្រើន នៅក្នុងឆ្នាំបន្ទាប់លើការយល់ដឹងទាំងអស់នេះ នៅពេល ពួកគេចាប់ផ្តើមសរសេរអត្ថបទផ្ទាល់ខ្លួន។*

នៅពេលគ្រូ និង សិស្សអានចប់ គ្រូបង្រៀនគួរសួរសំណួរដល់សិស្សអំពីអត្ថបទទាំងមូល។

ខាងក្រោមនេះគឺជាឧទាហរណ៍នៃសំណួរមួយចំនួន ដែលគ្រូអាចសួរដើម្បីជួយសិស្សអភិវឌ្ឍន៍ការយល់ដឹងថាអ្វីជាអត្ថបទពេញលេញ

- *តើនរណាជាតួអង្គសំខាន់នៅក្នុងរឿង?*
- *តើអ្វីបានកើតឡើងនៅក្នុងអត្ថបទ ( ព្រឹត្តិការណ៍សំខាន់ ) ?*
- *តើព្រឹត្តិការណ៍ក្នុងរឿងកើតឡើងនៅឯណា?*
- *តើព្រឹត្តិការណ៍ក្នុងរឿងកើតឡើងនៅពេលណា?*
- *តើរឿងនេះចាប់ផ្តើមដោយរបៀបណា?*
- *តើអ្វីបានកើតឡើងនៅពេលបន្ទាប់... (ឱ្យកុមារនិយាយរឿងឡើងវិញដោយប្រើពាក្យផ្ទាល់របស់ពួកគេ) ?*
- *តើអ្វីកើតឡើងនៅពេលបញ្ចប់រឿង?*

| សំណួររបស់គ្រូបង្រៀន | លក្ខណៈនៃអត្ថបទពេញលេញ |
|---|---|
| តើនរណាជាតួអង្គសំខាន់នៅក្នុងរឿង? | តួអង្គ |
| តើអ្វីបានកើតឡើងនៅក្នុងអត្ថបទ ( ព្រឹត្តិការណ៍សំខាន់ ) ? | ព្រឹត្តិការណ៍ |
| តើព្រឹត្តិការណ៍ក្នុងរឿងកើតឡើងនៅឯណា? | ទីកន្លែង |
| តើព្រឹត្តិការណ៍ក្នុងរឿងកើតឡើងនៅពេលណា? | ពេលវេលា |
| តើរឿងនេះចាប់ផ្តើមដោយរបៀបណា? | សេចក្តីផ្តើម |
| តើអ្វីបានកើតឡើងនៅពេលបន្ទាប់... (ឱ្យកុមារនិយាយរឿងឡើងវិញដោយប្រើពាក្យផ្ទាល់របស់ពួកគេ) ? | តួសេចក្តី សាច់រឿងទាំងមូល |
| តើអ្វីកើតឡើងនៅពេលបញ្ចប់រឿង? | សេចក្តីបញ្ចប់ |
| | |
| នៅក្នុងអត្ថបទរឿងនេះ តើអ្នកចូលចិត្តផ្នែកណា? ហេតុអ្វី? | គិតកម្រិតខ្ពស់ |
| តើតួអង្គណាមួយក្នុងរឿងដែលអ្នកចូលចិត្ត? | គិតកម្រិតខ្ពស់ |

គំនិតបង្រៀនទី៥: សំណេរដើម និង អត្ថបទចរចា

មនុស្សមួយចំនួនដែលមិនបានធ្វើការនៅក្នុងសាលារៀនគិតថា "បំនិនសរសេរ" គឺមានលក្ខណៈដូចគ្នានឹង "បំនិនសរសេរដៃ" ។ ពួកគេគិតថាបើសិនជាមនុស្សចេះតួអក្សរ ហើយអាចសរសេរដោយប្រើខ្មៅដៃបាន នោះពួកគេចេះសរសេរហើយ ។

ជាការពិតណាស់ការរៀនសរសេរអក្សរ និង ពាក្យគឺជាផ្នែកមួយសំខាន់ណាស់នៅក្នុងការងាររបស់សិស្សនៅក្នុងថ្នាក់ទី១ ២ និង ទី៣ ។ ទោះបីជាយ៉ាងណាក៏ដោយ នៅថ្នាក់ទី៤ សិស្សគួរតែចាប់ផ្តើមអភិវឌ្ឍបំនិនផ្សេងទៀត ព្រមទាំងសមត្ថភាពសរសេរឱ្យបានស្អាត និង ប្រកបបានត្រឹមត្រូវ ។

បើសិនជាការសរសេរបានល្អ ប្រសើរជាងការសរសេរដៃដែលស្អាត និង ប្រកបបានត្រឹមត្រូវនោះ តើការសរសេរបានល្អនោះមានន័យដូចម្តេច? អ្នកអប់រំជាច្រើនយល់ស្របថា ***អ្នកនិពន្ធល្អគឺជាអ្នកដែលអាចបញ្ចូលអត្ថន័យបានច្បាស់លាស់ និង ប្រើប្រាស់អក្សរដោយសន្សំសំចៃ។***

មានការសិក្សាពីការសរសេរជាច្រើននៅក្នុងភាសាផ្សេងៗគ្នា លើពិភពលោកយើងនេះ។ ការសិក្សាទាំងអស់យល់ស្របថា

- មធ្យោបាយល្អដើម្បីក្លាយជាអ្នកសរសេរគឺត្រូវសរសេរអត្ថបទផ្ទាល់ខ្លួនឯង (ពោលគឺ ដោយការអនុវត្ត)
- ការចម្លងសំណេរពីអ្នកដទៃមិនមែនជាមធ្យោបាយល្អបំផុតដើម្បីបង្កើនបំណិនសរសេរនោះទេ (លើកលែងតែកុមារដែលនៅក្មេងពេក និង មិនទាន់ហ្វឹកហាត់សរសេរដៃនៅឡើយ)
- ការសរសេរគឺជាដំណើរការមួយដែលអ្នកសរសេរត្រូវតែសរសេរអ្វីមួយជាច្រើនដង (សរសេរពង្រាងច្រើនដង) មុននឹងបានជាអត្ថបទពេញលេញមួយ។
- វាជាការល្អគឺត្រូវពិភាក្សាអត្ថបទសរសេរជាមួយអ្នកដទៃមុននឹងបញ្ចប់
- អត្ថបទទាំងឡាយត្រូវបែងចែកទៅជាច្រើនប្រភេទ ហើយប្រភេទនីមួយៗមានចរិកលក្ខណៈផ្ទាល់របស់វា
- សិស្សដែលបានយល់ពីរចនាសម្ព័ន្ធមូលដ្ឋាន និង លក្ខណៈប្រភេទផ្សេងៗនៃការសរសេរ គឺជាអ្នកសរសេរដ៏ល្អ

វាជាការសំខាន់ចំពោះគ្រូបង្រៀនដែលត្រូវផ្តល់ឱកាសឱ្យសិស្ស ទោះបីជាកុមារតូចៗក៏ដោយ ឱ្យបង្កើតការសរសេរផ្ទាល់ខ្លួន។ នេះមានន័យថាការសរសេរមានផ្ទុកនូវគំនិតផ្ទាល់របស់កុមារ វាមិនមែនជាការចម្លងពីក្តារខៀន ឬ សៀវភៅទេ។ កុមារដែលសរសេរផ្ទាល់ខ្លួន នឹងលូតលាស់ឡើងដោយមានជំនឿចិត្ត ក្នុងខណៈដែលពួកគេអនុវត្ត... ប្រយោគមួយ នឹងក្លាយទៅជាប្រយោគពីរ បន្ទាប់មកក្លាយទៅជាប្រយោគ៣... នឹងបន្ទាប់មកទៀតក្លាយទៅជាកថាខណ្ឌមួយ...ចំនុចនីមួយៗក្លាយ ជាអត្ថបទពេញលេញ។ វាជាការសំខាន់ផងដែរថា គ្រូបង្រៀនត្រូវអនុញ្ញាតឱ្យកុមារមើលឧទាហរណ៍នៃសំណេរដើមរបស់គេ-ដែលតាំងបង្ហាញនៅលើជញ្ជាំងថ្នាក់រៀន គៀបភ្ជាប់នឹងខ្សែរនៅខាងលើតុសិស្ស ឬ សរសេរបង្ហាញនៅលើក្តារខៀន។

ប៉ុន្តែចំពោះកុមារដែលមិនទាន់ចេះសរសេរនៅឡើយ តើពួកគេអាចបង្កើតសំណេរដើមដោយរបៀបណា? ពួកគេអាចធ្វើបានតាមដំណើរការមួយដែលហៅថា "អត្ថបទចរចា"។ នេះមានន័យថា គ្រូបង្រៀន និង កុមារត្រូវពិភាក្សាគ្នាអំពីអ្វីដែលកុមារចង់និយាយ ហើយនៅពេលកុមារយល់ព្រម គ្រូបង្រៀនត្រូវសរសេរឱ្យពួកគេ។ គ្រូបង្រៀន និង កុមារត្រូវអានអត្ថបទនោះជាមួយគ្នា។ ទោះបីជាពួកគេមិនបានសរសេរដោយខ្លួនពួកគេក៏ដោយ កុមារមានអារម្មណ៍ជាកម្មសិទ្ធិទៅលើអត្ថបទនោះ ពីព្រោះវាជាគំនិតរបស់ពួកគេ។ ដំណើរការដូចគ្នានេះ អាចប្រើប្រាស់នៅពេលកុមារគូរគំនូរ។ គ្រូបង្រៀនអាចសួរពីអ្វីដែលកុមារចង់សរសេរនៅខាងក្រោមគំនូរ បន្ទាប់មកគ្រូសរសេរអ្វីដែលពួកគេនិយាយនោះ។

គ្រូបង្រៀនអាចប្រើប្រាស់វិធីចរចាអត្ថបទប្រកបដោយជោគជ័យបាន ជាមួយសិស្សថ្នាក់ខ្ពស់ដែលអាចពិភាក្សាក្នុងក្រុមនូវអ្វីដែលពួកគេនិយាយ (ការចរចា) បន្ទាប់មកសមាជិកម្នាក់អាចសរសេរគំនិតរបស់ក្រុមនោះ។

## គំនិតបង្រៀនទី៦: ដំណើរការសរសេរ (ការធ្វើពង្រាង និង ការប្រជុំពិភាក្សា)

មានអ្នកសរសេរមួយចំនួនតូច ដែលអាចសរសេរអត្ថបទល្អឥតខ្ចោះក្នុងរយៈពេលតែមួយលើក។ ការសរសេរភាគច្រើនត្រូវឆ្លងកាត់ដំណើរការ**ពង្រាង**មួយ ពីរ ឬច្រើនមុននឹងអ្នកសរសេរពេញចិត្តនឹងអត្ថបទនោះ។ នៅពេលបច្ចុប្បន្ននេះមានការងាយស្រួលណាស់ ដោយប្រើកុំព្យូទ័រជាអ្នកកែរតម្រូវ ដែលគេអាចធ្វើបានគ្រប់ពេលវេលា។ បើសរសេរដៃ វាមានការលំបាកច្រើន ហើយមានភាពរញ៉េរញ៉ៃទៀតផង។ ការគូសខ្វែងចោល ការបញ្ចូលព័ត៌មានថ្មី និង ការកែតម្រូវផ្សេងទៀត គឺត្រូវធ្វើនៅលើក្រដាស ឬ ក្តារឆ្នួន ឬ លើក្តារខៀន។ ភាពជាអ្នកសរសេរមិនត្រូវរិះគន់ចំពោះពង្រាងដែលគ្មានសណ្តាប់ធ្នាប់នេះឡើយ-ការផ្លាស់ប្តូរច្រើនបង្ហាញថាអ្នកសរសេរយកចិត្តទុកដាក់ខ្លាំងអំពីការបង្កើត**ពង្រាងចុងក្រោយ**ដែលមានគុណភាពខ្ពស់។

អ្នកសរសេរជាច្រើនទទួលបានផលប្រយោជន៍ពីការដែលឱ្យអ្នកផ្សេងអាន និង ផ្តល់នូវគំនិត យោបល់លើពង្រាងសំណេររបស់ពួកគេ។ ការធ្វើបែបនេះ គេហៅថា **ការប្រជុំពិភាក្សា**។ នៅក្នុងសន្និសិទប្រជុំ អ្នកដែលអាន ពង្រាងគួរផ្តោតជាសំខាន់ទៅលើអត្ថន័យ-តើវាច្បាស់លាស់ឬទេ? តើវាគួរឱ្យចាប់អារម្មណ៍ឬទេ? តើផ្នែកដែលល្អ អាចធ្វើឱ្យកាន់តែល្អថែមទៀតឬទេ? កំហុសនៅក្នុងការប្រកបមិនសំខាន់ទេ (ពីព្រោះវាមិនមែនជាពង្រាងចុងក្រោយ) នៅក្នុងការប្រជុំពិភាក្សា។ នៅក្នុង **ពង្រាងចុងក្រោយ** អត្ថន័យគួរតែមានលក្ខណៈច្បាស់លាស់ ហើយរាល់កំហុសទាំងឡាយ រួមមាន ការប្រកប និង សញ្ញាវណ្ណយុត្តិត្រូវកែតម្រូវ។

ពង្រាងទាំងឡាយអាចធ្វើនៅលើក្រដាសចោលចាស់ៗ លើក្តារឆ្នួន ឬ លើក្តារខៀនតូច។ ការសរសេរនៅលើក្តារខៀនតូចអាចធ្វើការកែតម្រូវងាយជាង។ វាក៏មានលក្ខណៈប្រសើរផងដែរ បើសិនជាក្រុមតូចកំពុងធ្វើការរួមគ្នានៅលើអត្ថបទមួយពីព្រោះពួកគេទាំងអស់អាចនៅជុំគ្នា និង ពិនិត្យមើលអត្ថបទរួមគ្នា។

# ឯកសារទី១៥

## អត្ថបទជាក់ស្តែង-ប្រភព ឧទាហរណ៍ គោលបំណង ទស្សនិកជន

| *អត្ថបទជាក់ស្តែង* | *ឧទាហរណ៏* | *គោលបំណង* | *ទស្សនិកជន* |
|---|---|---|---|
| *ការផ្សាយពាណិជ្ជកម្ម* | *គ្រប់ផលិតផល* | *ដើម្បីលក់ផលិតផល* | *គ្រប់គ្នាដែលចង់ទិញផលិតផល* |
| *សេចក្តីណែនាំពីរបៀបប្រើ* | *ម៉ាស៊ីនចាក់វីស៊ីឌី* | *ជម្រាបជូន ការពារការខូចខាត* | *គ្រប់គ្នាដែលទិញ និង ប្រើប្រាស់ផលិតផល* |
| *រូបមន្តធ្វើម្ហូប* | *ផលិតផលអាហារ* | *បង្ហាញពីសេចក្តីណែនាំ សម្រាប់ចម្អិន* | *គ្រប់គ្នាដែលចង់ចម្អិនអាហារ នោះ* |
| *ព័ត៌មាន* | *ប៉ូស្ទ័រអំពីការបោះឆ្នោត* | *បញ្ចុះបញ្ចូលប្រជាជន ឱ្យបោះឆ្នោតជូនគណបក្ស ណាមួយ* | *គ្រប់គ្នាដែលមានសិទ្ធិបោះឆ្នោត* |
| *ព័ត៌មាន* | *ប៉ូស្ទ័រយល់ដឹងពីសុខភាព* | *បង្ហាញពីរបៀបដែលធ្វើ ឱ្យមានសុខភាពល្អ ឬ ការប្រថុយគ្រោះថ្នាក់* | *គ្រប់គ្នាដែលចេះអាន* |
| *ព័ត៌មាន* | *សញ្ញាបម្រាមតាមផ្លូវ* | *បង្កើនការពិចារណា ប្រាប់ដំណឹង បញ្ចុះបញ្ចូល* | *គ្រប់គ្នាដែលចេះអាន និង យល់* |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |

## ឯកសារទី១៦

## បញ្ជីសម្ភារ

| លរ | ការបរិយាយពីប្រភេទសម្ភារ | ចំនួន | ផ្សេងៗ |
|---|---|---|---|
| ១ | កាតាប | ១ | |
| ២ | ប្រដាប់កិបក្រដាស | ១ | |
| ៣ | គ្រាប់កិប | ១ ប្រអប់ | |
| ៤ | គូល័រទៀន | ២ ប្រអប់ | |
| ៥ | ហ្វឺតក្រដាសពណ៌ខ្មៅ | ៣ ដើម | |
| ៦ | ហ្វឺតក្រដាសពណ៌ក្រហម | ៣ ដើម | |
| ៧ | ទឹកហ្វឺតក្រដាសពណ៌ខ្មៅ | ១ ដប | |
| ៨ | ទឹកហ្វឺតក្រដាសពណ៌ក្រហម | ១ ដប | |
| ៩ | ប៊ិចខៀវ | ២ ដើម | |
| ១០ | ក្រដាសរ៉ាមអាកាត់ | ១ រ៉ាម | |
| ១១ | កាវទឹក | ១ ដប | |
| ១២ | ស្កុតក្រដាស | ១ ដុំ | |
| ១៣ | ដែកគោលវាយជញ្ជាំង | ២ កញ្ចប់ | |
| ១៤ | អក្សរចល័ត | ១ ឈុត | |
| ១៥ | កៅស៊ូកង | ២ ខាំ | |
| ១៦ | បំពង់បឺត | ៣០០ ដើម | |
| ១៧ | សៀវភៅសរសេរ ១២០ទំព័រ | ៤ ក្បាល | |
| ១៨ | ក្រដាសរ៉ាមធំ | ១០ សន្លឹក | |
| ១៩ | ក្រដាសកាតុង | ៥ សន្លឹក | |
| ២០ | ខ្សែនីឡុង | ៥០ ម | |
| ២១ | បញ្ជីស្រង់ពិន្ទុ | ១ ក្បាល | |
| ២២ | បញ្ជីហៅឈ្មោះសិស្ស | ១ ក្បាល | |